**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ កក្កដា ឆ្នាំ២០២២


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ៖ **កញ្ញា ខុន ស៊ីណា**

**កញ្ញា អាន ស្រីខៀវ**

សាស្ត្រាចារ្យណែនាំ៖

លោកសាស្ត្រាចារ្យ **ញឹក ខុទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ខុន ស៊ីណា** និងឈ្មោះ **អាន ស្រីខៀវ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

១. លោកឪពុក **ម៉ន សុខុន** និងអ្នកម្តាយ **នៅ ឡើន**

២. លោកឪពុក **នូ អាន** និងអ្នកម្តាយ **ខាំ នីវ៉ាន់។**

សូមសម្តែងនូវការគោរព និងដឹងគុណជាទីបំផុតដល់លោកអ្នកមានគុណទាំងពីរ ដែលបានបង្កើត ព្រមទាំងបំពេញករណីកិច្ចជាឪពុកម្តាយដ៏មានព្រហ្មវិហារធម៌សម្រាប់យើងខ្ញុំ និងអនុញ្ញាតឱ្យយើងខ្ញុំទទួលបានការសិក្សាអប់រំខ្ពង់ខ្ពស់រហូតដល់សាកលវិទ្យាល័យ ដោយលោកទាំងពីរតែងតែប្រៀនប្រដៅ អប់រំណែនាំ ជ្រោមជ្រែង គាំទ្រ ទំនុកបម្រុងទាំងប្រាក់ឧបត្ថម្ភ សម្ភារៈសិក្សា និងការផ្គត់ផ្គង់ផ្សេងៗជាច្រើនទៀត។ ចំពោះគុណូបការៈរបស់អ្នកមានគុណទាំងពីរ មានទំហំធំធេងគ្មានអ្វីប្រៀបផ្ទឹមបាន។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ធា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង និងសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រគ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្តក្នុងការបង្ហាត់បង្រៀនត្រួសត្រាយផ្លូវដល់និស្សិត និងបានផ្តល់ឱកាសឱ្យយើងខ្ញុំទទួលបានការសិក្សាអប់រំដ៏ល្អឥតខ្ចោះ ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧុធី** ជាសាស្ត្រាចារ្យណែនាំសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ណែនាំ ត្រួតពិនិត្យ និងព្យាយាមក្នុងការកែលម្អកិច្ចការស្រាវជ្រាវនេះ តាំងពីចំណុចចាប់ផ្តើមរហូតមកដល់ទីបញ្ចប់ ដើម្បីបង្កើតនូវសារណានេះឡើង។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរសព្ទសាធុការជូនចំពោះ មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ និងនិស្សិត ព្រមទាំង ក្រុមគ្រួសារ ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន មានសុខភាពល្អ ជៀសផុតពីជំងឺរាតត្បាតកាចសាហាវទាំងឡាយដែលកើតឡើងនាពេលបច្ចុប្បន្ននេះ ជាពិសេសសូមគោរពជូននូវពុទ្ធពរទាំង ០៤ (បួន) ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងអំឡុងពេលបួនឆ្នាំនេះ យើងខ្ញុំបានខិតខំប្រឹងប្រែងក្រេបជញ្ជក់យកចំណេះដឹងផ្នែកជំនាញនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាលទ្ធផលបានមកវិញ យើងខ្ញុំទទួលបានចំណេះដឹងទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត ព្រមទាំងបទពិសោធជាច្រើនអនេក។ រយៈពេលបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកនីតិសាស្ត្របានមកដល់ ក៏ជាពេលវេលាដែលសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្តល់ឱកាសដល់រូបយើងខ្ញុំបានរៀបចំស្រាវជ្រាវ ចងក្រង និងរៀបរៀងសារណានេះឡើង ដើម្បីទុកជាស្នាដៃសម្រាប់ការបញ្ចប់បរិញ្ញាបត្រ និងទុកជាឯកសារស្រាវជ្រាវមួយជូនដល់សិស្សានុសិស្សជំនាន់ក្រោយ។ ក្នុងសារណានេះ យើងខ្ញុំទាំងពីរបានជ្រើសរើសយកប្រធានបទផ្នែកនីតិវិធីរដ្ឋប្បវេណីពាក់ព័ន្ធនឹង **ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ដោយសារតែប្រធានបទនេះតែងតែកើតមានជារឿងរាល់ថ្ងៃនៅក្នុងសង្គមបច្ចុប្បន្ន។ ការសិក្សាលើប្រធានបទនេះ យើងខ្ញុំបានលើកយកគ្រប់ដំណាក់កាលទាំងអស់នៅក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដូចជា ការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន និងបណ្តឹងឧបាស្រ័យក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវមួយនេះនឹងក្លាយជាឯកសារដ៏មានប្រយោជន៍ដែលផ្តល់ចំណេះដឹងជាច្រើនក្នុងវង្វង់ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដល់និស្សិត និងប្រិយមិត្តអ្នកអានដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្ត។ សារណានេះ យើងខ្ញុំទាំងពីរបានព្យាយាមរៀបរៀងប្រកបដោយយកចិត្តទុកដាក់ខ្ពស់បំផុត ដោយមានលើកយកនូវមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតមកធ្វើការបកស្រាយ ចង្អុលបង្ហាញ និងយកជាឯកសារយោង។

ជាចុងក្រោយ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ និងមានមោទកភាពខ្លាំងណាស់ប្រសិនបើឯកសារនេះជាប្រភពចំណេះដឹងដែលអាចជួយសម្រួលដល់ការសិក្សារបស់ប្រិយមិត្តដែលជានិស្សិត ហើយយើងខ្ញុំក៏សូមអភ័យទោសទុកជាមុនបើមានកំហុសឆ្គងដែលពុំបានព្រាងទុកបានកើតឡើងដោយប្រការណាមួយ និងធ្វើការស្វាគមន៍រាល់ការរិះគន់ក្នុងន័យស្ថាបនា ព្រោះទោះបីយើងខ្ញុំបានខិតខំ និងព្យាយាមអស់ពីកម្លាំងកាយ និងកម្លាំងចិត្តយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតកើតឡើងជាក់ជាពុំខាន។ ហេតុដូច្នេះយើងខ្ញុំរីករាយនឹងទទួលពាក្យរិះគន់ក្នុងន័យស្ថាបនាជានិច្ច ហើយព្យាយាមកែប្រែនូវកំហុសឆ្គងទាំងឡាយ ដើម្បីឱ្យវណ្ណកម្មមួយនេះកាន់តែមានភាពប្រសើរឡើង។

# មាតិកា

**សេចក្តីផ្តើម**..........១

១. លំនាំបញ្ហានៃការស្រាវជ្រាវ..........១

២. ចំណោទបញ្ហា..........១

៣. គោលបំណងនៃការស្រាវជ្រាវ..........២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ..........២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ..........២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ..........៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........៣

**ជំពូកទី១**

**សញ្ញាណទូទៅ និងការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ**

**ផ្នែកទី១៖ សញ្ញាណទូទៅ**..........៤

១. និយមន័យនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ..........៤

២. គោលបំណងនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ..........៤

៣. ចរិតលក្ខណៈនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ..........៥

៤. លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន..........៦

**ផ្នែកទី២៖ ការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**..........៨

១. របៀបដាក់ពាក្យសុំ..........៨

២. ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ..........៨

៣. ឯកសារភ្ជាប់ជាមួយពាក្យសុំ..........១០

**ផ្នែកទី៣៖ សមត្ថកិច្ចសាលាជម្រះក្តី**..........១២

១. តុលាការមានសមត្ថកិច្ច..........១២

២. ករណីមិនចូលសមត្ថកិច្ច..........១៣

**ផ្នែកទី៤៖ ការពិនិត្យរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**..........១៤

១. ការពិនិត្យលក្ខខណ្ឌទម្រង់របស់ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន..........១៤

២. សោហ៊ុយនៃការរឹបអូសជាបណ្តោះអាសន្ន..........១៤

៣. ប្រាតិភោគ..................................................................................................................១៥

## ជំពូកទី២

## ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ផ្នែកទី១៖ ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**..............១៧
១. ក្បាលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន..........................................................១៧
២. អត្តសញ្ញាណរបស់ភាគី........................................................................................១៨
៣. ខ្លឹមសារនៃការទាមទារ..........................................................................................១៨
៤. សំអាងហេតុ.....................................................................................................១៨
៥. សេចក្ដីសម្រេចបញ្ជាប់........................................................................................១៨
**ផ្នែកទី២៖ ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន**..............................................១៩
១. គោលបំណងនៃប្រាក់រំដោះ....................................................................................១៩
២. ចំនួននៃប្រាក់រំដោះ..............................................................................................១៩
៣. វិធីនៃការដាក់ប្រាក់រំដោះ.......................................................................................២០
**ផ្នែកទី៣៖ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**.........................................២០
១. ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន.......................................................................២០
២. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង........................................................២២
៣. នីតិវិធីនៃការបញ្ជូន..............................................................................................២២

## ជំពូកទី៣

## ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ផ្នែកទី១៖ លក្ខខណ្ឌនៃការអនុវត្តដីការឹបអូសជាបណ្ដោះអាសន្ន**...................................២៦
១. អំឡុងពេលនៃការអនុវត្ត.........................................................................................២៦
២. ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត................................................................................២៧
**ផ្នែកទី២៖ ពាក្យសុំឱ្យអនុវត្តដីការឹបអូសជាបណ្ដោះអាសន្ន**.........................................២៨
១. ស្ថាប័នអនុវត្តដីការឹបអូសជាបណ្ដោះអាសន្ន...............................................................២៨
២. ពាក្យសុំអនុវត្ត.....................................................................................................២៨
**ផ្នែកទី៣៖ ការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន**................................៣០
១. ការផ្ដុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី............................................៣១

២. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជីដីធ្លី....................................៣២

## ជំពូកទី៤

## បណ្ដឹងឧបាស្រ័យក្នុងរឿងក្ដីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

**ផ្នែកទី១៖ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**....................................៣៥

១. នីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ា..................................................................៣៥

២. ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន.......................៣៦

**ផ្នែកទី២៖ ការតវ៉ាចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន**..................................................៣៦

១. បណ្ដឹងតវ៉ារបស់តតិយជន...........................................................................................៣៦

២. តុលាការមានសមត្ថកិច្ច...............................................................................................៣៦

**ផ្នែកទី៣៖ ការសុំលុបចោល និងផ្អាកលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**............៣៧

១. ការលុបចោល និងការផ្អាកលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន...................................៣៧

២. ការលុបចោលដោយការផ្លាស់ប្ដូរស្ថានភាព...................................................................៣៧

**ផ្នែកទី៤៖ បណ្ដឹងជំទាស់**..................................................................................................៣៧

១. នីតិវិធី និងអំឡុងពេលបណ្ដឹងជំទាស់.............................................................................៣៨

២. ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្ដឹងជំទាស់ ...................................................................៣៨

**ផ្នែកទី៥៖ ការសុំឱ្យជំនុំជម្រះសារជាថ្មី**.................................................................................៣៩

១. មូលហេតុដែលអាចសុំប្ដឹងជំនុំជម្រះសាជាថ្មី..................................................................៣៩

២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី...............................៤០

៣. អំឡុងពេលនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី.........................................................៤១

៤. តុលាការនៃការជំនុំជម្រះសាជាថ្មី...................................................................................៤១

**សេចក្ដីសន្និដ្ឋាន**...........................................................................................................៤២

**អនុសាសន៍**...................................................................................................................៤៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមនីមួយៗ ការរស់នៅរបស់ប្រជាពលរដ្ឋម្នាក់ៗរមែងតែងតែមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ហើយការធ្វើទំនាក់ទំនងនេះគឺជាមូលហេតុនាំឱ្យមានចំណងគតិយុត្តដែលបង្កើតឱ្យមានសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី។ ក្នុងករណីដែលភាគីណាមួយមិនបានអនុវត្តនូវកាតព្វកិច្ចទាំងនោះទេ វានឹងបង្កឱ្យមានវិវាទកើតឡើង។ ជាមួយគ្នានេះដែរ នៅពេលដែលមានវិវាទកើតឡើង ជាធម្មតាតែងតែឮសំណួរមួយសួរថាតើមានដំណោះស្រាយដូចម្តេចក្នុងការដោះស្រាយវិវាទទាំងនោះ? នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីយន្តការដោះស្រាយវិវាទ ក៏ដូចជាយន្តការអនុវត្តសិទ្ធិតាមផ្លូវតុលាការ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងសង្គម។ ដូច្នេះហើយ នៅពេលដែលមានវិវាទកើតចេញពីទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច អ្នកដែលមានសិទ្ធិហៅថា **ម្ចាស់បំណុល** អាចទាមទារអ្នកដែលមានកាតព្វកិច្ចហៅថា **កូនបំណុល** ឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមផ្លូវតុលាការបាន។ ទម្រាំទទួលបានសេចក្តីសម្រេចពីតុលាការ ត្រូវចំណាយពេលវេលាយូរ ដែលនាំឱ្យសិទ្ធិដែលត្រូវអនុវត្តនាពេលអនាគតពិបាកក្នុងការអនុវត្ត ឬពេលខ្លះអាចនឹងមិនបានអនុវត្តថែមទៀត ដោយសារការប្រែប្រួលនូវស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ក្នុងអំឡុងពេលនៃនីតិវិធីបណ្តឹងអង្គសេចក្តី។ ហេតុនេះដើម្បីបង្ការកុំឱ្យមានស្ថានភាពបែបនេះកើតឡើង និងសេចក្តីរំពឹងនូវការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលដែលឈ្នះក្តីត្រូវបានអាក់ខាន ទើបក្រមនីតិវិធីរដ្ឋប្បវេណីបង្កើតឱ្យមានយន្តការក្នុងការរក្សាការពារទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីបង្ការ និងទប់ស្កាត់ជាមុនកុំឱ្យមានការប្រែប្រួលទ្រព្យសម្បត្តិរបស់កូនបំណុល ដែលជាហេតុនាំឱ្យម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ការរក្សាការពារនោះគឺការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

## ២. ចំណោទបញ្ហា

បន្ទាប់ពីមានវិវាទដែលកើតចេញពីទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចកើតឡើងហើយ ក្រមនីតិវិធីរដ្ឋប្បវេណីផ្តល់សិទ្ធិឱ្យម្ចាស់បំណុលដែលបានបាត់បង់ផលប្រយោជន៍ អាចពឹងពាក់តុលាការដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តនាពេលអនាគតបានតាមរយៈការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

ដើម្បីសម្រេចនូវការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល តើត្រូវឆ្លងកាត់កិច្ចដំណើរការនីតិវិធីអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទសារណានេះ មានគោលបំណងសំខាន់ក្នុងការស្វែងយល់ថាតើដំណើរការលំហូរនីតិនីមួយៗនៃការរឹបអូសជាបណ្ដោះអាសន្នត្រូវឆ្លងកាត់អ្វីខ្លះដើម្បីមានភាពរលូន និងត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់ជាធរមាន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងសារណានេះ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវដោយយកនីតិវិធីអនុវត្តចាប់ឆ្នាំ២០០៧ ពោលគឺចាប់ពីពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីចូលជាធរមានទូទាំងប្រទេសក្នុងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក្នុងគន្ថីទី៧ មាត្រា៥៣១បានចែងអំពីប្រភេទនៃការចាត់ចែងរក្សាការពារមាន **បី** ចំណុចរួមមាន៖ **ក**. ការរឹបអូសជាបណ្ដោះអាសន្ន **ខ**. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង **គ**. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។ ប៉ុន្តែនៅក្នុងកិច្ចការស្រាវជ្រាវនេះ ជ្រើសរើសយកតែ **ការរឹបអូសជាបណ្ដោះអាសន្ន** យកមកពិចារណាតែប៉ុណ្ណោះ។ ដោយឡែកនៅក្នុងការរឹបអូសជាបណ្ដោះអាសន្ន មានកម្មវត្ថុនៃការរឹបអូសជាច្រើនដូចជា ចលនវត្ថុ អចលនវត្ថុ នាវា និងសិទ្ធិលើបំណុល ប៉ុន្តែក្នុងសារណានេះលើកយកតែកម្មវត្ថុជា **អចលនវត្ថុ** សម្ដៅទៅលើដីធ្លីតែមួយប៉ុណ្ណោះដើម្បីធ្វើការសិក្សាស្រាវជ្រាវ ពោលគឺ **ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**។ ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុសំដៅដល់ការចាត់ចែងដែលកម្រិតនូវទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីការពារ និងអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលក្នុងបំណងឱ្យសងជាប្រាក់នាពេលអនាគត។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

យើងខ្ញុំលើកយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវដើម្បីទទួលបានចំណេះដឹង មិនត្រឹមតែផ្នែកទ្រឹស្តីប៉ុណ្ណោះទេ ព្រមទាំងទទួលបាននូវចំណេះដឹងផ្នែកអនុវត្តជាក់ស្តែងទៀតផងនៅក្នុងនីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។ ការស្រាវជ្រាវប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំដើម្បីទទួលបានការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយជោគជ័យ និងជាទុនដ៏វិសេសវិសាលសម្រាប់ឱ្យយើងខ្ញុំទាំងពីរយកទៅអនុវត្តក្នុងជំនាញវិជ្ជាជីវៈនាពេលអនាគតដ៏ខ្លីខាងមុខ។ ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវនេះមិនត្រឹមតែចូលរួមចំណែកអភិវឌ្ឍប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងទុកជាឯកសារមួយសម្រាប់ជាប្រយោជន៍ដល់ប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់អំពីនីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដើម្បីទទួលបានការយល់ដឹងបន្ថែមកាន់តែច្បាស់លាស់ថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ យើងខ្ញុំអនុវត្តនូវវិធីសាស្ត្រពីរដើម្បីចងក្រងសារណានេះឡើង។ ទី១ យើងខ្ញុំបានធ្វើការសម្ភាសន៍ជាមួយអ្នកអនុវត្តច្បាប់ដែលមានបទពិសោធន៍ច្រើនឆ្នាំ ដូចជា ចៅក្រម និងក្រឡាបញ្ជីជាដើម។ ទី២ យើងខ្ញុំបានប្រមូលឯកសារពីការចូលរួមសិក្ខាសាលាដែលឧទ្ទេសនាមដោយ ចៅក្រម ក្រឡាបញ្ជី ព្រមទាំងដកស្រង់ពីឯកសារគតិយុត្តមួយចំនួនដូចជា ច្បាប់ ប្រកាសអន្តរក្រសួង សេចក្តីណែនាំជាអាទិ៍។ បន្ថែមពីនេះទៅទៀត យើងខ្ញុំបានប្រមូល និងស្រាវជ្រាវឯកសារពាក់ព័ន្ធពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមប្រព័ន្ធអេឡិចត្រូនិចផងដែរ។

ជាកិច្ចបន្ទាប់ យើងខ្ញុំបានយកទិន្នន័យដែលទទួលបានមកធ្វើការសិក្សាស្វែងយល់ វិភាគ និងប្រៀបធៀបទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដើម្បីរកចំណុចពិសេស ចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីឈានទៅរកការសន្និដ្ឋានរួម និងការផ្តល់អនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយ និងឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរនៅក្នុងចំណោទបញ្ហាខាងលើនេះឱ្យបានស៊ីជម្រៅ ហើយច្បាស់លាស់ ក្នុងសារណានេះយើងខ្ញុំនឹងធ្វើការបែងចែកជាបួនជំពូករួមមាន៖

**ជំពូកទី១ សញ្ញាណទូទៅ និងការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ជំពូកទី២ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ជំពូកទី៣ ការអនុវត្តនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ជំពូកទី៤ បណ្តឹងឧបាស្រ័យក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

# ជំពូកទី១
# សញ្ញាណទូទៅ និងការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជា
# បណ្ដោះអាសន្នចំពោះអចលនវត្ថុ

# ជំពូកទី១

# សញ្ញាណទូទៅ និងការដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុ

## ផ្នែកទី១ សញ្ញាណទូទៅ

### ១. និយមន័យនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺជាការចាត់ចែងមួយដែលកម្រិតនូវការចាត់ទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។[1]

អចលនវត្ថុសំដៅលើដីធ្លី និងវត្ថុដែលជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានមានដូចជា អាគារ សំណង់ និងដំណាំធម្មជាតិ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់បានកំណត់ថាជាអចលនវត្ថុ។[2] ជាងនេះទៅទៀត អចលនវត្ថុនឹងត្រូវរឹបអូសជាបណ្តោះអាសន្នលើដី ឬអាគារដែលត្រូវបានចុះបញ្ជី ឬចំណែកកម្មសិទ្ធិអវិភាគនៃអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។

ជារួមមក ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺសំដៅទៅលើការចាត់ចែងដែលកម្រិតនូវការចាត់ចែងលើដីធ្លី ឬវត្ថុដែលជាប់នៅនឹងដីហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបាន របស់កូនបំណុល ដើម្បីរក្សាការពារអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។

### ២. គោលបំណងនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

គោលបំណងនៃការរឹបអូសជាបណ្តោះអាសន្ន គឺដោយសារតែមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនបានធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬប្រសិនបើមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារតែមានវិវាទអំពី ទំនាក់ទំនងនៃសិទ្ធិ ដូច្នេះហើយបុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទាររឹបអូសជាបណ្តោះអាសន្នបាន។[3] ការរឹបអូសជាបណ្តោះអាសន្ននេះជានីតិវិធីសំខាន់ក្នុងការការពារសិទ្ធិរបស់ម្ចាស់បំណុល ហើយធានាឱ្យបាននូវការរក្សាស្ថានភាពដើមដែលជាទ្រព្យសម្បត្តិបច្ចុប្បន្នរបស់កូនបំណុលឱ្យមានស្ថេរភាព។

---

[1] សូមមើលមាត្រា៥៣១.ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[2] សន្ទានុក្រម ផ្នែករដ្ឋប្បវេណីលេខ ១៧៦

[3] មាត្រា៥៣០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

## ៣. ចរិតលក្ខណៈនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

### ក. លក្ខណៈបន្ទាប់បន្សំ

ការរឹបអូសជាបណ្តោះអាសន្ន គឺជានីតិវិធីបន្ទាប់បន្សំនៃបណ្តឹងអង្គសេចក្តី។ នៅពេលដែលមិនមានការដាក់បណ្តឹងអង្គសេចក្តីទេ នឹងត្រូវលុបចោលតាមពាក្យសុំរបស់កូនបំណុល។ បានសេចក្តីថានៅពេលដែលតុលាការបង្គាប់ឱ្យដាក់បណ្តឹងអង្គសេចក្តីអំឡុងពេល ០២ (ពីរ) សប្តាហ៍ ម្ចាស់បំណុលត្រូវតែដាក់ បើមិនដូច្នេះទេ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវលុបចោល។[4]

### ខ. លក្ខណៈបណ្តោះអាសន្ន

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីបណ្តោះអាសន្ននៃបណ្តឹងអង្គសេចក្តីដោយសារ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទេ។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នគ្រាន់តែជាវិធីមួយក្នុងការពារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលកុំឱ្យបាត់បង់ផលប្រយោជន៍ និងដើម្បីទប់ស្កាត់កូនបំណុលក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ ប៉ុន្តែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះមិនមានន័យថាម្ចាស់បំណុលអាចយកទៅអះអាងថាខ្លួនមានសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនៅក្នុងដីកាសម្រេចទេ។ ដីកាសម្រេចនេះគ្រាន់តែមានការការពារជាបណ្តោះអាសន្នទម្រាំអាចសម្រេចគោលបំណងនូវការអនុវត្តដោយបង្ខំនាពេលអនាគតប៉ុណ្ណោះ។

### គ. បន្ទាន់បន្ទំ

ការរឹបអូសជាបណ្តោះអាសន្ន មិនអាចសម្រេចគោលបំណងបានទេ ប្រសិនបើមិនអនុវត្តឱ្យបានឆាប់រហ័ស។ សេចក្តីសម្រេចទាក់ទងនឹងនីតិវិធីដីកាសម្រេចរក្សាការពារត្រូវធ្វើឡើងដោយដីកាសម្រេច[5] ហើយសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ គឺគ្រាន់តែធ្វើ**សេចក្តីបញ្ជាក់ដំបូង**[6] ជាការគ្រប់គ្រាន់[7] ។ ម្យ៉ាងវិញទៀត ការចាត់ចែងរក្សាការពារត្រូវបានបង្គាប់ជាវិធានការសម្រាប់ឱ្យទាន់ស្ថានភាពជាបន្ទាន់ ហើយត្រូវអនុវត្តភ្លាម ហេតុនេះមានពេល២សប្តាហ៍នៃអំឡុងពេលអនុវត្ត។ យ៉ាងណាមិញ បើចាប់ផ្តើមសកម្មភាពអនុវត្តក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍នោះជាការគ្រប់គ្រាន់ហើយចំពោះសកម្មភាពអនុវត្តបន្តពេលក្រោយ ប៉ុន្តែនីតិវិធីបន្តបន្ទាប់ពីនេះមិនបានកំណត់ពេលវេលាទេ។

---

[4] មាត្រា៥៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[5] មាត្រា ៥៣៥.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] សេចក្តីបញ្ជាក់ដំបូង គឺជារបៀបទទួលស្គាល់អង្គហេតុជាស្ថាពរ ទោះបីជាសេចក្តីបញ្ជាក់ដំបូងនោះ មានកម្រិតនៃជំនឿទុកចិត្ត (កម្រិតនៃការបញ្ជាក់) ទាបជាងការបញ្ជាក់ក៏ដោយ។ ករណីដែលជាការបញ្ជាក់គឺអាចធ្វើឱ្យតុលាការយល់ឃើញអំពីភាពជាក់ច្បាស់នៃអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ ប៉ុន្តែករណីដែលសេចក្តីបញ្ជាក់ដំបូងវិញ ប្រសិនបើអាចធ្វើឱ្យតុលាការយល់ឃើញថា វាមានភាពហាក់ដូចជាការពិតនៃអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុគឺជាការគ្រប់គ្រាន់។

[7] មាត្រា ៥៤១.៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឃ. លក្ខណៈសម្ងាត់**

ក្នុងករណីដែលម្ចាស់បំណុលដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នលើអចលនវត្ថុណាមួយនោះ ចំពោះនីតិវិធីនៃការរឹបអូសនេះ ត្រូវតែធ្វើឡើងជាការសម្ងាត់ជូនម្ចាស់បំណុល ដើម្បីបង្ការក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល និងដើម្បីការពារកុំឱ្យកូនបំណុលបានដឹងហើយប្រព្រឹត្តអំពើការពារខ្លួន។ ម្យ៉ាងវិញទៀត ចំពោះការសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនេះ។ ដូច្នេះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុណាមួយ តុលាការត្រូវមានការពិនិត្យ និងថ្លឹងថ្លែងឱ្យបានច្បាស់លាស់នូវលក្ខណៈបន្ទាន់បង្ខំនៃនីតិវិធី និងភាពសុចរិតរបស់ម្ចាស់បំណុល និងកូនបំណុល យោយផ្អែកទៅលើឯកសារ ឬភស្តុតាងជាចាំបាច់ដើម្បីកុំឱ្យមានការខាតបង់ប្រយោជន៍ភាគីណាមួយ។

**៤. លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន**

មុនចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការនឹងពិនិត្យមើលលក្ខខណ្ឌចំនួនពីរ រួមមាន **លក្ខខណ្ឌសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ** (ក) និង **លក្ខខណ្ឌនៃភាពចាំបាច់នៃការរក្សាការពារ** (ខ)។

**ក. លក្ខខណ្ឌសិទ្ធិ ឬទំនាក់ទនងគតិយុត្តដែលត្រូវរក្សាការពារ**

សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារត្រង់ចំណុចនេះត្រូវសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារនិងអង្គហេតុសំខាន់ៗផ្សេងទៀតបើមាន ព្រោះការសរសេរពីអង្គហេតុនេះដើម្បីបង្ហាញពីការកកើតនៃសិទ្ធិ។ សិទ្ធិដែលទាមទារនោះ ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ "សិទ្ធិលើបំណុលសងជាប្រាក់"។[8] ប្រសិនបើសិទ្ធិលើបំណុលជាប្រាក់ ទោះបីជាសិទ្ធិលើបំណុលនេះភ្ជាប់នឹងលក្ខខណ្ឌ ឬពេលកំណត់ ក៏បានដែរ។[9] សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលបានរក្សាការពារត្រូវតែកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារ និងចំនួនទឹកប្រាក់ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកចេញពីសិទ្ធិលើបំណុលផ្សេងទៀត។ ការកំណត់សិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ ត្រូវសរសេរតាមច្បាប់សារធាតុនៃសិទ្ធិលើបំណុលនោះ (ប្រាក់កម្ចី ប្រាក់ថ្លៃលក់ទិញ កម្រៃលទ្ធផលនៃការងារជាអាទិ៍) និងធាតុផ្សំសំខាន់នៃសិទ្ធិលើបំណុល (ពេលវេលានៃការកើតឡើងនៃសិទ្ធិលើបំណុល មូលហេតុនៃការកកើតពេលកំណត់សង ខ្លឹមសារនៃលក្ខខណ្ឌជាដើម)។ យ៉ាងណាមិញ ក្នុងករណីម្ចាស់បំណុលបារម្ភ ឬអាចមើលឃើញអំពីអង្គហេតុតវ៉ាដែល

[8] មាត្រា ៥៣១. ក និងមាត្រា ៥៤៥.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ៥៣១.ក និងមាត្រា ៥៤៥.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

អាចអះអាងដោយកូនបំណុលជាការប្រសើរណាស់ ដែលម្ចាស់បំណុលត្រូវការបដិសេធអំពីអង្គហេតុទាំងនោះ ពីព្រោះវាមានប្រយោជន៍សម្រាប់តុលាការក្នុងការចេញដីកាសម្រេច និងសម្រេចអំពីចំនួនប្រាតិភោគ។[10]

**ឧទាហរណ៍** (១) ៖ កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០១០ លោក **ក** (កូនបំណុល) បានខ្ចីប្រាក់ ពីលោក **ខ** (ម្ចាស់បំណុល) ចំនួន ៨០០០ដុល្លារ។ នៅថ្ងៃដដែលនោះ លោក **ក** ក៏បានទទួលបានប្រាក់ចំនួន ៨០០០ដុល្លារ នោះពីលោក **ខ** ។ ភាគីទាំងពីរនាក់បានព្រមព្រៀងគ្នាអំពីរយៈពេលខ្ចី ចំនួន២៤ខែ (គិតចាប់ពីថ្ងៃទទួលបានប្រាក់) ឯការប្រាក់ក្នុងរយៈពេលខ្ចី ១០% ក្នុង ១ឆ្នាំ ។ កូនបំណុលត្រូវសង ៨០០០ដុល្លារ និងការប្រាក់ទៅឱ្យម្ចាស់បំណុល២៤ខែក្រោយ គឺនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១២។ ក្នុងករណីដែលកូនបំណុលមិនអាចសងប្រាក់ទាំងអស់តាមកាលកំណត់ខាងលើនេះទេ កូនបំណុលត្រូវបង់ការប្រាក់យឺតយ៉ាវ ២០% ក្នុង១ឆ្នាំ ដែលស្មើនឹងទ្វេដងនៃការប្រាក់ហើយត្រូវគណនាដោយផ្អែកលើការប្រាក់ដែលសងយឺតយ៉ាវ និងរយៈពេលការសងយឺតយ៉ាវ។

**ខ. ភាពចាំបាច់នៃការរក្សាការពារ**

ភាពចាំបាច់នៃការរក្សាការពារនៅក្នុងការរឹបអូសជាបណ្ដោះអាសន្ននឹងទទួលស្គាល់នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នៅពេលដែលមានការបារម្ភថានឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។[11] ភាពចាំបាច់នៃការរក្សាការពារនឹងទទួលស្គាល់នៅក្នុងករណីដែលមានការបារម្ភអំពីការកើតឡើងនូវឧបសគ្គតាមអង្គហេតុដូចជា នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជាធ្លាក់តម្លៃជាបរិមាណ ឬជាគុណភាព ឬដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ឬនៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្ដូរលំនៅឋានជាច្រើនលើកច្រើនសារ ដែលធ្វើឱ្យមានការពិបាកដើម្បីដឹងអំពីទ្រព្យសម្បត្តិរបស់កូនបំណុលជាអាទិ៍។ ចំពោះភាពចាំបាច់នៅក្នុងការអនុវត្តដោយសារតែការធ្លាក់ចុះទ្រព្យសម្បត្តិរបស់កូនបំណុល នឹងមានវិនិច្ឆ័យជាសត្យានុម័ត ដោយពិចារណា មុខរបរ ឋានៈ និងស្ថានភាពទ្រព្យសម្បត្តិ (រួមទាំងតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ) របស់កូនបំណុល។ ចំពោះភាពចាំបាច់នៃការរក្សាការពារចាំបាច់ត្រូវសរសេរអង្គហេតុបង្ហាញស្ថានភាពទាំងនោះឱ្យបានលម្អិត។

**ឧទាហរណ៍** (២)៖ លោក **ក** មិនបានសងទៅឱ្យលោក **ខ** ទេ ទោះបីជាកាលបរិច្ឆេទនៃថ្ងៃកំណត់ដែលត្រូវសងបានកន្លងហួសហើយក៏ដោយ។ ប្រមាណជានៅ ខែកុម្ភៈ នៅឆ្នាំ២០១២ លោក **ខ** បានដាស់តឿនជាញឹកញាប់ឱ្យលោក **ក** សងប្រាក់ ប៉ុន្តែ លោក **ក** មិនបានសងប្រាក់ឡើយ ដោយលើកហេតុផលថា គាត់បានសង ៨០០០ដុល្លារ មុនកាលកំណត់សង ចំណែកឯប្រាក់ដែលនៅសល់ត្រូវបានគេលើកលែង។ លោក **ក** បានខ្ចីប្រាក់ពីសាច់ញាតិ ហើយគាត់បានយកប្រាក់ទាំងនោះទៅចំណាយលើថ្លៃព្យាបាលឪពុករបស់គាត់ និង

[10] មាត្រា ៥៣១.ក និងមាត្រា ៥៤២.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា ៥៣១.ក និងមាត្រា ៥៤១.ឃ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្ថិតនៅក្រោមសំពាធត្រូវសងប្រាក់កម្ចីទៀត។ ក្រៅពីនេះ ការរកស៊ីរបស់លោក **ក** មើលទៅដំណើរក៏មិនសូវល្អដែរ។ លោក **ក** មានអាគារ និងដីមួយកន្លែង ក្រៅពីនេះមិនឃើញមានទ្រព្យសម្បត្តិផ្សេងពីនេះទេ។ ក្នុងករណីនេះ លោក **ក** អាចនឹងលក់ដីដើម្បីចាយវាយ។

## ផ្នែកទី២ ការដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ម្ចាស់បំណុល ជាអ្នកដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្នដើម្បីឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ក្នុងគោលបំណងការពារសិទ្ធិលើបំណុលរបស់ខ្លួន។ ដោយឡែកដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះ ម្ចាស់បំណុលត្រូវដឹងពី៖ **របៀបដាក់ពាក្យសុំ (១) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ (២) និងឯកសារភ្ជាប់ជាមួយពាក្យសុំ (៣)។**

### ១. របៀបដាក់ពាក្យសុំ

ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវធ្វើជាលាយលក្ខណ៍អក្សរមិនអាចធ្វើដោយផ្ទាល់មាត់បានទេ។[12]

### ២ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចធ្វើទៅបានលុះត្រាតែមានពាក្យសុំរបស់ភាគីណាមួយបានដាក់មកតុលាការមានសមត្ថកិច្ច។[13] នៅក្នុងពាក្យសុំឱ្យចេញដីការឹបអូសជាបណ្ដោះអាសន្នត្រូវសរសេរឱ្យច្បាស់លាស់លើចំណុចមួយចំនួនដូចជា៖ **ឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (២.១) ខ្លឹមសារនៃដីការសម្រេចរឹបអូសជាបណ្ដោះអាសន្នរបស់អ្នកដាក់ពាក្យសុំទាមទារ (២.២) សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន (២.៣) ភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ន (២.៤) និងភស្តុតាង (២.៥)។**

#### ២.១ ឈ្មោះឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

នៅក្នុងពាក្យសុំដីការឹបអូសជាបណ្ដោះអាសន្នត្រូវបញ្ជាក់ឱ្យបានច្បាស់ថាអ្នកណាជាម្ចាស់បំណុល និងកូនបំណុលដោយមានសរសេរបញ្ជាក់ពីអាសយដ្ឋានមកជាមួយផង។ ក្នុងករណីមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬមានអ្នកតំណាងដោយអាណត្តិ ត្រូវសរសេរឱ្យបានច្បាស់លាស់។[14]

[12] មាត្រា ៥៣៤.ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
[13] មាត្រា ៥៣៤.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
[14] មាត្រា ៥៤១.១.ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.២ ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ប្រភេទសេចក្តីសម្រេចនៅក្នុងរក្សាការពារមានបីប្រភេទ[15] ដែលមាននីតិវិធីខុសៗគ្នា។ ដូច្នេះហើយ ខ្លឹមសារនៃដីកាសម្រេចសុំទាមទារមានសារៈសំខាន់ ពោលគឺត្រូវមានអត្ថន័យឱ្យបានច្បាស់លាស់ដើម្បីបញ្ជាក់ពីប្រភេទនៃដីកាសម្រេចរក្សាការពារនីមួយៗកុំឱ្យមានការភាន់ច្រឡំ។ ជាក់ស្តែងខ្លឹមសារនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅក្នុងពាក្យសុំរបស់ម្ចាស់បំណុល គឺជាកម្មវត្ថុនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ខ្លឹមសារនោះត្រូវតែបញ្ជាក់ថា តើភាគីអ្នកដាក់ពាក្យសុំទាមទាររឹបអូសអចលនវត្ថុមួយណា?

### ២.៣ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារនៅក្នុងការរឹបអូសជាបណ្តោះអាសន្នត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ទោះបីជាសិទ្ធិលើបំណុលនោះភ្ជាប់ជាមួយលក្ខខណ្ឌ ឬពេលកំណត់ក៏ដោយ។[16] ម្ចាស់បំណុលត្រូវតែសរសេរឱ្យបានច្បាស់ពីខ្លឹមសារនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ និងករណីកិច្ចរវាងខ្លួន និងកូនបំណុល ព្រមទាំង ចំនួនទឹកប្រាក់ដែលជាសិទ្ធិលើបំណុល។ ម្យ៉ាងទៀត ការកំណត់សិទ្ធិលើបំណុលដែលត្រូវរក្សាការពារ (ប្រាក់កម្ចី ប្រាក់ថ្លៃទំនិញ ជាអាទិ៍) និងធាតុផ្សំសំខាន់ៗនៃសិទ្ធិលើបំណុលផ្សេងៗត្រូវសរសេរតាមច្បាប់សារធាតុ។

### ២.៤ ភាពចាំបាច់នៃការរក្សាការពារ

ម្ចាស់បំណុលត្រូវសរសេរអង្គហេតុយ៉ាងណាបង្ហាញពីស្ថានភាពឱ្យបានច្បាស់ពីភាពចាំបាច់ ដើម្បីឱ្យចៅក្រមចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ភាពចាំបាច់នេះ គឺក្នុងករណីដែលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងនៅក្នុងការអនុវត្តដោយបង្ខំ ដូចជានៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជាធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ឬនៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្តូរលំនៅឋានជាច្រើនលើកច្រើនសារ ដែលធ្វើឱ្យមានការពិបាកដើម្បីដឹងអំពីទ្រព្យសម្បត្តិរបស់កូនបំណុល។[17]

### ២.៥ ភស្តុតាង

ពេលដែលម្ចាស់បំណុលសរសេរអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃការរក្សាការពារនៅក្នុងពាក្យសុំ ម្ចាស់បំណុលគប្បីសរសេរឱ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាង (ឯកសារអំពីសេចក្តីបញ្ជាក់ដំបូង) ដែលបញ្ជាក់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ

[15] មាត្រា ៥៣៨.ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០

[16] មាត្រា ៥៣១.ក និងមាត្រា ៥៤៥. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា ៥៤៥.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

និងភាពចាំបាច់នៃការរក្សាការពារ ពីព្រោះការយោងនេះមានប្រយោជន៍សម្រាប់តុលាការក្នុងការស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង។[18]

## ៣. ឯកសារភ្ជាប់ជាមួយពាក្យសុំ

### ៣.១. សេចក្តីបញ្ជាក់ដំបូង

សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន មានន័យថាឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង គឺជាឯកសារជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបាននៅពេលធ្វើសេចក្តីបញ្ជាក់ដំបូង។ នៅពេលម្ចាស់បំណុលដាក់ពាក្យសុំឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ដែលភ្ជាប់ជាមួយពាក្យសុំនោះមានពីរគឺ **ឯកសារដែលបញ្ជាក់ដំបូងពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ (ក) និង ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន (ខ)។**

#### ក. ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិដែលត្រូវរក្សាការពារ

ម្ចាស់បំណុលដែលដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែធ្វើសេចក្តីបញ្ជាក់ដំបូងចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត។ ដើម្បីធ្វើសេចក្តីបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ អ្នកដាក់ពាក្យសុំ (ម្ចាស់បំណុល) ត្រូវធ្វើការបញ្ជាក់ពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ពីការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ភស្តុតាងដែលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងនេះទៀតសោតត្រូវតែធ្វើឡើងជាឯកសារ។ ជាក់ស្តែងឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ គឺតាមប្រភេទនៃរឿងក្តីដូចជា រឿងក្តីទាក់ទងនឹងការទាមទារឱ្យធ្វើការប្រគល់អចលនវត្ថុ នោះសេចក្តីបញ្ជាក់ដំបូងដែលជាភស្តុតាងជាឯកសារគឺ ប័ណ្ណសម្គាល់កម្មសិទ្ធិ ហើយរឿងក្តីទាក់ទងនឹងកិច្ចសន្យាខ្ចីបរិភោគ សេចក្តីបញ្ជាក់ដំបូងដែលជាភស្តុតាងជាឯកសារ គឺជាលិខិតកិច្ចសន្យាខ្ចីបរិភោគ។

ការដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនេះមានសារៈសំខាន់សម្រាប់ឱ្យចៅក្រមធ្វើការពិនិត្យបានភ្លាមៗ និងកំណត់ថា តើម្ចាស់បំណុលមានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ឬអត់។ ផ្ទុយមកវិញបើម្ចាស់បំណុលខកខានមិនបានដាក់ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារទេ គឺចៅក្រមមិនអាចដឹង ឬមិនអាចកំណត់សិទ្ធិរបស់ម្ចាស់បំណុលបានឡើយ។ ការខ្វះឯកសារនេះ គឺខុសពីលក្ខខណ្ឌចាំបាច់ក្នុងការដាក់ពាក្យសុំ ជាហេតុនាំឱ្យចៅក្រមលើកពាក្យសុំចោលដោយដីកាសម្រេច។[19]

---

[18] មាត្រា ៥៤១.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា ៥៤១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

**ខ. ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន**

ចៅក្រមមិនត្រឹមតែពិនិត្យលើសេចក្តីបញ្ជាក់ដំបូងដើម្បីបញ្ជាក់ពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមក៏ត្រូវតែពិនិត្យផងដែរលើភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន ទើបចៅក្រមអាចចេញសេចក្តីសម្រេច។ ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ននេះជាធាតុផ្សំមួយដែលមិនអាចខ្វះបានដើម្បីឱ្យចៅក្រមពិចារណាថា គួរចេញសេចក្តីសម្រេចតាមពាក្យសុំ ឬអត់ព្រោះមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល។ ភាពចាំបាច់នេះគឺក្នុងករណីមានការបារម្ភថា ការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើទៅបាន ឬមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។[20]

**៣.២. លិខិតតំណាង**

នៅក្នុងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានសិទ្ធិជ្រើសតាំងអ្នកតំណាងដោយអាណត្តិដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបានដោយសកម្មភាពបណ្តឹងជំនួសខ្លួន។ បើមានអ្នកតំណាងដោយអាណត្តិ អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវដាក់ឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះភ្ជាប់ជាមួយពាក្យសុំ។[21] បើគ្មានលិខិតបញ្ជាក់ពីសិទ្ធិតំណាងដោយអាណត្តិទេ តុលាការមិនអាចលើកចោលពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបានទេ គឺគ្រាន់តែឱ្យភាគីកែតម្រូវដោយធ្វើការណែនាំឱ្យដាក់លិខិតនោះប៉ុណ្ណោះ។ ផ្ទុយមកវិញ ភាគីត្រូវមកធ្វើសកម្មភាពក្នុងនីតិវិធីរឹបអូសជាបណ្តោះអាសន្នដោយខ្លួនឯង ប្រសិនបើមិនដាក់លិខិតបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ។ ជាគោលការណ៍អ្នកតំណាងដោយអាណត្តិគឺជាមេធាវី លើកលែងតែមានលក្ខខណ្ឌមួយចំនួនដូចមានចែងនៅក្នុងមាត្រា៥៣ តែប៉ុណ្ណោះ។ ឯកសារបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះ មានសារៈសំខាន់ណាស់សម្រាប់ចៅក្រម ដើម្បីកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិដើម្បីធានាស្ថេរភាពនៃនីតិវិធីរឹបអូសជាបណ្តោះអាសន្ន ប៉ុន្តែបើគ្មានលិខិតបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិទេ នោះតុលាការមិនអាចកំណត់អំពីទំហំនៃសិទ្ធិដែលអ្នកតំណាងដោយអាណត្តិមានទេ។

ដូចច្នេះហើយ លិខិតបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ គឺមានផលប្រយោជន៍សម្រាប់តុលាការក្នុងការចាត់ការនីតិវិធីរឹបអូសជាបណ្តោះអាសន្នប្រកបដោយយុត្តិធម៌ និងសម្រាប់ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីនៃនីតិវិធីរឹបអូសជាបណ្តោះអាសន្នផងដែរ។

[20] មាត្រា ៥៤៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[21] មាត្រា ៥៣.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.៣. ឯកសារដើម្បីបញ្ជាក់កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន

ជាទូទៅ នៅក្នុងករណីកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នជាអចលនវត្ថុតុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយកំណត់ជាក់លាក់នូវកម្មវត្ថុនេះ ប៉ុន្តែសម្រាប់ចលនវត្ថុវិញតុលាការអាចចេញដីកាសម្រេចបានដោយមិនចាំបាច់កំណត់ពីកម្មវត្ថុទេ។[22] ការបញ្ជាក់អំពីកម្មវត្ថុបែបនេះ គឺងាយស្រួលសម្រាប់តុលាការក្នុងការយកជាមូលដ្ឋានក្នុងការចេញដីកាសម្រេចត្រង់ថា តុលាការអាចកំណត់កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នដាក់នៅក្នុងដីកាសម្រេច។ ឯកសារដើម្បីបញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសបណ្ដោះអាសន្ននេះគឺ អ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់យ៉ាងណាដើម្បីឱ្យតុលាការជឿថាកម្មវត្ថុដែលសុំឱ្យតុលាការធ្វើការរឹបអូសជាបណ្ដោះអាសន្ននោះ ពិតជាកម្មសិទ្ធិរបស់របស់កូនបំណុល ទៅលើទ្រព្យសម្បត្តិនោះ។ ជាធម្មតា ឯកសារដែលជាលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុល ចំពោះទ្រព្យសម្បត្តិដូចជា បញ្ជាក់ថា ដី ឬផ្ទះទំហំប៉ុន្មានដែលជាកម្មសិទ្ធិរបស់កូនបំណុលជាដើម។ ការបញ្ជាក់អំពីកម្មសិទ្ធិលើអចលនវត្ថុជាភារកិច្ចរបស់មន្ត្រីសុរិយោដី។ ក្នុងការអនុវត្តជាក់ស្តែងករណីមិនអាចទទួលបានការបញ្ជាក់ពីមន្ត្រីសុរិយោដីទេ ម្ចាស់បំណុលអាចរកឯកសារតាមមធ្យោបាយផ្សេងៗ ដែលឯកសារនោះតុលាការអាចទទួលយកបានមានដូចជា មានការបញ្ជាក់ពីមេភូមិ ឬចៅសង្កាត់ជាអាទិ៍។

## ផ្នែកទី៣ សមត្ថកិច្ចសាលាជម្រះក្ដី

បញ្ញត្តិដែលទាក់ទងនឹងតុលាការមានសមត្ថកិច្ច ការដាក់ពាក្យសុំ វិធីនៃការវិនិច្ឆ័យ និងការចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ក៏ដូចជាទៅនឹងបញ្ញត្តិស្ដីពីការចាត់ចែងជាបណ្ដោះអាសន្នដែរ លើកលែងមានបញ្ញត្តិពិសេស។[23]

### ១. តុលាការមានសមត្ថកិច្ច

រឿងក្ដីរឹបអូសជាបណ្ដោះអាសន្ន ត្រូវស្ថិតនៅក្រោម**សមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី** ( ក ) និង នៅ**សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ** ( ខ )។[24]

#### ក. តុលាការមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី

តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ជាតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី មានន័យថាជាតុលាការនៃការជំនុំជម្រះលើកទី១ ពោលគឺសាលាដំបូងរាជធានីខេត្ត

[22] មាត្រា ៥៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០

[23] ជំពូកទី៤ ផ្នែកទី២ កថាខណ្ឌទី២ សេចក្ដីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី

[24] មាត្រា ៥៤០.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

ដែលមានសមត្ថកិច្ចលើអង្គសេចក្ដីដែលកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណី។ ដោយឡែក បើរឿងអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដីគឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ដែលមានសមត្ថកិច្ចទទួលពាក្យសុំ និងចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តាមពាក្យសុំរបស់ម្ចាស់បំណុល។[25] ក្នុងករណីដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្ដឹងសាទុក្ខ នោះត្រូវត្រឡប់ទៅរកគោលការណ៍ដើមវិញពោលគឺតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដីគឺតុលាការនៃការជំនុំជម្រះលើកទី១។ ជាងនេះទៅទៀត សមត្ថកិច្ចទាំងនេះគឺជាសមត្ថកិច្ចផ្ដាច់មុខ។[26]

### ខ. សាលាដំបូងមានសមត្ថកិច្ចលើវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន

នៅពេលដែលអង្គសេចក្ដីកំពុងត្រូវបានចាត់ការ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះលើកទី១។ លើសពីនេះទៅទៀត តុលាការដែលមានសមត្ថកិច្ចក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺជាតុលាការដែលវត្ថុត្រូវរឹបអូសជាបណ្ដោះអាសន្នស្ថិតនៅ។[27]

## ២. ករណីមិនចូលសមត្ថកិច្ច

រាល់ការដាក់ពាក្យសុំ ឬបណ្ដឹងជូនមកតុលាការ ហើយតុលាការត្រូវតែពិនិត្យមើលទម្រង់លិខិតទាំងនោះ ទៅលើចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំដោយផ្អែកតាមមាត្រា៥៤១ ហើយមានខុស ឬខ្វះត្រង់ចំណុចណាមួយដែលត្រូវឱ្យកែតម្រូវ។ ប្រសិនបើតុលាការយល់ឃើញថាពាក្យសុំ ឬបណ្ដឹងទាំងមូល ឬផ្នែកណាមួយ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្ដឹងនោះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំរបស់ភាគី ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[28] យ៉ាងណាមិញ ទោះបីជាផ្នែកណាមួយនៃពាក្យសុំ ឬបណ្ដឹងមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ តុលាការអាចទទួលបណ្ដឹងនោះមកដោះស្រាយបាន ដោយតាមបញ្ញត្តិនៃមាត្រា ១១ (សមត្ថកិច្ចសាលាជម្រះក្ដីចំពោះការទាមទារច្រើនចំណុចដោយបញ្ចូលជាមួយគ្នា)។ ប៉ុន្តែប្រសិនបើផ្នែកណាមួយនៃបណ្ដឹងនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការណាមួយផ្សេងទៀត នោះតុលាការដែលទទួលពាក្យបណ្ដឹង ត្រូវផ្ទេរផ្នែកនោះទៅតុលាការដែលមានសមត្ថកិច្ច។ ដោយហេតុថា បណ្ដឹងដែលខុសសមត្ថកិច្ច ឬមិនចូលសមត្ថកិច្ច។[29]

[25] មាត្រា ៥៤០.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] មាត្រា ៥៣៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា ៥៤០.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មាត្រា ១៨.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមើលឧបសម្ព័ន្ធ៣

[29] មាត្រា ១៨.៣ សេចក្ដីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

## ផ្នែកទី៤ ការពិនិត្យរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

មុននឹងចៅក្រមចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែពិនិត្យទៅលើពាក្យសុំរឹបអូសជាបណ្តោះអាសន្នជាមុនសិន ថាតើបានបំពេញនៅគ្រប់លក្ខខណ្ឌដែលជាលក្ខខណ្ឌទម្រង់ និងសោហ៊ុយនៃការចេញដីការឹបអូសជាបណ្តោះអាសន្ន និងបានដាក់ប្រាតិភោគហើយឬនៅ?

### ១. ការពិនិត្យលក្ខខណ្ឌទម្រង់របស់ពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះ ត្រូវសរសេរបញ្ជាក់នូវចំណុចមួយចំនួនដូចជា៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

- ខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលអ្នកដាក់ពាក្យសុំទាមទារ

- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ

- ភាពចាំបាច់នៃការរក្សាការពារ

-ភស្តុតាង

-សេចក្តីបញ្ជាក់ដំបូង។[30]

### ២. សោហ៊ុយនៃការរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្នច្បាប់បានបញ្ញត្តិអំពីសោហ៊ុយនៃការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្ន ក្នុងនោះមានបីគឺ **ពន្ធដាក់ពាក្យសុំ** (២.១) **និង ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ** (២.២) **និង ប្រាក់ប្រដាប់ក្តីរបស់ភាគី** (២.៣)។

#### ២.១. ពន្ធដាក់ពាក្យសុំ

នៅក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្ន អ្នកដាក់ពាក្យសុំដែលជាម្ចាស់បំណុលត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល។[31] បើម្ចាស់បំណុលមិនបានបង់ទេ តុលាការត្រូវបង្គាប់ម្ចាស់បំណុលបង់ពន្ធដាក់ពាក្យសុំក្នុងអំឡុងពេលសមរម្យ។[32] ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធដាក់ពាក្យសុំទៅតាមអំឡុងពេលដែលតុលាការបានកំណត់ទេ នោះពាក្យសុំចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលើកចោលដោយដីកាសម្រេច ប៉ុន្តែអាចធ្វើការប្តឹងជំទាស់បាន។[33]

---

[30] មាត្រា ៥៤១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[31] មាត្រា ៥៣៧.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[32] មាត្រា ៥៣៩ និងមាត្រា ៧៨.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា ៧៨.២ និង៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.២. ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

បន្ថែមពីពន្ធដាក់ពាក្យសុំ ម្ចាស់បំណុលដែលជាអ្នកដាក់ពាក្យសុំត្រូវបង់ពន្ធប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធដែលជាចំនួនប្រាក់ចាំបាច់សម្រាប់ពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅតុលាការ។[34] ជាឧទាហរណ៍៖ សោហ៊ុយសម្រាប់ធ្វើដំណើរនៅក្នុងករណីតុលាការបញ្ជូនដីកាសម្រេចទៅភាគីជាអាទិ៍។[35]

### ២.៣. ប្រាក់ប្រដាប់ក្ដីភាគី

ប្រាក់ប្រដាប់ក្ដីភាគី គឺជាប្រាក់ថ្លៃធ្វើលិខិតដាក់ឯកសារដូចជា លិខិតពាក្យបណ្ដឹង លិខិតពាក្យសុំ ឯកសារត្រៀមផ្សេងៗជាអាទិ៍ និងថ្លៃដាក់ឯកសារទៅតុលាការ។ បន្ថែមពីនេះទៅទៀតប្រាក់ប្រដាប់ក្ដីភាគីនេះក៏ជាសោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ ប្រាក់ឧបត្ថម្ភរបស់ភាគី ឬអ្នកតំណាងដើម្បីបង្ហាញខ្លួននៅកាលបរិច្ឆេទដែលបានកំណត់។[36]

## ៣. ប្រាតិភោគ

### ៣.១.គោលបំណងនៃការដាក់ប្រាតិភោគ

លក្ខណៈពិសេសនៃនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបាន ដោយពុំចាំបាច់សួរកូនបំណុល ដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្តីបញ្ជាក់ដំបូងជាការស្រេច។ ប៉ុន្តែដីកាសម្រេចរក្សាការពារក្នុងករណីខ្លះត្រូវប្រឈមមុខការលុបចោលទៅវិញ ត្រង់ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលប្រយោជន៍របស់កូនបំណុល គឺបណ្ដាលឱ្យកូនបំណុលខូចខាតច្រើន។ ដូច្នេះដើម្បីឆ្លើយតបនឹងការខូចខាតរបស់កូនបំណុលដែលកើតឡើងជាយថាហេតុទើបតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ ការដាក់ប្រាតិភោគរបស់ម្ចាស់បំណុលគឺក្នុងគោលបំណងទប់ស្កាត់ការប្រើប្រាស់សិទ្ធិហួសប្រមាណ។ គោលបំណងនៃប្រាតិភោគគឺដើម្បីធានាសងការខូចខាត និងជម្ងឺចិត្តក្នុងករណីប៉ះពាល់ផលប្រយោជន៍កូនបំណុល។ ជាងនេះទៅទៀត កូនបំណុលនឹងមានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត។[37]

---

[34] មាត្រា ៦២.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] មាត្រា ៦៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[37] មាត្រា ៥៣៩ និងមាត្រា ៧២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.២.ចំនួននៃប្រាតិភោគ

មុនពេលតុលាការធ្វើការសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំរបស់ម្ចាស់បំណុល តុលាការត្រូវពិចារណាទៅលើហានិភ័យដែលនឹងអាចកើតមានជាយថាហេតុ ដោយសារការចេញដីកាសម្រេចរបស់ខ្លួនហើយនាំឱ្យខូចប្រយោជន៍របស់កូនបំណុល។ តុលាការធ្វើការបង្គាប់ឱ្យម្ចាស់បំណុលបង់ប្រាក់ប្រាតិភោគ ដោយពិចារណាទៅលើ ទី១ ការវាយតម្លៃទៅលើការខូចខាតរបស់កូនបំណុលដែលអាចកើតមាននាពេលអនាគត។ ទី២ សេចក្តីបញ្ជាក់ដំបូង "បើសេចក្តីបញ្ជាក់ដំបូងមានភាពរឹងមាំ នោះចំនួននៃប្រាក់ប្រាតិភោគគឺ ទាប ឬតិចតួច" ប៉ុន្តែ "បើសេចក្តីបញ្ជាក់ដំបូងមានលក្ខណៈរឹងមាំទេ នោះតម្រូវការនៃការដាក់ប្រាតិភោគត្រូវមានកម្រិតខ្ពស់ ឬច្រើន" ។ ទី៣ តុលាការនឹងពិចារណាទៅលើប្រភេទនៃកម្មវត្ថុនៃការចេញដីកាសម្រេចរក្សាការពារ ថាតើជាអចលនវត្ថុ ឬជាចលនវត្ថុ ឬជាសិទ្ធិលើបំណុល។ ផ្អែកទៅលើចំណុចទាំងបីនេះ ទើបតុលាការងាយស្រួលក្នុងការកំណត់ប្រាក់សម្រាប់ដាក់ប្រាតិភោគដែលតម្រូវឱ្យម្ចាស់បំណុលដាក់។

### ៣.៣.វិធីនៃការដាក់ប្រាតិភោគ

តុលាការអាចចេញបង្គាប់ឱ្យដាក់ប្រាតិភោគមុន ឬក្រោយចេញដីកាសម្រេច។ បើការដាក់ប្រាតិភោគមុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការដាក់ប្រាតិភោគនេះសម្រាប់ជាលក្ខខណ្ឌមួយដើម្បីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ តុលាការមិនចេញដីកាសម្រេចទេ បើម្ចាស់បំណុលមិនធ្វើការដាក់ប្រាតិភោគមុនចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

ប៉ុន្តែក្នុងករណីដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែលមានភ្ជាប់មកជាមួយការបង្គាប់ឱ្យដាក់ប្រាតិភោគ ហើយការដាក់ប្រាតិភោគនេះគឺជាលក្ខខណ្ឌដើម្បីអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ហេតុនេះ ដើម្បីអាចអនុវត្តដីការឹបអូសជាបណ្តោះអាសន្នបាន លុះត្រាតែម្ចាស់បំណុលដាក់ប្រាតិភោគ។ ប្រាតិភោគត្រូវមានអានុភាពដោយការផ្ញើប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬតុលាការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[38]

[38] មាត្រា ៥៣៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២
# ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះ
# អចលនវត្ថុ

# ជំពូកទី២

# ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមិនបានចែងឱ្យបានច្បាស់លាស់ថា ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុត្រូវតែធ្វើជាលាយលក្ខណ៍អក្សរនោះទេ។ យ៉ាងណាមិញ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះត្រូវតែសរសេរជាលាយលក្ខណ៍អក្សរដោយផ្អែកលើមូលដ្ឋានគ្រឹះដូចមានចែងក្នុងមាត្រា៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីដូចតទៅ "តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី"។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុគឺជាប្រភេទមួយនៃដីកាសម្រេចរក្សាការពារ។ តាមខ្លឹមសារខាងលើមានន័យថាដីកាសម្រេចរក្សាការពារត្រូវចាំបាច់សរសេរជាលាយលក្ខណ៍អក្សរព្រោះដីកានេះត្រូវបញ្ជូនទៅភាគីដើម្បីឱ្យភាគីបានយល់ដឹងច្បាស់លាស់អំពីអត្ថន័យក្នុងដីកាសម្រេចរក្សាការពារនោះ ហើយដើម្បីបន្សល់ឱ្យភាគីនូវមធ្យោបាយបញ្ជាក់នោះទៀតផង។[39] ហេតុនេះ ដីកាសម្រេចរក្សាការពារត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។

## ផ្នែកទី១ ចំណុចដែលត្រូវសរសេរក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅពេលដែលតុលាការបានពិនិត្យមើលឯកសារទាំងអស់រួចមកហើយ ប្រសិនបើតុលាការយល់ឃើញថាស្ថានភាពរបស់ម្ចាស់បំណុលបានបំពេញលក្ខខណ្ឌដែលអាចឱ្យតុលាការយកជាមូលដ្ឋានក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នហើយ នោះតុលាការនឹងចេញដីកាសម្រេច។ គ្មានមាត្រាច្បាប់ណាចែងពីទម្រង់នៃដីកាសម្រេចទេ ប៉ុន្តែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានចង្អុលបង្ហាញឱ្យយកបញ្ញត្តិស្ដីពីសាលក្រមមកអនុវត្តដូចគ្នា។[40] ដូច្នេះហើយការរឹបអូសជាបណ្ដោះអាសន្ននេះ តុលាការនឹងបញ្ជាក់ចំណុចមួយចំនួននៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដូចជា **ក្បាលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន(១) អត្តសញ្ញាណរបស់ភាគី (២) ខ្លឹមសារនៃការទាមទារ (៣) សំអាងហេតុ (៤)** និង**សេចក្ដីសម្រេចបញ្ចប់ (៥)**។[41]

### ១. ក្បាលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ក្បាលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះគឺជាចំណុចចាប់ផ្ដើមដំបូងនៃដីកាសម្រេច។ ជាទូទៅនៅក្នុងក្បាលនៃដីកាសម្រេចត្រូវសរសេរ ឈ្មោះប្រទេស បាវចនាជាតិ សញ្ញា និងឈ្មោះសាលាដំបូង លេខ

[39] មាត្រា ៥៤៣ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗក្រមនីតិវិធីរដ្ឋប្បវេណី

[40] មាត្រា ២១៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[41] មាត្រា ១៨៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

សំណុំរឿងរក្សាការពារ កាលបរិច្ឆេទ និងឈ្មោះចៅក្រម និងក្រឡាបញ្ជីទទួលបន្ទុករឿងក្តីនេះ ហើយមានចំណងជើងនៃដីកាថា ការរឹបអូសជាបណ្តោះអាសន្ន ឬការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។[42]

**២. អត្តសញ្ញាណរបស់ភាគី**

បន្ទាប់ពីមានក្បាលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នហើយ ត្រូវសរសេរបញ្ជាក់នូវអត្តសញ្ញាណរបស់ម្ចាស់បំណុល កូនបំណុល អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិបើមាន។ នៅក្នុងនោះដែរត្រូវបញ្ជាក់ពី ឈ្មោះ ភេទ អាយុ សញ្ជាតិ និងអាសយដ្ឋាន។

**៣. ខ្លឹមសារនៃការទាមទារ**

ត្រង់ចំណុចនេះតុលាការនឹងធ្វើការបញ្ជាក់អំពីខ្លឹមសារនៃការទាមទាររបស់ម្ចាស់បំណុល ហើយតុលាការតែងតែចម្លងយកសេចក្តីស្នើសុំទាំងមូលរបស់ម្ចាស់បំណុលដែលមានលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

**៤. សំអាងហេតុ**

សំអាងហេតុ គឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលតុលាការត្រូវយកមកពិចារណា។ សំអាងហេតុត្រូវសំអាងទាំងអង្គហេតុនិងអង្គច្បាប់។ គុណភាពនៃសំអាងហេតុគឺត្រូវមានភាពងាយយល់ ប្រើប្រាស់ពាក្យណាដែលងាយយល់ សមហេតុផល គ្រប់ជ្រុងជ្រោយ។

ដើម្បីជាមូលដ្ឋានក្នុងការសរសេរសំអាងហេតុ មានពីរចំណុចៈ

ក. ទទួលស្គាល់អង្គហេតុតាមរយៈភស្តុតាង

ខ. សម្រេចត្រូវ ឬខុស (ទទួលស្គាល់ ឬច្រានចោល)។

ចំណុចនេះតុលាការនឹងវិនិច្ឆ័យអង្គហេតុដែលម្ចាស់បំណុលបានលើកឡើង ហើយតុលាការនឹងបង្ហាញពីការយល់ឃើញពាក់ព័ន្ធនឹងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុលព្រមទាំងភាពចាំបាច់ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ក្នុងករណីយល់ឃើញថាចាំបាច់ក្នុងការលើកឡើងពីការបកស្រាយច្បាប់ តុលាការត្រូវបង្ហាញការយល់ឃើញដែលនាំឱ្យមានការបកស្រាយច្បាប់ និងមូលហេតុនោះ។ លើសពីនេះទៀត តុលាការក៏ត្រូវបង្ហាញអំពីការពិនិត្យភស្តុតាងផ្សេងៗដែលម្ចាស់បំណុលបានដាក់មកជាមួយសេចក្តីបញ្ជាក់ដំបូងដែរ។

**៥. សេចក្តីសម្រេចបញ្ចប់**

ដីកាសម្រេចចាត់ចែងរក្សាការពារត្រូវសរសេរបញ្ចូលនូវសេចក្តីសម្រេច ការសម្រេចបញ្ចប់នូវការវិនិច្ឆ័យលើពាក្យសុំដែលម្ចាស់បំណុលបានដាក់។ សេចក្តីសម្រេចបញ្ចប់ គឺជាលទ្ធផលនៃសំអាងហេតុ។ នៅក្នុងក្រម

[42] មើលឧបសម្ព័ន្ធ៤

នីតិវិធីរដ្ឋប្បវេណីមិនបានបញ្ជាក់ថាសេចក្តីសម្រេចបញ្ចប់ត្រូវសរសេរយ៉ាងដូចម្តេចទេ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង តុលាការតែងតែនិយមសរសេរថា "ហេតុដូច្នេះសម្រេច រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល"។

## ផ្នែកទី២ ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

នៅមាត្រា៥៤៧ បានចែងថា "ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន"។ កូនបំណុលត្រូវផ្ញើទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការអនុវត្តការរក្សាការពារ។ បានសេចក្តីថាខ្លឹមសារនៃសេចក្តីសម្រេចត្រូវតែកំណត់ពីចំនួនទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្នដោយខានពុំបាន ដើម្បីឱ្យកូនបំណុលរួចផុតពីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។ យ៉ាងណាមិញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នពុំមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ទេ បើក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ពុំមានបញ្ជាក់អំពីចំនួនទឹកប្រាក់រំដោះ។

### ១. គោលបំណងនៃប្រាក់រំដោះ

ការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយកូនបំណុលត្រូវផ្ញើទឹកប្រាក់នោះនូវចំនួនដែលស្មើនឹងសិទ្ធិលើបំណុលដែលទាមទារឱ្យសងជាប្រាក់ នោះម្ចាស់បំណុលនឹងមិនទទួលបានការខូតខាតឡើយ។[43] ម្យ៉ាងទៀតប្រសិនបើទ្រព្យណាមួយរបស់កូនបំណុលត្រូវបានរឹបអូសជាបណ្តោះអាសន្ន កូនបំណុលនឹងត្រូវបានខាតប្រយោជន៍ដោយសារតែការរឹបអូសជាបណ្តោះអាសន្ននោះ។ ក្នុងករណីនេះ មធ្យោបាយដែលអាចដោះស្រាយបាននឹងមានអានុភាព គឺការផ្ញើប្រាក់ដែលមានចំនួនស្មើនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលបានទាមទារក្នុងបំណងឱ្យសងជាប្រាក់ ហើយកូនបំណុលក៏ត្រូវបានរួចផុតពីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។ មានន័យថានៅពេលដែលកូនបំណុលបានផ្ញើប្រាក់ចំនួនស្មើនឹងចំនួននៃសិទ្ធិលើបំណុលដែលត្រូវរក្សាការពាររួចរាល់ហើយ ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ននោះមិនមានអាទិភាពទៀតទេ។

### ២. ចំនួននៃប្រាក់រំដោះ

ការសម្រេចអំពីចំនួននៃប្រាក់រំដោះ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមដោយពុំមានមាត្រាមួយណាបានកំណត់យ៉ាងច្បាស់លាស់អំពីប្រាក់រំដោះនោះទេ គឺវាអាស្រ័យលើទំហំ ឬសិទ្ធិលើបំណុលដែលបានទាមទារ និងតម្លៃនៃទ្រព្យដែលត្រូវរឹបអូសជាបណ្តោះអាសន្ននោះ។ ការអនុវត្តជាក់ស្តែង តុលាការត្រូវពិចារណាទៅលើតម្លៃទ្រព្យសម្បត្តិដែលត្រូវរឹបអូស ប្រសិនបើទ្រព្យមានតម្លៃច្រើនជាងសិទ្ធិលើបំណុលដែលមានគោលបំណង

[43] មាត្រា៥៤៧ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

សងជាប្រាក់ នោះប្រាក់រំដោះដែលកូនបំណុលត្រូវផ្ញើ គឺស្មើនឹងប្រាក់បំណុល។ ផ្ទុយមកវិញ ប្រសិនបើតុលាការវាយតម្លៃទៅឃើញថា តម្លៃទ្រព្យដែលត្រូវរឹបអូសតិចជាងប្រាក់បំណុល នោះប្រាក់រំដោះត្រូវស្មើនឹងតម្លៃអចលនវត្ថុដែលត្រូវរឹបអូសនោះ។

**៣. វិធីនៃការដាក់ប្រាក់រំដោះ**

ការផ្ញើប្រាក់ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬតុលាការអនុវត្តការរក្សាការពារ។[44] នីតិវិធីនេះ គឺមានចែងលម្អិត នៃការផ្ញើប្រាក់ និងមានកំណត់នៅក្នុង សេចក្ដីណែនាំរបស់ក្រសួងយុត្តិធម៌កំពុងធ្វើសេចក្ដីព្រាង។

**ផ្នែកទី៣ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

បន្ទាប់ពីតុលាការបានចេញដីកាសម្រេចហើយ តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នទៅភាគី។[45] មានន័យថា តុលាការត្រូវរៀបចំខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹងដើម្បីជូនដំណឹងដល់ភាគីដែលមានជាប់ពាក់ព័ន្ធនឹងប្រយោជន៍នៃវត្ថុដែលបានរឹបអូសជាបណ្ដោះអាសន្ននោះ តាមនីតិវិធីដែលបានច្បាប់កំណត់។ នីតិវិធីនៃការជូនដំណឹងនេះ អ្នកប្រតិបត្តិការអាចប្រើប្រាស់គ្រប់មធ្យោបាយដូចជា តាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសណីយ៍ សំបុត្រជាដើម ដើម្បីឱ្យភាគីដែលត្រូវទទួលបានការបញ្ជូននោះបានដឹងពីដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ហើយផ្ដល់ឱកាសដល់កូនបំណុលក្នុងការប្ដឹងតវ៉ា។[46] ម្យ៉ាងទៀតការបញ្ជូននេះត្រូវធ្វើតាមឆន្ទានុសិទ្ធិលើកលែងតែក្នុងករណីដែលមានបញ្ញត្តពិសេសនៅក្នុងច្បាប់។[47] ឯកសារដែលត្រូវបញ្ជូនទៅភាគីនោះត្រូវតែ ឯកសារថតចម្លងទាំងអស់លើកលែងតែក្នុងករណីដែលមានបញ្ញត្តពិសេសនៅក្នុងច្បាប់។[48]

**១. ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន**

ក្រឡាបញ្ជី គឺជាអ្នកទទួលបន្ទុកក្នុងការធ្វើកិច្ចការបញ្ជូនដែលត្រូវបញ្ជូនទៅអ្នកទទួលបានការបញ្ជូន[49] ចំណែកអ្នកដែលត្រូវបានប្រតិបត្តិការបញ្ជូនកិច្ចការបញ្ជូន គឺបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី។[50]

**អ្វីដែលចោទជាបញ្ហា ថាតើមុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន (ក្រឡាបញ្ជី) មានអ្វីខ្លះ?**

[44] សូមមើលមាត្រា ៥៤៧.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[45] សូមមើលមាត្រា ៥៤៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[46] សូមមើលមាត្រា ៥៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[47] សូមមើលមាត្រា ២៤៧.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[48] សូមមើលមាត្រា ២៤៧.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[49] សូមមើលមាត្រា ២៤៦.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] សូមមើលមាត្រា ២៤៦.២ និងទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្រឡាបញ្ជីដើរតួនាទីយ៉ាងសំខាន់ជាមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន ហើយកិច្ចការនោះមានដូចជា៖

- ធ្វើ ឬផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ការបញ្ជូន
- ប្រគល់អំណាចនៃការបញ្ជូនឯកសារនោះ ទៅមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។
- បន្ទាប់ពីបានទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួច ក្រឡាបញ្ជីត្រូវយករបាយការណ៍នៃការបញ្ជូននោះទៅជូនចៅក្រម ដើម្បីចៅក្រមធ្វើការពិនិត្យមើលថាតើការបញ្ជូននេះត្រឹមត្រូវហើយ ឬនៅ?
- ជាចុងក្រោយ ត្រូវរក្សាទុករបាយការណ៍នៃការបញ្ជូននេះទុកនៅក្នុងសំណុំរឿងដោយរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ និងឱ្យបានល្អបំផុតទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារទាំងអស់នោះ ដើម្បីបញ្ជាក់ថាឯកសារដែលត្រូវការបញ្ជូន គឺបានបញ្ជូនទៅដល់អ្នកដែលត្រូវទទួលការបញ្ជូនរួចហើយ។

**តើមុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានអ្វីខ្លះ?** មុខងារទាំងនោះរួមមាន៖

- ធ្វើការបញ្ជូនដោយផ្ទាល់ចំពោះជនដែលត្រូវទទួលការបញ្ជូន។
- ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូន។
- ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននេះទៅតុលាការដើម។

របាយការណ៍អំពីការបញ្ជូនដែលត្រូវធ្វើដោយមន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវតែបញ្ជាក់អំពីចំណុចដូចមានចែងក្នុងមាត្រា២៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីរួមមាន៖

ក. សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។

ខ. ជនដែលត្រូវទទួលការបញ្ជូន។

គ. ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានបញ្ជូន។

ឃ. វិធីបញ្ជូន

ង. ចំណាត់ការក្នុងការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ។

ច. ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួលឯកសារ។

ឆ. ហេតុការណ៍ ដែលអ្នកទទួលការបញ្ជូនមិនព្រមទទួល (ក្នុងករណីបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល)។

ជ. ហេតុការណ៍នៅក្នុងករណីនៃការបញ្ជូនតាមវិធីបង្គ្រប់កិច្ច និងទុកចោល។

ឈ. ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។

## ២.ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

អ្នកដែលគ្មានសមត្ថភាពក្នុងបណ្ដឹងមានដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភជាជនដែលត្រូវការអ្នកតំណាងក្នុងការធ្វើសកម្មភាពបណ្ដឹង។ ហេតុនេះការបញ្ជូន ដីកាសម្រេចរក្សាការពារ គឺបញ្ជូនទៅអ្នកតំណាង ឬ អាចបញ្ជូនទៅនរណាម្នាក់ គឺជាការគ្រប់គ្រាន់ ប្រសិនបើជន នោះមានអ្នកតំណាងច្រើននាក់។ យ៉ាងណាមិញ ក៏មានករណីលើកលែងផងដែរចំពោះជនដែលអាចធ្វើ សកម្មភាពបណ្ដឹងដោយខ្លួនឯងបាន ដោយមិនចាំបាច់មានអ្នកតំណាង គឺអនីតិជនដែលទទួលការអនុញ្ញាត ឱ្យប្រកបអាជីវកម្ម[51] និងអនីតិជនដែលទទួលបានអត្តាធិនភាព។ បន្ថែមពីនេះ ក្នុងមាត្រា២៤៨ បានបញ្ជាក់ថា៖

១.ការបញ្ជូនទៅបុគ្គលអសមត្ថភាពក្នុងបណ្ដឹង ត្រូវធ្វើទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់។

២.ចំពោះករណីដែលអ្នកមានសិទ្ធិ មានតំណាងរួមគ្នាច្រើននាក់ ការបញ្ជូនអាចធ្វើទៅចំពោះតែជនណាម្នាក់ជាការគ្រប់គ្រាន់។

៣.ការបញ្ជូនទៅអ្នកជាប់ពន្ធនាគារត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។

## ៣.នីតិវិធីនៃការបញ្ជូន

### ៣.១.ការបញ្ជូនដោយការប្រគល់

ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូនទៅអ្នកដែលទទួល ការបញ្ជូននោះ។ ការបញ្ជូន ត្រូវធ្វើទៅដល់លំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែល ត្រូវទទួលបានការបញ្ជូន។ ប៉ុន្តែចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើទៅទីកន្លែង អាជីវកម្ម ឬទីស្នាក់ការរបស់អ្នកតំណាងបាន។

### ៣.២.ការប្រគល់ដោយជួបប្រទះ

ក្នុងករណី ជនដែលត្រូវទទួលការបញ្ជូននោះពុំមានការច្បាស់លាស់ថា មានទីលំនៅឋាន ទីសំណាក់ ទីអាជីវកម្ម ឬទីស្នាក់ការនៃព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលបានជួបប្រទះ អ្នកនោះតែម្ដង លើកលែងតែករណីបញ្ជូនចំពោះអ្នកដែលបានជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា ២៥០។ បញ្ញត្តិនេះក៏ត្រូវអនុវត្តផងដែរចំពោះករណីមានទីលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ ច្បាស់លាស់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាបញ្ជូនទៅបុគ្គលដែលបានស្គាល់ទីកន្លែងច្បាស់លាស់ក៏ដោយ បើជួបជននោះនៅកន្លែងថៃដន្យណាមួយ ហើយជននោះបានយល់ព្រមទទួលការបញ្ជូន ត្រូវចាត់ទុកថាជា ការបញ្ជូនដោយជួបប្រទះ។

[51]មាត្រា ២០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**៣.៣.ការបញ្ជូនដោយមន្ត្រីបំពេញកិច្ច**

ក្នុងករណីដែលមន្ត្រីទទួលបន្ទុកការបញ្ជូនឯកសារ (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) នោះមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូនទេ នោះមន្ត្រីទទួលបន្ទុកការបញ្ជូននោះអាចប្រគល់ឯកសារទៅអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន។

អ្នកដែលមានការយល់ដឹងសមរម្យ (មិនចាំបាច់ជានីតិជនទេ) សម្តៅលើ៖ អ្នកដែលយល់ដឹងពីសារៈសំខាន់នៃឯកសារដែលបានបញ្ជូននោះ យល់ពីអត្ថន័យនៃឯកសារដែលខ្លួនបានទទួល និងមានសមត្ថភាពអាចយកឯកសារនេះទៅប្រគល់ឱ្យអ្នកដែលត្រូវទទួលការបញ្ជូន។ **ឧទាហរណ៍៖** ប្តី អាចទទួលយកឯកសារនោះជំនួសប្រពន្ធដែលជាអ្នកត្រូវទទួលការបញ្ជូននោះបាន។ ប៉ុន្តែប្រសិនបើ ប្តីជាអ្នកប្តឹងប្រពន្ធវិញនោះ ហើយប្តីទទួលជំនួសប្រពន្ធនឹងត្រូវចាត់ទុកជាមោឃៈ ព្រោះមានទំនាស់ផលប្រយោជន៍ហើយមិនរំពឹងថា ប្តី នឹងយកឯកសារដែលត្រូវបញ្ជូននោះទៅឱ្យប្រពន្ធនោះទេ។

**៣.៤.ការបញ្ជូនដោយទុកចោល**

ក្នុងករណីដែលជនត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ២៥២ បើមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន។ **ឧទាហរណ៍៖** នៅពេលដែលអាជ្ញាសាលាបានយកឯកសារ (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចនវត្ថុ) ទៅប្រគល់ឱ្យលោក **ខ** តែមិនបានជួបជាមួយលោក **ខ** ទេ ឃើញតែអ្នកបម្រើម្នាក់ បន្ទាប់មកអាជ្ញាសាលាក៏បានប្រគល់ឯកសារនោះទៅនាង តែនាងមិនព្រមទទួលឯកសារនោះទេដោយសំអាងថា នាងគ្រាន់តែជាអ្នកបម្រើ មិនហានទទួលទេ។ ហេតុផលនេះមិនអាចទទួលយកបានទេ ហើយអាជ្ញាសាលាអាចទុកដីកា ឬឯកសារនោះនៅចំពោះមុខអ្នកបម្រើនោះបាន។ យ៉ាងណាមិញ បើនាងលើកហេតុផលថា លោក **ខ** មិនបាននៅផ្ទះទេ ទៅក្រៅប្រទេសយូរហើយ មិនដឹងពេលណាត្រឡប់មកវិញ ហើយនាងក៏មិនអាចទាក់ទងទៅលោក **ខ** បានដែរ។ ករណីនេះអាជ្ញាសាលាមិនអាចទុកដីកាសម្រេចនោះជាមួយអ្នកបម្រើបានទេ។

**៣.៥.ការបញ្ជូនទៅបរទេស**

នៅក្នុងករណីដែលជនត្រូវទទួលការបញ្ជូននោះមិននៅក្នុងប្រទេស ឬមានលំនៅនៅក្រៅប្រទេស ហើយពុំមានទីសំណាក់ ឬទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ នោះមានវិធីសាស្ត្រពីរយ៉ាងដើម្បីបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូនគឺ៖

ទី១.ករណីជនដែលត្រូវទទួលការបញ្ជូនជាជនបរទេស គប្បីធ្វើការបញ្ជូនទៅក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

ទី២. ករណីជនដែលទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីធ្វើការបញ្ជូនដោយការប្រគល់ទៅឱ្យអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះឱ្យធ្វើការបញ្ជូន។ ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ មុនពេលបញ្ជូន តុលាការគួរគប្បីពិនិត្យមើលលើអនុសញ្ញា ឬ សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងៗ ឬការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់រវាងប្រទេសនោះ និងប្រទេសកម្ពុជា ព្រោះប្រទេសនោះអាចនឹងមានបទដ្ឋានគតិយុត្តចែងពីនីតិវិធីនៃការបញ្ជូន។

**៣.៦.ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការផ្សាយជាសាធាណៈអាចធ្វើទៅបានលុះត្រាតែបានបំពេញនូវលក្ខខណ្ឌណាមួយដូចខាងក្រោមៈ

១.ក្នុងករណីដែលប្រឹងប្រែងរកស្រាវជ្រាវយ៉ាងណាក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន។

២.ករណីដែលដឹងពីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូននៅតែមិនអាចធ្វើបាន ទោះបីព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។

៣.ករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេសបាន។

៤.ករណីដែលតុលាការមិនបានទទួលលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែគិតចាប់ពីថ្ងៃបញ្ជូន។

ម្យ៉ាងទៀត ការផ្សាយជាសាធារណៈនេះអាចធ្វើទៅបានក្នុងករណីមានការស្នើសុំឱ្យតុលាការផ្សាយជាសាធារណៈ និងមានការអនុញ្ញាតពីតុលាការ។ ជាងនេះទៅទៀត តុលាការអាចធ្វើការម្រេចដោយឆន្ទានុសិទ្ធិរបស់ខ្លួន បើតុលាការយល់ឃើញថាមានភាពចាំបាច់។ យ៉ាងណាមិញ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពីពីរដងទៅចំពោះភាគីដដែល តុលាការត្រូវធ្វើតាមឆន្ទានុសិទ្ធិ ប៉ុន្តែការបញ្ជូនទៅបរទេស ត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ។

ការផ្សាយជាសាធារណៈអាចធ្វើទៅបានតាមវិធីដូចជា៖

-ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ក្រឡាបញ្ជីជាអ្នករក្សានូវឯកសារដែលត្រូវបញ្ជូន និងអាចប្រគល់ឯកសារនោះទៅជនដែលត្រូវទទួលបានការបញ្ជូននៅពេលណាក៏បានដែរ និងអាចបិទប្រកាសនៅទីកន្លែងណាមួយដែលតុលាការទទួលស្គាល់ថាសមរម្យ។

-ម្យ៉ាងទៀត តុលាការអាចចុះនៅក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំណែកការបញ្ជូនដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច។

ការបញ្ជូនតាមការផ្សាយជាសាធារណៈមានអានុភាពនៅក្រោយអំឡុងពេល ០២ (ពីរ) សប្តាហ៍ដោយគិតពីថ្ងៃដែលបានបិទប្រកាស។ ចំណែកឯ ការបញ្ជូនតាមការផ្សាយជាសាធារណៈដែលបានធ្វើនៅបរទេសវិញនឹងមានអានុភាពនៅក្រោយអំឡុងពេល ០៦ (ប្រាំមួយ) សប្តាហ៍ បន្ទាប់ពីការបិទប្រកាស។ មានន័យថាការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថា អ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននោះ។

# ជំពូកទី ៣
# ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន
# ចំពោះអចលនវត្ថុ

# ជំពូកទី ៣

# ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

បន្ទាប់ពីបានទទួលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុទៅតាមពាក្យសុំរបស់ម្ចាស់បំណុលរួចហើយ ដើម្បីអាចរឹបអូសចំពោះអចលនវត្ថុរបស់កូនបំណុលបាន លុះត្រាតែស្ថាប័នមានសមត្ថកិច្ចជាអ្នករឹបអូសចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។ ក្នុងនោះដែរ ដើម្បីអាចឱ្យការអនុវត្តការរឹបអូសជាបណ្តោះអាសន្នអាចសម្រេចទៅបាន គប្បីមើលទៅលើចំណុចដូចជា **លក្ខខណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន** (**ផ្នែកទី១**) **ពាក្យសុំឱ្យអនុវត្ត** (**ផ្នែកទី២**) និង **ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** (**ផ្នែកទី ៣**)។

## ផ្នែកទី ១ លក្ខខណ្ឌនៃការអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន

ជាកិច្ចដំបូង មុននឹងឈានទៅដល់ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ម្ចាស់បំណុលត្រូវមើលទៅលើលក្ខខណ្ឌមួយចំនួនដូចជា **អំឡុងពេលនៃការអនុវត្ត** (**១**) ថាតើមានគោរពទៅតាមចិរវេលាដែលបានកំណត់នៅក្នុងច្បាប់ហើយឬនៅ? និង **ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត** (**២**) ដោយមានបញ្ជាក់ពីមូលហេតុនៃការមិនដាក់រូបមន្តអនុវត្ត ដើម្បីអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន។

### ១. អំឡុងពេលនៃការអនុវត្ត

នៅពេលដែលម្ចាស់បំណុលទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម្ចាស់បំណុលត្រូវអនុវត្តរឹបអូសជាបណ្តោះអាសន្នក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលបានដីកាសម្រេចរឹបអូស។ ការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនឹងមិនអាចអនុវត្តបានឡើយ ប្រសិនលើសរយៈពេល០២ (ពីរ)សប្តាហ៍នេះ។[52] ដូចបានរៀបរាប់អំពីចរិតលក្ខណៈរបស់ការរឹបអូសជាបណ្តោះអាសន្នគឺមានលក្ខណៈបន្ទាន់បង្ខំ ដូច្នេះហើយដោយយោងតាមស្មារតីរបស់ច្បាប់ ការកំណត់រយៈពេល០២(ពីរ)សប្តាហ៍នេះគឺដើម្បីឆ្លើយតបចំពោះភាពបន្ទាន់បង្ខំនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមិនអនុវត្តភ្លាមៗបែបនេះទេ នោះភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវបាត់បង់ ហើយដីកានេះនឹងត្រូវប្រែក្លាយជាគ្មានន័យ។ អ្វីដែលគួរតែកត់សម្គាល់នោះគឺការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ ប៉ុន្តែនីតិវិធីបន្តបន្ទាប់ពីនេះមិនបានកំណត់ពេលវេលាទេ។

---

[52] មាត្រា ៥៦២.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២. ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មានលក្ខណៈបន្ទាន់បង្ខំ ដូច្នេះហើយត្រូវមានអានុភាពអនុវត្តបានភ្លាមៗ និងលឿនបំផុត ដើម្បីកម្រិតសិទ្ធិចាត់ចែងអចលនវត្ថុកូនបំណុលឱ្យទាន់ពេលវេលា ជៀសវាងការចាត់ចែងអចលនវត្ថុដោយសេរី មានន័យថាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានអានុភាពអនុវត្តបានភ្លាមៗ ដោយមិនត្រូវការរូបមន្តអនុវត្តឡើយ[53]។ ជាទូទៅ បុគ្គលដែលទទួលរងនូវវិសាលភាពនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺមានតែភាគីដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុតែប៉ុណ្ណោះ។[54] ហេតុដូច្នេះហើយ បើការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះជនក្រៅពីភាគី ដែលបានកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការរឹបអូសនេះត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ព្រមទាំងរូបមន្តអនុវត្ត។[55] រូបមន្តអនុវត្តនេះ គឺជារូបមន្តអនុវត្តពិសេសដែលត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលទទួលបន្ទុករឿងក្តីរឹបអូសជាបណ្តោះអាសន្ន[56] ប៉ុន្តែត្រូវតែមានការអនុញ្ញាតពីតុលាការដែលស្ថិតនៅថែមទៀត។[57] ដើម្បីទទួលបានរូបមន្តអនុវត្តពិសេសនេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តជាលាយល័ក្ខណ៍អក្សរ ដែលមានទម្រង់ដូចខាងក្រោមនេះ៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ព្រមជាមួយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណនៃលិខិតអនុវត្ត។

គ. ហេតុការណ៍ និងមូលហេតុ ដែលទាមទារឱ្យផ្តល់រូបមន្តអនុវត្តពិសេស ឬទាមទារឱ្យផ្តល់រូបមន្តអនុវត្តច្រើនច្បាប់។[58]

បន្ទាប់ពីម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តពិសេស ក្រឡាបញ្ជីនឹងចេញរូបមន្តអនុវត្តពិសេសជូនម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងមានចុះហត្ថលេខារបស់ក្រឡាបញ្ជី និងសរសេរថ្ងៃ ខែ ឆ្នាំ នៃការផ្តល់រូបមន្តអនុវត្តពិសេស ដោយរូបមន្តអនុវត្តពិសេស ត្រូវសរសេរចំណុចខាងក្រោមដូចតទៅ៖

[53] សូមមើលមាត្រា ៥៦២.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[54] សូមមើលមាត្រា ៥៦៤ និងមាត្រា៣៥១.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[55] សូមមើលមាត្រា ៥៦២.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[56] សូមមើលមាត្រា ៥៦៤ និងមាត្រា៣៥៤.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] សូមមើលមាត្រា ៥៦៧ និងមាត្រា ៣៥៦.៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] សូមមើលមាត្រា ៥៦៤ និងមាត្រា ៣៥៥.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

ក. បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តរឹបអូសជាបណ្តោះអាសន្នបាន ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬភាគីម្ខាងទៀត។

ខ. ហេតុការណ៍ដែលផ្តល់រូបមន្តអនុវត្តពិសេស។

គ. ទំហំដែលអាចអនុវត្តការរឹបអូសជាបណ្តោះអាសន្ន (ទាំងមូល ឬផ្នែកណាមួយនៃសិទ្ធិទាមទារ)។

ឃ. ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍។[59]

## ផ្នែកទី ២ ពាក្យសុំឱ្យអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន

### ១. ស្ថាប័នអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន

បន្ទាប់ពីបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តាមពាក្យសុំរបស់ម្ចាស់បំណុល ម្ចាស់បំណុលត្រូវតែធ្វើការដាក់ពាក្យស្នើសុំឱ្យតុលាការអនុវត្តរឹបអូសជាបណ្តោះអាសន្នទៅលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល។ ម្ចាស់បំណុលអាចដាក់ពាក្យសុំការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការដែលចេញសេចក្តីសម្រេចនោះ។[60] មានន័យថាស្ថាប័នតុលាការដែលបានចេញដីការឹបអូសជាបណ្តោះអាសន្ន ក៏ជាស្ថាប័នតុលាការដែលមានសមត្ថកិច្ចសម្រាប់ការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែរ ដែលគេហៅថាតុលាការអនុវត្ត។ ដូចបានរៀបរាប់រួចមកហើយថា ការរឹបអូសជាបណ្តោះអាសន្នជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ឬសាលាដំបូងដែលអចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នស្ថិតនៅ។[61] ជាក់ស្តែងសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចរឹបអូបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់លោក **ក** ជាកូនបំណុលនោះលោក **ខ** ដែលជាម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំអនុវត្តដីការឹបអូសជាបណ្តោះអាសន្នទៅ សាលាដំបូងរាជធានីភ្នំពេញដដែល។

### ២. ពាក្យសុំអនុវត្ត

បន្ទាប់ពីបានដឹងតុលាការអនុវត្តដីការឹបអូសជាបណ្តោះអាសន្នរួចមកហើយ ជាកិច្ចបន្ទាប់ត្រូវដឹងពីរបៀបក្នុងការសរសេរពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន។ ជាគោលការណ៍ ពាក្យសុំអនុវត្តដីការឹបអូសជាបណ្តោះអាសន្នត្រូវធ្វើជាលាយលក្ខណ៍អក្សរ មិនអាចធ្វើផ្ទាល់មាត់បានទេ។[62] នៅពេលពាក្យសុំឱ្យអនុវត្តដីការឹបអូសជាបណ្តោះអាសន្នត្រូវមាន**ទម្រង់នៃពាក្យសុំអនុវត្ត** (ក) ច្បាស់លាស់ដូចបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ហើយម្ចាស់បំណុលក៏ត្រូវភ្ជាប់ជាមួយឯកសារសំខាន់ៗជាមួយពាក្យសុំឱ្យអនុវត្ត ដូច្នេះហើយម្ចាស់បំណុលអនុវត្តត្រូវដាក់**ឯកសារភ្ជាប់** (ខ)។

[59] មាត្រា ៥៦៤ និងមាត្រា ៣៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[60] មាត្រា ៥៦២.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[61] មាត្រា ៥៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] មាត្រា ៥៣៤.ច នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

**ក. ទម្រង់នៃពាក្យសុំអនុវត្ត**

នៅក្នុងពាក្យសុំរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវសរសេរបញ្ជាក់ចំណុចដូចតទៅ៖

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយ និងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

គ. សេចក្តីសុំឱ្យអនុវត្ត (វិធានអនុវត្តបង្ខំដោយផ្ទាល់)។

ឃ. សញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។[63]

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត សុំឱ្យអនុវត្តដីការឹបអូសជាបណ្តោះអាសន្នត្រង់ផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់ពីសេចក្តីនោះក្នុងពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន។[64] ចំពោះទម្រង់ និងចំណុចដែលត្រូវសរសេរ ម្ចាស់បំណុលនៃការអនុវត្តគួរគប្បីសរសេរឱ្យបានត្រឹមត្រូវតាមអ្វីដែលបានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ ដើម្បីឱ្យកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់មានភាពងាយស្រួល ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

**ខ. ឯកសារភ្ជាប់ជាមួយពាក្យសុំអនុវត្តដីការឹបអូសជាបណ្តោះអាសន្ន**

នៅពេលដែលម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យអនុវត្តទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជូនឯកសារដូចខាងក្រោមនេះជាមួយពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន៖

ក. ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ សំដៅដល់ឯកសារដែលក្រឡាបញ្ជីបានចម្លងចេញពីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នច្បាប់ដើម និងមានរំលេចពាក្យ "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" ហើយបានប្រកាសប្រថាប់ត្រាថា "បានឃើញ" ពីចៅក្រមទទួលបន្ទុកផងដែរ។[65]

ខ. លិខិតបញ្ជាក់ពីការតម្កល់ប្រាតិភោគ ជាទូទៅការបង្គាប់ឱ្យតម្កល់ប្រាតិភោគជាឆន្ទានុសិទ្ធិរបស់តុលាការ នៅក្នុងករណីដែលតុលាការឱ្យតម្កល់ប្រាតិភោគនោះនៅពេលដែលម្ចាស់បំណុលបានតម្កល់ប្រាតិភោគរួចហើយ ម្ចាស់បំណុល គប្បីភ្ជាប់ជូនឯកសារដែលបានបញ្ជាក់ពីការតម្កល់ប្រាតិភោគរបស់ខ្លួនទៅតុលាការអនុវត្ត។[66]

[63] មាត្រា ៥៦៤ និងមាត្រា ៣៤៩.២ និង៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា ៥៦៤ និងមាត្រា ៣៤៩.៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[65] មាត្រា ៥៦២.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[66] មាត្រា ៥៣៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

គ. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ (បើមានអ្នកតំណាងដោយអាណត្តិ) ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី ហើយសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ។ លើសពីនេះទៅទៀត នៅក្នុងវិធានវិជ្ជាជីវៈមេធាវីក៏បានបញ្ញត្តិថាមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ដែលត្រូវសរសេរលម្អិតពីសិទ្ធិ និងតួនាទីរបស់មេធាវី ដែលអតិថិជនប្រគល់ឱ្យស្របតាមច្បាប់។[67] ស្របតាមអត្ថន័យនេះ អ្នកតំណាងដោយអាណត្តិត្រូវភ្ជាប់ជូនលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនតុលាការអនុវត្ត ដើម្បីបង្ហាញពីការតំណាងដោយអាណត្តិជូនកូនក្តីរបស់ខ្លួនក្នុងសំណុំរឿងអនុវត្ត។

ឃ. ឯកសារបន្ទាប់បន្សំមួយចំនួនទៀត ក្នុងករណីខ្លះម្ចាស់បំណុលនៃការអនុវត្តអាចរៀបចំឯកសារមួយចំនួនបន្ថែមទៀតដើម្បីសម្រួលដល់ការអនុវត្តនីតិវិធីរឹបអូសជាបណ្តោះអាសន្នដូចជា ឧបសម្ព័ន្ធស្តីពីអចលនវត្ថុ (ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុច្រើនទីតាំង) ជាដើម។

## ផ្នែកទី ៣ ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[68] ដោយក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ[69]។ ពាក្យថាស្ថាប័ននៅក្នុងទីនេះសំដៅលើរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តដែលអចលនវត្ថុនោះតាំងនៅ។ បច្ចុប្បន្ននេះ អចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជាមួយចំនួនធំនៅមិនទាន់មានការចុះបញ្ជីដីធ្លីឱ្យបានត្រឹមត្រូវស្របតាមលិខិតបទដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ។ ហេតុដូច្នេះ ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នឹងធ្វើការបកស្រាយចំពោះ **ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី** (១) និង**ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជី** (២)។

ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការបញ្ជូនលិខិតផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ហើយលិខិតផ្ទុកផ្តាក់ត្រូវសរសេរ ឈ្មោះប្រទេស (ព្រះរាជាណាចក្រកម្ពុជា) បាវចនា ( ជាតិ សាសនា ព្រះមហាក្សត្រ) ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ក្រឡាបញ្ជី។

[67] មាត្រា២៣ ក្រមសីលធម៌មេធាវី នៃគណៈមេធាវី ឆ្នាំ ២០១២, មើលឧបសម្ព័ន្ធ២

[68] មាត្រា ៥៦៧.១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[69]មាត្រា ៥៦៧.៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

ចំណុចដែលបានរៀបរាប់នេះជាចំណុចទូទៅដែលត្រូវសរសេរក្នុងលិខិតផ្ទុកផ្តាក់ ហើយត្រូវសរសេរបន្ថែមចំណុចមួយចំនួនទៀត ស្របតាមប្រភេទលិខិតផ្ទុកផ្តាក់។[70]

គួរបញ្ជាក់ផងដែរថា ក្រោយគោលនយោបាយនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើឱ្យការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នប្រែប្រួលចំណុចមួយចំនួន។ គោលបំណងនៃការបង្កើតច្រកចេញចូលតែមួយ គឺដើម្បីលើកកម្ពស់ គុណភាព ប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំ ការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាតាមតម្រូវការរបស់ប្រជាពលរដ្ឋ។[71] ការអនុវត្តកន្លងមកលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តតែម្តង ប៉ុន្តែក្រោមទម្រង់នៃការផ្លាស់ប្តូរថ្មីគ្រប់ប្រភេទនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ[72] ត្រូវបញ្ជូនទៅផ្នែកជួរមុខ[73] នៃការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្តជាមុនសិន បន្ទាប់មកទើបការិយាល័យច្រកចេញចូលតែមួយបញ្ជូនលិខិតផ្ទុកផ្តាក់នេះបន្តទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តដើម្បីដំណើរការនីតិវិធីបន្ទាប់។ ក្នុងអំឡុងពេលនោះ ការិយាល័យច្រកចេញចូលតែមួយនឹងចេញ "បង្កាន់ដៃទទួលពាក្យ" ដើម្បីបញ្ជាក់ពីការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ទន្ទឹមនឹងនេះម្ចាស់បំណុលក៏ត្រូវ "បង់សេវាសាធារណៈ" ដូចមានកំណត់ក្នុងប្រកាសស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ។

## ១. ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលបានចុះបញ្ជីដីធ្លី គឺជាអចនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលត្រូវបានស្គាល់ថាជាវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬអាចហៅម្យ៉ាងទៀតបានថាជាប្លង់រឹង។ ក្នុងករណីដែលអចលនវត្ថុបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជី

[70] ប្រការ៥ ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០១១

[71] មាត្រា១ អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៧

[72] អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៧

[73] មាត្រា៥ ផ្នែកជួរមុខ គឺជាកន្លែងដែលប្រជាពលរដ្ឋប្រាស្រ័យដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំបង់ប្រាក់កម្រៃ និងទទួលយកលទ្ធផលសម្រេចជាផ្លូវការនៃការស្នើសុំសេវារដ្ឋបាល (អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៧

ដីធ្លីរួចរាល់ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នទៅរដ្ឋបាលសុរិយោដី ថ្នាក់រាជធានី ខេត្ត[74]។

ជាងនេះទៅទៀតលិខិតផ្ទុកផ្ដាក់ត្រូវសរសេរបន្ថែមចំណុចដូចខាងក្រោម៖

ក. កម្មវត្ថុ (សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន)។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ (លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំង)។

គ. គោលបំណងនៃការចុះបញ្ជី (ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ)។

ឃ. មូលហេតុ (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី ខែ ឆ្នាំ និងឈ្មោះតុលាការ)។

ង. ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត រួមទាំងអាសយដ្ឋាន។

ច. ឈ្មោះកូនបំណុល នៃការអនុវត្ត រួមទាំងអាសយដ្ឋាន។

ដោយមានភ្ជាប់ជូននូវឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[75] និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុផងដែរ។

បន្ទាប់មកទៀត មន្ត្រីសុរិយោដីថ្នាក់រាជធានី ខេត្តត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" ដោយត្រូវសរសេរថា "ត្រូវរឹបអូសជាបណ្ដោះអាសន្នលើកម្មសិទ្ធិតាមដីកាសម្រេចលេខ........ចុះថ្ងៃទី.........ខែ..........ឆ្នាំ របស់តុលាការ ......... (ជាទឹកក្រហម) រួចបោះត្រាលេខចារឹក និងចុះកាលបរិច្ឆេទ (ជាទឹកខៀវ ឬខ្មៅ)។[76]

## ២. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី ជាអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី នឹងត្រូវបានសន្មតថាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[77] ដោយស្គាល់ថាជាលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ឬអាចហៅម្យ៉ាងទៀតថាប្លង់ទន់។ ក្នុងករណីអចលនវត្ថុមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ ក្នុងនោះមាន

[74] ប្រការ ៥.១.១ ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០១១,

[75] ប្រការ ១៦ ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០១១

[76] ប្រការ ៣២.ក ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០១១

[77] ប្រកា ៤ ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤

ស្ថាប័នចំនួន ០២ (ពីរ) ដែលអាចទទួលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រួមមាន រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុនោះតាំងនៅ។[78]

ក្នុងនោះដែរក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្ដាក់ដើម្បីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលគោរពតាមទម្រង់ និងខ្លឹមសារដូចខាងក្រោម៖

ក. កម្មវត្ថុ គឺត្រូវសរសេរពីខ្លឹមសារនៃការចុះបញ្ជីអំពី ការរឹបអូសជាបណ្ដោះអាសន្ន។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ (ទីតាំងដី ទំហំដី និងលេខប័ណ្ណ)។

គ. ឈ្មោះ និងអាសយដ្ឋានរបស់កម្មសិទ្ធិករ។

ឃ. គោលបំណងនៃការចុះបញ្ជី (ការរឹបអូសជាបណ្ដោះអាសន្ន)។

ង. មូលហេតុ (ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន លេខ...ចុះថ្ងៃទី ខែ ឆ្នាំ)។

ច. ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល

ឆ. ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល។

លើសពីនេះទៅទៀត ត្រូវភ្ជាប់ជាមួយឯកសារមួយដែលជាឯកសារចម្លងយថាភូតនៃដីការឹបអូសជាបណ្ដោះអាសន្នមានការបញ្ជាក់ភាពត្រឹមត្រូវនៃដីកាសម្រេចដោយក្រឡាបញ្ជី និងឯកសារបញ្ជាក់ដំបូងអំពីកម្មសិទ្ធិរបស់កូនបំណុល។[79]

បន្ទាប់ពីបានទទួលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត និងរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចុះលេខរៀងនៃការទទួលលិខិតផ្ទុកផ្ដាក់នេះ ក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សដែលបង្កើតដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត។[80] ការចុះលេខរៀងនេះ ដើម្បីសម្គាល់ពីលំដាប់នៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ បើមានការដាក់ពាក្យសុំចុះបញ្ជីច្រើនលើអចលនវត្ថុតែមួយ។[81]

ទោះបីជារដ្ឋបាលសុរិយោដីថ្នាក់ ក្រុង ស្រុក ខណ្ឌ អាចទទួលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នពិតមែន ប៉ុន្តែរដ្ឋបាលសុរិយោដីថ្នាក់ ក្រុង ស្រុក ខណ្ឌ មិនមានសិទ្ធិផ្ដល់សេវារដ្ឋបាល

[78] ប្រការ៥ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤

[79] ប្រការ៦ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤

[80] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤, ប្រកា ៥ កថាខណ្ឌទី១ និងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមនីតិវិធី

[81] ប្រការ៧ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ២០១៣

ទាក់ទងនឹងការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះទេ ដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់អំពីការរឹបអូសជាបណ្តោះអាសន្ន និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ ដោយគ្មានការយឺតយ៉ាវ។ បន្ទាប់ពី រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត បានទទួលលិខិតផ្ទុកផ្តាក់នោះ និងឯកសារផ្សេងៗព្រមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូងទៅរដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ដើម្បីអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងឱ្យបានឆាប់រហ័ស និងគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។[82] ទន្ទឹមនឹងនេះ ម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចបង់ជាមុនរាល់ការចំណាយចុះបញ្ជីលើកដំបូង ឬសោហ៊ុយនៃការរឹបអូសជាបណ្តោះអាសន្ន ជាអាទិ៍។[83]

នៅពេលបញ្ចប់នីតិវិធីនៃការចុះបញ្ជីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ រាជធានី ខេត្ត ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូចការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី (ប្លង់រឹង) ខាងលើនេះ។[84]

[82] ប្រការ៥ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤

[83] ប្រការ៩ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤

[84] ប្រការ៨ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឆ្នាំ ២០១៤ និងប្រការ ៣២.ក ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០១១

# ជំពូកទី៤
# បណ្តឹងឧបាស្រ័យនៅក្នុងរឿងក្តីរំលែករួសជាបណ្តោះអាសន្ន
# ចំពោះអចលនវត្ថុ

# ជំពូកទី៤
# បណ្តឹងឧបាស្រ័យនៅក្នុងរឿងក្តីរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងរបស់ភាគីដែលមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចណាមួយរបស់ចៅក្រម ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។ ការតវ៉ា គឺជាបណ្តឹងមួយក្នុងបណ្តឹងឧបាស្រ័យដែលអាចធ្វើឡើងដោយកូនបំណុល ឬតតិយជនដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍ ដោយមានការអនុញ្ញាតពីច្បាប់។

## ផ្នែកទី១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

បណ្តឹងតវ៉ា គឺតម្រូវឱ្យមានការពិនិត្យសាជាថ្មីនូវសំណុំរឿង ដោយតុលាការដែលបានចេញសេចក្តីសម្រេចដែលត្រូវបានគេជំទាស់នោះ។ ចំពោះនីតិវិធីសុំឱ្យមានការវិនិច្ឆ័យ អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ កូនបំណុលមិនបានចូលរួមទេ ដោយសារតែដីកានេះត្រូវបានចេញដោយសម្ងាត់ដូច្នេះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ កូនបំណុលមិនអាចប្តឹងជំទាស់ភ្លាមៗបានទេ។ បន្ទាប់ពីតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរួចហើយ កូនបំណុលដែលមិនសុខចិត្តនឹងដីកាសម្រេចនោះ អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះបាន។[85]

### ១.នីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ា

បន្ទាប់ពីតុលាការទទួលបានពាក្យសុំតវ៉ា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការក៏ត្រូវគោរពនូវនីតិវិធីដែលច្បាប់បានបញ្ញត្តិទុកដូចខាងក្រោម៖

#### ក.ការទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចតវ៉ានេះ ក្រោយពីកូនបំណុលបានដាក់ពាក្យសុំតវ៉ា លើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនេះ តុលាការនេះ មិនអាចចេញដីកាសម្រេចតវ៉ានេះ ដោយមិនបានធ្វើការឆ្លងកាត់តាមបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរភាគីទេ។ ដូច្នេះ ក្រោយពីមានការទាញហេតុផលដោយផ្ទាល់មាត់ ឬការកំណត់កាលបរិច្ឆេទឱ្យភាគីចូលរួមរួចទើបតុលាការអាចចេញសេចក្តីសម្រេច។[86]

---

[85] មាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[86] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

**ខ. ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា**

ដើម្បីបញ្ចប់ការវិនិច្ឆ័យ អំពីការតវ៉ាផ្ទាល់មាត់ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យនេះ ដោយធ្វើការកំណត់ពេលវេលាដ៏សមរម្យបំផុតមួយ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ។[87]

**២. ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

នៅក្នុងដីកាសម្រេចអំពី ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តុលាការត្រូវទទួលស្គាល់ ឬផ្លាស់ប្ដូរ ឬលុបចោលនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ។ ក្រោយពេលដែលតុលាការបានចេញដីកាសម្រេច អំពីពាក្យសុំតវ៉ាចំពោះដីការួចមក សម្រេចរក្សាការពារនេះ ដោយបានទទួលស្គាល់ ឬផ្លាស់ប្ដូរ ឬ លុបចោលដីកាសម្រេចរក្សាការពាររួចមក តុលាការត្រូវធ្វើការបញ្ជូនដីកាសម្រេចនេះទៅភាគី។[88]

**ផ្នែកទី២ ការតវ៉ាចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន**

ការតវ៉ាចំពោះ ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ននេះ គឺជាបណ្ដឹងមួយដែលធ្វើឡើងដើម្បីតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់ក្នុងដីកាអនុវត្តនោះ។

**១. បណ្ដឹងតវ៉ារបស់តតិយជន**

មិនមែនមានតែគូភាគីទេដែលមានសិទ្ធិក្នុងការតវ៉ាចំពោះការរឹបអូសជាបណ្ដោះអាសន្នទេ ប៉ុន្តែតតិយជនក៏អាចធ្វើការតវ៉ាចំពោះការរឹបអូសជាបណ្ដោះអាសន្នបានផងដែរ។ នៅក្នុងករណីដែលតតិយជនមានការពាក់ព័ន្ធ និងផលប្រយោជន៍ តតិយជនក៏អាចធ្វើការតវ៉ាមិនត្រឹមតែចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្នទេ គឺថែមទាំងចលនវត្ថុទៀត ដែលដាក់ទៅស្ថាប័នអនុវត្តដែលជាតុលាការអនុវត្ត ឬអាជ្ញាសាលា មិនថាមានគោលបំណងសងជាប្រាក់ ឬគ្មានគោលបំណងសងជាប្រាក់។

**២. សមត្ថកិច្ច**

ការតវ៉ា គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការថ្នាក់ដដែល ដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ការតវ៉ានេះអាចធ្វើឡើងនៅពេលណាក៏បានដែរ ឱ្យតែមានការទាក់ទងនឹងផលប្រយោជន៍ ហើយមិនកំណត់អំឡុងពេលសម្រាប់ធ្វើការតវ៉ាដូចបណ្ដឹងជំទាស់នោះទេ។ ប៉ុន្តែនៅក្នុងករណីដែលមានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចេញដោយសាលាឧទ្ធរណ៍ ក្នុងនាមជាតុលាការអនុវត្តវិញគឺត្រូវស្ថិតនៅក្រោម

[87] មាត្រា ៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[88] មាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

សមត្ថកិច្ចរបស់សាលាដំបូងមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ។[89]

## ផ្នែកទី៣ ការសុំឱ្យលុបចោល និងការផ្អាកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ចំពោះការលុបចោលដីកាសម្រេចរក្សាការពារ មិនមែនមានត្រឹមតែបណ្តឹងតវ៉ា ដែលអាចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទេ គឺមានករណីផ្សេងៗទៀត ដូចជា **ការលុបចោលដោយមិនបានដាក់បណ្តឹងអង្គសេចក្តី** (១) និង **ការលុបចោលដោយការផ្លាស់ប្តូរស្ថានភាព** (២)

### ១. ការលុបចោលដោយមិនបានដាក់បណ្តឹងអង្គសេចក្តី

នៅពេលតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលដែលដាក់ពាក្យបណ្តឹងអង្គសេចក្តី និងឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យតាមពាក្យសុំរបស់កូនបំណុល។ ប៉ុន្តែទោះបីចែងអំពីអំឡុងពេលសមរម្យក៏ដោយ ក៏មិនឱ្យតិចជាង ០២ (ពីរ) សប្តាហ៍ដែរ។ យ៉ាងណាមិញ ក្នុងករណីដែលម្ចាស់បំណុលមិនបានដាក់បណ្តឹងអង្គសេចក្តី ឬឯកសារក្នុងអំឡុងពេលសមរម្យនោះទេ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះតាមពាក្យសុំរបស់កូនបំណុលបាន។[90]

### ២. ការលុបចោលដោយការផ្លាស់ប្តូរស្ថានភាព

បើមានការរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬការផ្លាស់ប្តូរស្ថានភាពផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចរឹអូសជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តាមពាក្យសុំរបស់កូនបំណុលបាន ដោយកូនបំណុលត្រូវតែធ្វើសេចក្តីបញ្ជាក់ដំបូង។[91]

## ផ្នែកទី៤ បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទដែលប្តឹងជំទាស់ទៅលើដីកាសម្រេចនានាទៅតុលាការជាន់ខ្ពស់ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។[92]

អ្នកដែលមានសិទ្ធិប្តឹងជំទាស់បាន គឺជាអ្នកដែលបាត់បង់ផលប្រយោជន៍ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។ បណ្តឹងជំទាស់អាចធ្វើបានលុះត្រាតែមានចែងនៅក្នុងច្បាប់។[93]

---

[89] មាត្រា ៥៦៧ ចំណុចទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[90] មាត្រា ៥៥៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[91] មាត្រា ៥៥៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[92]ផ្នែកទី៤.ខ សៀវភៅនីតិវិធីរដ្ឋប្បវេណី របស់លោកគ្រូ សាស្ត្រាចារ្យ សាន់ ជួយ

[93] មាត្រា ២៥៩.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

ដីកាសម្រេចមួយចំនួនដែលអាចប្តឹងជំទាស់បានមានដូចជា៖

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ
- ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ
- ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ។[94]

## ១. នីតិវិធី និងអំឡុងពេលបណ្តឹងជំទាស់

ដើម្បីប្តឹងជំទាស់បាន ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់នេះទៅតុលាការដើម ហើយតុលាការដើមត្រូវផ្ញើពាក្យបណ្តឹងជំទាស់នេះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។ ចំពោះនីតិវិធីនៃការប្តឹងជំទាស់ អ្នកដែលមានសិទ្ធិធ្វើបណ្តឹងជំទាស់អាចធ្វើបានតែអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលទទួលបានការបញ្ជូន។[95]

យ៉ាងណាមិញ បើក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរដីកាសម្រេចដើមក្នុងបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលបានសរសេរអំពីមូលហេតុនៃការទាមទារឱ្យលុបចោលនោះ ទៅតុលាការនៃបណ្តឹងជំទាស់ក្នុងអំឡុងពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។

នីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានរយៈពេលយូរ ឬយឺតជាងការតវ៉ា។ នៅក្នុងចំណុចខ្លះក៏ត្រូវអនុវត្តដូចនីតិវិធីនៃការតវ៉ាដែរ មានដូចជា៖

- ✓ ការទាញហេតុផលផ្ទាល់មាត់៖ នៅក្នុងបណ្តឹងជំទាស់ ចំពោះនីតិវិធីនៃបណ្តឹងជំទាស់ ជានីតិវិធីមួយដែលមានការរយៈពេលយូរ ឬយឺតជាងការតវ៉ា។ បណ្តឹងជំទាស់នេះ ចំណុចខ្លះក៏ត្រូវអនុវត្តដូចនីតិវិធីនៃការតវ៉ាដែរ មានដូចជា៖

នៅក្នុងបណ្តឹងជំទាស់ ចំពោះនីតិវិធីចាត់ចែងរក្សាការពារ តុលាការចាំបាច់ត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ ដោយត្រូវធ្វើការកំណត់ពេលដ៏សមរម្យ ដើម្បីធ្វើការទាញហេតុផលផ្ទាល់មាត់អាចឱ្យភាគីដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍អាចចូលរួមបាន។

## ២. ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់

នៅក្នុងការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់ មានលក្ខណៈដូចគ្នាទៅនឹងការបញ្ចប់ការវិនិច្ឆ័យការតវ៉ាដែរ ដោយសារតុលាកាត្រូវធ្វើការកំណត់ពេលអនុគ្រោះដ៏សមរម្យដើម្បីធ្វើការបញ្ចប់ការវិនិច្ឆ័យ។ ប៉ុន្តែបើ

[94] មាត្រា ៥៦១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[95] សូមមើលមាត្រា ៥៦១.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

តុលាការបានកំណត់បរិច្ឆេទហើយ តុលាការអាចប្រកាសភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ដូចដែលបានកំណត់ទៅតាមកាលបរិច្ឆេទ។[96]

## ផ្នែកទី៥ ការសុំឱ្យជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីរដ្ឋប្បវេណីមួយដែលអនុញ្ញាតឱ្យភាគីដែលទទួលរងនូវភាពអយុត្តិធម៌ ដោយការសម្រេចសេចក្តីមានចំណុចខ្វះចន្លោះ ក្នុងដំណើរការនីតិវិធីនៃបណ្តឹង ឬឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យសាលក្រម ឬសាលដីកានោះមានវិការៈធ្ងន់ធ្ងរ ឬមានភាពខ្វះខាតមិនប្រក្រតីនោះ ដែលបានចូលជាស្ថាពររួចហើយ អាចធ្វើបណ្តឹងស្នើសុំឱ្យតុលាការដែលបានចេញសាលក្រម ឬសាលដីកាចុងក្រោយនោះ ធ្វើការពិនិត្យ និងសម្រេចឱ្យលើកយកសំណុំរឿងដែលបានចូលស្ថាពរមកធ្វើការវិនិច្ឆ័យឡើងវិញម្តងទៀត។

### ១. មូលហេតុដែលអាចសុំប្តឹងជំនុំជម្រះសាជាថ្មី

ជាគោលការណ៍ច្បាប់នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦ ដើម្បីអាចស្នើសុំប្តឹងឧបាស្រ័យ ទាមទារជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ភាគីត្រូវមានមូលហេតុត្រឹមត្រូវ ដូចខាងក្រោម៖[97]

- បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬសាលដីកា ទៅតាមច្បាប់កំណត់។
- បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រមឬសាលដីកានោះ។
- បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹងឬខ្វះសិទ្ធិតំណាងដោយអាណត្តិ។
- បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាបានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី។
- បើភាគីបានសារភាព ឬត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រមឬសាលដីកាដោយសារបទល្មើសរបស់អ្នកដទៃ។
- បើឯកសារ ឬវត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬសាលដីកាត្រូវបានក្លែង ឬកែប្រែដោយបន្លំ។
- បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ

[96] មាត្រា ៥៥៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[97] មាត្រា ៣០៧ និងមាត្រា៣០៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬសាលដីកា។

- បើសាលក្រម ឬសាលដីកា ឬសេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬផ្នែក ព្រហ្មទណ្ឌ ឬការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា ត្រូវបានផ្លាស់ប្តូរដោយសារសេចក្តីសម្រេច ឬការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ។

- បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមាន ឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា។

- បើសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ។

ដើម្បីឱ្យមានតម្លាភាព និងយុត្តិធម៌ចំពោះការជំនុំជម្រះសារជាថ្មី តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនៃការជំនុំជម្រះនោះគឺ តុលាការដែលបានចេញសាលក្រម ឬសាលដីកាចុងក្រោយដែលចូលជាស្ថាពរនោះ។ ប៉ុន្តែ សមាសភាពចៅក្រមដែលបានចូលរួមក្នុងការវិនិច្ឆ័យចេញសាលក្រម ឬ សាលដីកាស្ថាពរក្នុងរឿងអង្គសេចក្តីរួចហើយ ពុំអាចចូលរួមក្នុងការជំនុំជម្រះ និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះបានឡើយ។

## ២.ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

នៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

**ក.** ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយ និងឈ្មោះ និងអាសយដ្ឋានរបស់តំណាងដែលច្បាប់បានកំណត់។

**ខ.** សញ្ញាណនៃសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងសេចក្តីទាមទារជំនុំជម្រះសាជាថ្មីចំពោះសាលក្រមឬសាលដីកានោះ។

**គ.** អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី។[98]

ចំពោះឯកសារចម្លងនៃសាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។[99] ចំពោះមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលបានអះអាងនៅក្នុងពាក្យបណ្តឹង ភាគីអាចកែប្រែបាន នៅក្រោយពេលដែលបានដាក់ពាក្យបណ្តឹងទាមទារ

[98] មាត្រា ៣១២.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[99] មាត្រា ៣១២.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

ឱ្យជំនុំជម្រះសាជាថ្មីបាន។[100]

## ៣.អំឡុងពេលនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ ថ្ងៃ (មិនអាចពន្យារពេលបានឡើយ) ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ក្រោយពេលដែលសាលក្រម ឬ សាលដីកាចូលជាស្ថាពរហើយ ឬ ៥ ឆ្នាំដោយគិតចាប់ពីសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ឬ មូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង។ ម្យ៉ាងវិញទៀត បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើឡើងដោយតតិយជនបាន ក្នុងករណីដែលភាគីដើមចោទ និងចុងចម្លើយរួមគំនិតគ្នាទទួលយកនូវសាលក្រម ឬសាលដីកាក្នុងបំណងដែលធ្វើឱ្យតតិយជនបាត់បង់សិទ្ធិ និងផលប្រយោជន៍។[101] ក្នុងករណីនេះគឺដើមចោទ និងចុងចម្លើយក្លាយជាសហចុងចម្លើយ។ ចំពោះនីតិវិធីនៃការជំនុំជម្រះសាជាថ្មីត្រូវយកនីតិវិធីនៃការជំនុំជម្រះលើកទី១ មកអនុវត្តដូចគ្នាផងដែរ។[102]

សរុបជារួមមក ការជំនុំជម្រះសាជាថ្មីនៃនីតិវិធីរដ្ឋប្បវេណីនេះគឺបានផ្តល់ឱកាសឱ្យភាគីដែលយល់ឃើញថាមានមូលហេតុដែលនាំមកនូវភាពអយុត្តិធម៌ ដោយសាលក្រម ឬសាលដីកាស្ថាពរ អាចទាមទារឱ្យធ្វើការជំនុំជម្រះជាថ្មីម្តងទៀតបាន។ ក៏ប៉ុន្តែការជំនុំជម្រះសាជាថ្មីនេះមិនអាចឱ្យភាគីក្នុងរឿងក្តីចេះតែទាមទារឱ្យជំនុំជម្រះបានតាមតែចិត្តចង់នោះទេ គឺត្រូវតែមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីច្បាស់លាស់ ដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

## ៤. តុលាការនៃការជំនុំជម្រះសាជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះ។[103]

[100] មាត្រា ៣១៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[101] មាត្រា ៣១១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[102] ស្រង់ ពីកម្មវិធីយល់ដឹងពីច្បាប់៖ ការជំនុំជម្រះសាជាថ្មី រៀបរៀងដោយ៖ លោកមេធាវី សេង ឈុនលី និងលោក រៀម គឹមឡេង ជាជំនួយការមេធាវី និងជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ ថ្ងៃទី២៧ ធ្នូ ២០២២

[103] មាត្រា ៣០៩.១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទ **ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** កន្លងមក ក្រុមយើងខ្ញុំបានរកឃើញថា ការរឹបអូសជាបណ្តោះអាសន្ននេះមានលំហូរនីតិវិធីជាច្រើនដែលប្រទាក់ក្រឡាគ្នាតាមលំដាប់លំដោយ ប្រៀបដូចជា "សម្លកំពឹស" ដូច្នេះដែរ ដោយនៅត្រង់ថា មុននឹងអាចអនុវត្តទៅលើការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះជាមុនសិន។ ពាក្យសុំនេះត្រូវសរសេរតាមលក្ខខណ្ឌដែលច្បាប់កំណត់ក្នុងមាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីដាក់ទៅតុលាការដែលមានសមត្ថកិច្ច ហើយតុលាការក៏ត្រូវត្រួតពិនិត្យពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃពាក្យសុំនោះ។ នៅដំណាក់កាលសម្រេច បើតុលាការយល់ឃើញថាពាក្យសុំមិនត្រឹមត្រូវទេ នោះតុលាការអាចចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះបាន ហើយម្ចាស់បំណុលអាចប្តឹងជំទាស់បានក្នុងអំឡុងពេល០២ (ពីរ) សប្តាហ៍ចាប់ពីពេលដែលបានទទួលដំណឹង (មាត្រា៥៤៤)។ ប៉ុន្តែបើតុលាការយល់ឃើញថា ពាក្យសុំនោះត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងបញ្ជូនដីកាសម្រេចនោះ ទៅភាគីតាមមាត្រា៥៤៣ ដើម្បីឱ្យភាគី (កូនបំណុល) បានដឹងពីខ្លឹមសារ ហើយតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីមកតុលាការក្នុងអំឡុងពេល០២ (ពីរ) សប្តាហ៍។ ដីកាសម្រេចនេះ មិនអាចប្តឹងជំទាស់បានភ្លាមៗទេ ប៉ុន្តែកូនបំណុលអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីការសម្រេចនេះបាន នៅពេលណាក៏បានដោយមិនមានកំណត់អំពីអំឡុងពេលឡើយ។ ចំណុចសំខាន់នៅត្រង់កន្លែងនេះ យើងយល់ឃើញថាទោះបីជាមានការដាក់ពាក្យសុំតវ៉ាពីកូនបំណុលក៏ពិតមែន ប៉ុន្តែវាមិនមានអានុភាពអាចផ្អាកការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននោះបានទេ។ ងាកមកវិញ ចំពោះ***ការអនុវត្តដីកាសម្រេចរឹបជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ*** ម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តក្នុងអំឡុងពេល០២ (ពីរ) សប្តាហ៍ចាប់ពីដែលទទួលបានការបញ្ជូនដីកាសម្រេចនោះទៅតុលាការដែលត្រូវអនុវត្តការរក្សាការពារ។ ចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនេះ មានពីរ៖ គឺ **ចំពោះអចលនវត្ថុដែលបានចុះបញ្ជី** (ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ទៅ ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ និង**អចលនវត្ថុមិនទាន់ចុះបញ្ជី** (ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចឱ្យចាប់ផ្តើមចុះបញ្ជីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ)។

វត្ថុដែលជាកម្មវត្ថុនៃការការរឹបអូសជាបណ្តោះអាសន្ន ត្រូវតែរក្សាទុកនូវតម្លៃ ឬស្ថានភាពដើមនៃវត្ថុដែលត្រូវការរឹបអូស ក្នុងគោលបំណងធ្វើយ៉ាងណាកុំឱ្យវត្ថុនោះធ្លាក់ទៅក្នុងដៃអ្នកដទៃ (តតិយជន) ដើម្បីរក្សាការពារសិទ្ធិលើបំណុលជាប្រាក់។ ម៉្យាងទៀត ដើម្បីជៀសវាងកុំឱ្យមានតែសាលក្រមឈ្នះក្តីតែវត្ថុនោះធ្លាក់លើអ្នកដទៃបាត់។

# អនុសាសន៍

# អនុសាសន៍

នៅចុងបញ្ចប់នៃកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំមានយោបល់មួយចំនួនពាក់ព័ន្ធនឹងប្រធានបទខាងលើ ដោយយើងដឹងរួចមកហើយថា **នីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ជានីតិវិធីដំបូងមុនឈានទៅដល់ការសម្រេចបាននូវការអនុវត្តដោយបង្ខំទៅលើអចលនវត្ថុរបស់កូនបំណុល ប៉ុន្តែទោះបីជានីតិវិធីនេះមានផលប្រយោជន៍ច្រើនក៏ដោយ ក៏នៅតែមានចំណុចខ្វះចន្លោះមួយចំនួនគឺប្រជាជនទូទៅមួយចំនួនមិនសូវយល់ដឹងពីនីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុឱ្យបានច្បាស់លាស់នោះទេ ដែលជាហេតុនាំឱ្យការដាក់ឯកសារទៅតុលាការមិនត្រឹមត្រូវស្របតាមពេលវេលាកំណត់ដោយច្បាប់។ ជាងនេះទៅទៀត ការប្រគល់ឯកសារពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ អំពីការចុះបញ្ជីអចលនវត្ថុ និងការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នតបតាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី នៅក្នុងរឿងក្ដីស្មុគស្មាញមួយចំនួនតូចមានលក្ខណៈយឺតយ៉ាវ ហេតុនេះក្នុងនាមយើងខ្ញុំជាអ្នកសិក្សាផ្នែកច្បាប់សូមធ្វើការផ្ដល់មតិយោបល់មួយចំនួនដូចតទៅៈ

## ក. ក្រសួងយុត្តិធម៌

- បង្កើន និងពង្រឹងសកម្មភាពក្នុងការផ្សព្វផ្សាយនីតិវិធីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុឱ្យបានទូលំទូលាយជាងមុនជូនសាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា កម្មវិធីវិទ្យុ ទូរទស្សន៍ ការសែត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដើម្បីធានាដល់ការយល់ដឹងឱ្យបានច្បាស់លាស់ដល់ប្រជាជន ជាពិសេសប្រជាជនទៅតាមតំបន់ដាច់ស្រយាល។
- បន្តពង្រឹងសមត្ថភាពដល់អ្នកអនុវត្តច្បាប់ និងអ្នកមានវិជ្ជាជីវៈ ដោយការផ្ដល់ជូនតាមរយៈសិក្ខាសាលា និងកម្មវិធីចំណេះដឹងផ្នែកច្បាប់ផ្សេងៗទៀត។

## ខ. ស្ថាប័នតុលាការ

- គួរតែពន្យល់ម្ចាស់បំណុល និងកូនបំណុលឱ្យបានច្បាស់លាស់ មុននឹងសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬសម្រេចច្រានចោលការទាមទារមួយចំនួនរបស់ម្ចាស់បំណុល ព្រោះពេលខ្លះម្ចាស់បំណុលមិនបានដាក់ឯកសារភ្ជាប់ជាមួយការទាមទារឱ្យបានត្រឹមត្រូវ ដែលជាហេតុនាំឱ្យតុលាការសម្រេចលើកចោល ឬច្រានចោលការទាមទារ។
-តុលាការគប្បីសួរម្ចាស់បំណុលឱ្យបានជាក់លាក់ ដើម្បីជៀសវាងពីស្ថានភាពដែលទំហំនៃការរឹបអូសជាបណ្ដោះអាសន្នមានទំហំធំជាងទំហំសិទ្ធិលើបំណុលដែលមានលើកូនបំណុលដែលអាចនាំឱ្យប៉ះពាល់ប្រយោជន៍ស្របច្បាប់របស់កូនបំណុល។

**គ. ក្រសួងពាក់ព័ន្ធជាមួយនឹងការចុះបញ្ជីអចលនវត្ថុ**

គួរគប្បីមានការបញ្ជូនឯកសារត្រឡប់មកក្រឡាបញ្ជីវិញឱ្យបានឆាប់រហ័ស ដើម្បីសម្រេចនូវការអនុវត្ត សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល លើកូនបំណុលកុំឱ្យយឺតយ៉ាវក្នុងន័យដើម្បីធានាភាពយុត្តិធម៌ទៅដល់ភាគី។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងព្រះរាជក្រម

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧។

- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/ ០២១, ២៧ កក្កដា ២០០៧។

- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

## ២. អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្របក, ០៨ កុម្ភៈ ២០១៧។

## ៣. ប្រកាស

- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ ប្រកដនស/១១, ០៣ ឧសភា ២០១១។

- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, លេខ ៣០ កយដនសប្រក/១៣, ២៩ មករា ២០១៣។

- ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រកដនស, ២១ វិច្ឆិកា ២០១៤។

- ប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់, លេខ ៣៥៦ សហវប្រក,២៦ មីនា ២០១៩។

## ៤. ឯកសារផ្សេងទៀត

-ក្រមសីលធម៌មេធាវី នៃគណៈមេធាវី, ២១ កញ្ញា ២០១២។

-ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី.* ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧។

-ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១.* ភ្នំពេញ៖ គម្រោងអភិវឌ្ឍវិស័យច្បាប់ និងតុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន (JICA) , ២០១៣។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្ដល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការផ្ដល់សេវារដ្ឋបាលទាំងនោះ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលទទួលបានតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត
### ផ្នែកទី១
### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា៤.–**

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមាន**អង្គភាពច្រកចេញចូលតែមួយ**សម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៥.–**

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

អង្គភាពច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។

**មាត្រា៦.–**

អង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(២)រូបជាជំនួយការ។

ប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយកទីចាត់ការនៃសាលារាជធានី ខេត្ត។

អនុប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយករងទីចាត់ការនៃសាលារាជធានី ខេត្ត។

ការតែងតាំងប្រធាននិងអនុប្រធានអង្គភាពច្រកចេញចូលតែមួយ ត្រូវអនុលោមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

**មាត្រា៧.–**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា៨.–**

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់អង្គភាពច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់បុគ្គលិកបំពេញការងារនៅក្នុងអង្គភាពនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា៩.–**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងស្ថានភាពជាក់ស្តែងនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗសម្រាប់បំពេញការងារនៅផ្នែកជួរមុខនៃអង្គភាពច្រកចេញចូលតែមួយ។

**មាត្រា១០.–**

អភិបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលដើម្បីចាត់តាំងបុគ្គលិកជំនាញយ៉ាងតិចចំនួនមួយ(១)រូប ដែលមានសមត្ថភាព និងបទពិសោធមកបំពេញការងារពេញម៉ោងនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើសេវារដ្ឋបាលតាមវិស័យជំនាញរបស់ខ្លួន លើកលែងតែប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់។

ក្នុងករណីខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយប្រធានមន្ទីរ អង្គភាពជំនាញនីមួយៗ ដើម្បីកំណត់អំពីប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសសាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់តាំងបុគ្គលិកជំនាញទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវារដ្ឋបាលទាំងនេះ។

**មាត្រា១១.–**

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

**មាត្រា១២.–**

ក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញងាយយល់និងច្បាស់លាស់។

## ជំពូកទី៣

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ផ្នែកទី១

### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា១៣.**_

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ឬយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

លក្ខណសម្បត្តិនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៤.**_

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាផ្នែកដែលទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។

**មាត្រា១៥.**_

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសលេខ ៩២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ។

បែបបទនិងនីតិវិធីនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២

### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា១៦.**_

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់

បុគ្គលិកបំពេញការងារនៅក្នុងការិយាល័យនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា១៧.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងតាមស្ថានភាពជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យមកបំពេញការងារនៅផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា ត្រូវចាត់តាំងបុគ្គលិកជំនាញមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាផ្នែកជួរក្រោយនៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពណាមួយពុំទាន់មានបុគ្គលិកជំនាញសម្រាប់ចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិករដ្ឋបាលរបស់ខ្លួនឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយទទួលរ៉ាប់រងក្នុងនាមជាភ្នាក់ងារតំណាងឱ្យវិស័យជំនាញនោះ។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានចាត់តាំងនោះ។

បុគ្គលិកដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលក្រុង ស្រុក ខណ្ឌ។ ក្របខ័ណ្ឌ និងបៀវត្សរបស់បុគ្គលិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្នុងក្រសួង ស្ថាប័នសាមីដោយទទួលបានការដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស ការលើកទឹកចិត្ត និងអត្ថប្រយោជន៍នានាតាមនីតិវិធីជាធរមាន។

**មាត្រា១៨.-**

ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

មាត្រា១៩.-

ក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៤

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

មាត្រា២០.-

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

មេឃុំ ចៅសង្កាត់ អាចប្រគល់សិទ្ធិក្នុងការពិនិត្យ ការសម្រេច និងការចុះហត្ថលេខាលើលិខិតអនុញ្ញាតឬលិខិតបញ្ជាក់ចាំបាច់មួយចំនួនជូនជំទប់ ចៅសង្កាត់រងរបស់ខ្លួនស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា២១.-

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងស្មៀន ឬបុគ្គលិកជំនួយការរដ្ឋបាលឱ្យបំពេញភារកិច្ចជាបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ ទទួលកម្រៃសេវារដ្ឋបាល និងពិនិត្យផ្តល់យោបល់លើសំណើសុំសេវារដ្ឋបាលដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

ការចាត់តាំងឬការប្រគល់ភារកិច្ចជូនបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ និងទទួលកម្រៃសេវារដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានទីកន្លែងសម្រាប់ការផ្តល់សេវារដ្ឋបាលឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់ការផ្តល់សេវារដ្ឋបាល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

មាត្រា២២.-

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលទៅតាមប្រភេទសេវា កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

មាត្រា២៣.-

ក្រសួងមហាផ្ទៃត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៥
## ការគ្រប់គ្រងនិងការចាត់ចែងចំណូលសេវារដ្ឋបាល

**មាត្រា២៤.-**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានចំណូលពីកម្រៃសេវារដ្ឋបាល។

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ និង/ឬថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការបែងចែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលការណ៍ និងនីតិវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៥.-**

ការបែងចែកចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៦
## ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា២៦.-**

គ.ជ.អ.ប មានតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធនានាក្នុងការគាំទ្រផ្នែកគោលនយោបាយ ការកៀរគរធនធាន និងការគាំទ្របច្ចេកទេសពីអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប អាចប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៧.-**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលក្នុងការបង្កើតអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងគាំទ្រផ្នែកបច្ចេកទេសដល់ដំណើរការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាលដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។

ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការរៀបចំទីកន្លែងផ្តល់សេវា និងបំពាក់សម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងមហាផ្ទៃ អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ឬយន្តការដែលមានស្រាប់ដើម្បីជានាលើការគ្រប់គ្រង ការគាំទ្រ ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះ។

**មាត្រា២៨.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវសម្របសម្រួល និងជំរុញមន្ទីរ អង្គភាពជំនាញរបស់ខ្លួនក្នុងការចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយនៅក្នុងអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ ព្រមទាំងផ្តល់ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវធានាឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ព្រមទាំងទទួលដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតអង្គភាពច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆមាសទី១នៃឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ត្រូវបង្កើតការិយាល័យច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលក្ខណសម្បត្តិសមស្របសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតយន្តការច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ២

# ក្រមសីលធម៌មេធាវី
# នៃគណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ ២០១២

# ក្រមសីលធម៌មេធាវី
# នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី១
## វិធានទូទៅ

**មាត្រា ១..** គោលបំណង

ក្រមសីលធម៌មេធាវីមានគោលបំណងការពារនិងពង្រឹងឯករាជ្យភាព សេរីភាពនៃវិជ្ជាជីវៈមេធាវី និងធានាសេចក្តីថ្លៃថ្នូររបស់មេធាវី ទាំងក្នុង និងក្រៅការប្រកបវិជ្ជាជីវៈ ដើម្បីបង្កើនជំនឿទុកចិត្តពីសាធារណជន។

**មាត្រា ២..** វិសាលភាព

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះមេធាវីកម្មសិក្សានិងមេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣..** គោលការណ៍គ្រឹះ

នៅគ្រប់កាលៈទេសៈ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។

មេធាវីមិនត្រូវចូលរួមសកម្មភាពដែលមានលក្ខណៈផ្ទុយនឹងច្បាប់ វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។

**មាត្រា ៤..** បេសកកម្ម

មេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។

**មាត្រា ៥..** សេរីភាពនិងឯករាជ្យភាព

មេធាវីមានសេរីភាព និងឯករាជ្យភាពនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា ៦..** សុចរិតភាពនិងភាពស្មោះត្រង់

មេធាវីត្រូវគោរពនិងប្រតិបត្តិ នូវគោលការណ៍សុចរិតភាពនិងភាពស្មោះត្រង់។

**មាត្រា ៧..** ការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួនដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ។ ការសម្ងាត់នេះមិនត្រូវអាចឲ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ។

ពុំមានកាតព្វកិច្ចលាក់ការសម្ងាត់ទេ ល្គឹកណាមេធាវីត្រូវឆ្លើយតបទៅនឹងបណ្ដឹងអតិថិជនរបស់ខ្លួន ប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកម្រិតនៃការចាំបាច់នៃការការពាររបស់ខ្លួនតែប៉ុណ្ណោះ។

ត្រូវទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការផ្ដល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយដែលមេធាវីតាក់តែងឡើងសម្រាប់អតិថិជនរបស់ខ្លួន និងលិខិតស្នាមទាំងឡាយដែលមេធាវីនិងអតិថិជនរបស់ខ្លួនផ្ញើទាក់ទងគ្នា។

**មាត្រា ៨..** វិញ្ញាបនបត្រសមាជិកគណៈមេធាវី

មេធាវីបញ្ជាក់ពីភាពត្រឹមត្រូវនៃមុខងាររបស់ខ្លួន តាមរយៈវិញ្ញាបនបត្រដែលចេញដោយគណៈមេធាវី។

វិញ្ញាបនបត្រនេះត្រូវដកហូតមកវិញដោយគណៈមេធាវី ក្នុងករណីដែលមេធាវីបានលាឈប់ ឬ ត្រូវហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈក្នុងរយៈពេលមួយមានកំណត់ ឬ ត្រូវលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី។

**មាត្រា ៩..** អាវវិជ្ជាជីវៈមេធាវី

មេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវីនៅចំពោះមុខសវនាការ និងយុត្តាធិការគ្រប់ប្រភេទ លើកលែងតែមានប្រពៃណីផ្ទុយពីនេះ។

មេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវី នៅពេលចូលរួមពិធីផ្លូវការ ឬ បុណ្យរបស់គណៈមេធាវី តាមតម្រូវការរបស់គណៈមេធាវី។

## ជំពូកទី២
## ទីលំនៅវិជ្ជាជីវៈនិងកន្លែងពិគ្រោះយោបល់

**មាត្រា ១០..** ការិយាល័យដើម

សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ ត្រូវមានការិយាល័យដើម ឬ ជាសមាជិកនៃការិយាល័យមេធាវីណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យដើមរបស់មេធាវីត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- នាមករណ៍ ស្លាកសញ្ញា អាសយដ្ឋានការិយាល័យ និងលេខទូរស័ព្ទ
- ទូរសារ ទូរពុម្ព គេហទំព័ររបស់ការិយាល័យនិងរូបភាពរបស់ការិយាល័យ (ប្រសិនមាន)
- បញ្ជីឈ្មោះមេធាវីដែលបានចូលរួមក្នុងការិយាល័យនេះ (ប្រសិនមាន)
- គំនូសបង្ហាញទីតាំងការិយាល័យ និងគំនូសបង្ហាញប្លង់ក្នុងការិយាល័យ
- រូបសញ្ញា (Logo) ប្រសិនបើមាន ត្រូវមានការអនុញ្ញាតពីគណៈមេធាវី
- ឯកសារពាក់ពន្ធ័ផ្សេងទៀត តាមតម្រូវការរបស់គណៈមេធាវី។

ការតាំងការិយាល័យប្រកបវិជ្ជាជីវៈត្រូវធ្វើនៅដាច់ដោយឡែកពីការិយាល័យពាណិជ្ជកម្ម ក៏ប់រងឲ្យបាននូវការគោរពគោលការណ៍នៃសេចក្ដីថ្លៃថ្នូរ និងឯករាជ្យភាពព្រមទាំងធានានូវការសម្ងាត់នៃវិជ្ជាជីវៈ។

សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកបវិជ្ជាជីវៈ នៅតាមអង្គភាព ឬ ស្ថាប័នណាមួយដែលគ្មានការិយាល័យដើម ឬ ជាសមាជិកនៃការិយាល័យមេធាវីណាមួយត្រូវផ្ដល់អាសយដ្ឋានជាក់លាក់សម្រាប់ទំនាក់ទំនងជាមួយគណៈមេធាវី។

**មាត្រា ១១..** ការិយាល័យសាខា

ការិយាល័យសាខា គឺជាការិយាល័យមួយដោយឡែកពីការិយាល័យដើម និងមានទីតាំងស្ថិតនៅក្រៅដែនដី រដ្ឋបាលរាជធានី-ខេត្តដែលការិយាល័យដើមតាំងនៅ។

មេធាវីដែលចង់បើកការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ ខាងលើ និងយ៉ាងតិចត្រូវមានមេធាវីពេញសិទ្ធិម្នាក់ជាអ្នកទទួលខុសត្រូវ។

ការបើកការិយាល័យសាខាត្រូវមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាគណៈមេធាវី។ ការបើកការិយាល័យសាខាធ្វើបានតែមួយគត់ នៅតាមរដ្ឋបាលដែនដីនៃរាជធានី និងខេត្តនីមួយៗ។

មេធាវីដែលមានបំណងបើកការិយាល័យសាខានៅបរទេស ត្រូវជូនដំណឹងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគោរពតាមលក្ខខណ្ឌតម្រូវនានារបស់គណៈមេធាវីបរទេសនោះ។

ដើម្បីធានាការសម្ងាត់និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈមេធាវី គណៈមេធាវីអាចត្រួតពិនិត្យការិយាល័យដើម និងការិយាល័យសាខាបាននៅរាល់ម៉ោងធ្វើការ ដោយគ្រាន់តែជូនដំណឹងជាមុនក្នុងរយៈពេល៧ថ្ងៃនៃថ្ងៃធ្វើការយ៉ាងតិច ទៅការិយាល័យដែលត្រូវត្រួតពិនិត្យនោះ។

**មាត្រា ១២..** ការិយាល័យសាខានៃមេធាវីបរទេស

មេធាវីបរទេស អាចបើកការិយាល័យសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមេធាវីបរទេសនោះ បានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីបរទេសដែលគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈ ត្រូវគោរពតាមច្បាប់ និងវិធានវិជ្ជាជីវៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៣..** ទីកន្លែងទទួលពិគ្រោះច្បាប់

មេធាវីអាចទទួលពិគ្រោះច្បាប់ជូនអតិថិជននៅការិយាល័យដើម ឬ ក្នុងការិយាល័យសាខារបស់ខ្លួន។

មេធាវីអាចទទួលពិគ្រោះច្បាប់ នៅទីកន្លែងផ្សេងទៀតដែលមានភាពសមរម្យ និងធានាបាននូវការសម្ងាត់វិជ្ជាជីវៈ។

## ជំពូក៣
## ការផ្សព្វផ្សាយ

**មាត្រា ១៤..** ការផ្សព្វផ្សាយពីមុខងារ

គណៈមេធាវី ធានារ៉ាប់រងផ្សព្វផ្សាយពីមុខងារនៃវិជ្ជាជីវៈមេធាវីជារួម។

**មាត្រា ១៥..** ការផ្សព្វផ្សាយវិជ្ជាជីវៈជាឯកជន

មេធាវីមិនត្រូវផ្តល់នូវព័ត៌មានក្លែង ឬ បន្លំបោកប្រាស់ ឬ អួតអាងពីសេវាកម្មរបស់ខ្លួន ដើម្បីផ្សព្វផ្សាយទាក់ទាញអតិថិជនឡើយ។

មេធាវីអាចធ្វើការផ្សព្វផ្សាយអំពីសេវាកម្មនៃការិយាល័យមេធាវីរបស់ខ្លួន តាមរយៈទំនាក់ទំនងជាលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក រួមទាំងប្រពន្ធ័ផ្សព្វផ្សាយជាសាធារណៈ បន្ទាប់ពីមានការមានការអនុញ្ញាតពីក្រុមប្រឹក្សា។

**មាត្រា ១៦..** ក្រដាសសរសេររបស់មេធាវី និងនាមប័ណ្ណរបស់មេធាវី

ក្រដាសសរសេររបស់មេធាវីត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូលបកតិនាមមេធាវី ឬ នាមករណ៍នៃក្រុមហ៊ុនមេធាវី
- រូបសញ្ញា Logo ប្រសិនជាមាន
- និទ្ទេស "មេធាវី" ឬ "មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា"
- ទីលំនៅវិជ្ជាជីវៈដើម ហើយបើមានការិយាល័យសាខា ត្រូវចុះអាសយដ្ឋាននៃការិយាល័យសាខាដែលបានបើកដោយត្រឹមត្រូវតាមច្បាប់
- លេខកូដប្រៃសណីយ៍ ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដទៃទៀត ប្រសិនជាមាន។

មេធាវីទាំងឡាយដែលបំពេញការងារនៅការិយាល័យប្រមូលផ្តុំ ដោយពុំបានធ្វើជាសមាគម ក្រោមរូបភាពណាមួយ អាចត្រូវអនុញ្ញាតឲ្យប្រើក្រដាសសរសេររួមបាន ក្រោមលក្ខខណ្ឌដែលមិនបង្កើតឲ្យមានការភ័ន្តច្រឡំជាមួយរចនាសម្ព័ន្ធការងារ។

នាមប័ណ្ណផ្ទាល់របស់មេធាវីត្រូវចុះនិទ្ទេសដូចតទៅ៖

- នាមត្រកូល បកតិនាមមេធាវី ឬ នាមករណ៍នៃក្រុមហ៊ុនមេធាវី
- រូបសញ្ញា Logo ប្រសិនជាមាន
- និទ្ទេស "មេធាវី"
- ទីលំនៅវិជ្ជាជីវៈដើម ហើយបើមានការិយាល័យសាខា ត្រូវចុះអាសយដ្ឋាននៃការិយាល័យសាខាដែលបានបើកដោយត្រឹមត្រូវតាមច្បាប់
- លេខកូដប្រៃសណីយ៍ ទូរគមនាគមន៍ និងបែបបទនៃទំនាក់ទំនងដទៃទៀត ប្រសិនជាមាន។

**មាត្រា ១៧..** អន្តរាគមន៍តាមប្រព័ន្ធផ្សាយព័ត៌មានជាសាធារណៈនៃមេធាវី

គ្រប់អន្តរាគមន៍សាធារណៈ ឬ តាមប្រព័ន្ធផ្សាយព័ត៌មានជាសាធារណៈរបស់មេធាវីក្នុងឋានៈខ្លួនជាមេធាវី អាចអនុញ្ញាតឲ្យធ្វើបានតែក្នុងក្របខ័ណ្ឌនៃការគោរពដោយម៉ឺងម៉ាត់នូវកាតព្វកិច្ចនៃវិជ្ជាជីវៈ។ អន្តរាគមន៍បែបនេះ ទាមទារឲ្យមានការប្រុងប្រយ័ត្ន។

## ជំពូកទី៤
## មេធាវី និងអតិថិជន

**មាត្រា ១៨..** ទំនាក់ទំនងរវាងមេធាវី និងអតិថិជន

ទំនាក់ទំនងរវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងតាមកិច្ចសន្យា ហើយកិច្ចសន្យានោះមានប្រភពពីទំនៀមទំលាប់ និងពីការព្រមព្រៀងគ្នាទៅវិញទៅមក។ មេធាវីគឺជាអ្នកកាន់តំណែងការពារ និងតំណាងឲ្យអតិថិជន។

ទំនាក់ទំនងរវាងមេធាវី និងអតិថិជន កើតមាននៅពេលជនណាម្នាក់ បង្ហាញពីបំណងចង់ឲ្យមេធាវីផ្តល់សេវាកម្មផ្នែកច្បាប់ ហើយមេធាវីនោះយល់ព្រម។

**មាត្រា ១៩..** ការសម្ងាត់វិជ្ជាជីវៈ

មេធាវីគ្រប់រូបមានកាតព្វកិច្ចរក្សាការសម្ងាត់ជូនអតិថិជនរបស់ខ្លួនជាដាច់ខាត ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ មេធាវីមិនត្រូវបង្ហាញការសម្ងាត់របស់អតិថិជនខ្លួនឡើយ លើកលែងតែមានការជូនដំណឹង និងយល់ព្រមពីអតិថិជន ឬ កាលណាមានការអនុញ្ញាតដោយច្បាប់ ឬ តម្រូវដោយច្បាប់។

**មាត្រា ២០..** បញ្ហាលើការតាក់តែងលិខិតស្នាមដោយមេធាវី

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមតែម្នាក់ឯង តាមការព្រមព្រៀងពីគូភាគី អាចធ្វើសកម្មភាព ឬ ការពារលើការអនុវត្តលិខិតនោះបាន នៅពេលដែលការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់លើលិខិតស្នាមនោះលេចជាបញ្ហា តែមិនត្រូវធ្វើសកម្មភាពប្រឆាំងនឹងភាគីណាមួយដែលមាននៅក្នុងលិខិតស្នាមនោះឡើយ។

មេធាវីដែលបានចូលរួមក្នុងការតាក់តែងលិខិតស្នាម ក្នុងឋានៈជាទីប្រឹក្សារបស់ភាគីម្ខាង អាចធ្វើសកម្មភាពឬការពារលើការអនុវត្តន៍លិខិតនោះតទល់នឹងភាគីម្ខាងទៀតបាន។

មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមឬដែលជាអ្នកចូលរួមតាក់តែង មិនអាចបំពេញកិច្ចការ ឬ ការពារលើសុពលភាព ឬ លើការបកស្រាយលិខិតស្នាមដែលខ្លួនបានសរសេរនោះទេ កាលបើការអន្តរាគមន៍របស់ខ្លួននាំខ្លួនឲ្យទៅជាសាក្សី ឬ ឲ្យប៉ះពាល់ដល់ការសម្ងាត់វិជ្ជាជីវៈ។ មេធាវីនេះ ក៏មិនអាចធ្វើអន្តរាគមន៍ទៅកើតដែរ កាលណាការទទួលខុសត្រូវផ្ទាល់ខ្លួនត្រូវលេចជាបញ្ហាឡើង។

**មាត្រា ២១..** ការតាក់តែងលិខិតដោយមេធាវីរួមគ្នា

មេធាវីម្នាក់ៗ ត្រូវប្រមូលផ្តុំនូវឯកសារព័ត៌មានផ្ទាល់របស់អតិថិជនខ្លួន។ មេធាវីម្នាក់ៗ ត្រូវផ្ទៀងពិនិត្យភាពត្រឹមត្រូវ ឬ ភាពសច្ចៈនៃអត្តសញ្ញាណរបស់បុគ្គលនៃនិទ្ទេសនានា និងឯកសារនានាដែលអតិថិជនខ្លួនបានប្រគល់ឲ្យ និងហត្ថលេខាដែលខ្លួនបានឲ្យចុះ។

លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ មេធាវីដែលរ៉ាប់រងការរៀបចំលិខិតស្នាម ត្រូវចាប់ផ្តើមកិច្ចការភ្លាម និងចាប់ផ្តើមធ្វើទម្រង់ការចាំបាច់នានាសម្រាប់សុពលភាព និងប្រសិទ្ធភាព។ បន្ទាប់មក មេធាវីនេះត្រូវជូនទៅសហភាគារបស់ខ្លួននូវលិខិតស្នាមគ្រប់ច្បាប់ដែលត្រូវបញ្ជូនត្រឡប់ទៅឲ្យអតិថិជនរបស់សហភាគានេះ។

មេធាវីម្នាក់ៗត្រូវទទួលខុសត្រូវចំពោះមុខសហភាគារបស់ខ្លួន អំពីការខ្វះខ្នែង អំពីបែបបទដែលខ្លួនជាអ្នកទទួលបន្ទុកត្រូវធ្វើក្នុងផលប្រយោជន៍រួម ប៉ុន្តែក្នុងលក្ខខណ្ឌដែលខ្លួនត្រូវបានទទួលមូលនិធិចាំបាច់រួចហើយសិន។

**មាត្រា ២២..** ការទទួលរឿងក្តី

មេធាវីមានសិទ្ធិទទួលឬមិនទទួលជួយអតិថិជន លើកលែងតែត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។ មេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីផ្ទាល់ឬតតីយជន។

ប្រសិនបើយល់ព្រមទទួលយកបេសកកម្ម មេធាវីត្រូវបំពេញបេសកកម្មនោះ ដោយយកចិត្តទុកដាក់រហូតដល់ចប់បេសកកម្ម លើកលែងតែអតិថិជនឈប់ពឹងពាក់។

ប្រសិនបើយល់ព្រមទទួល មេធាវីត្រូវពន្យល់ប្រាប់អតិថិជនរបស់ខ្លួនអំពីលក្ខណនៃរឿងក្តី ជម្រើសនៃវិធីដោះស្រាយ កម្រៃសេវាមេធាវី ការចំណាយ និងកម្រៃផ្សេងៗទៀត ដោយផ្អែកលើព័ត៌មានដែលទទួលបានពីអតិថិជន។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន និងក្នុងការគោរពសេរីភាពរបស់អតិថិជន មេធាវីត្រូវស្ថិតនៅជាម្ចាស់នៃមធ្យោបាយការពារ។

មេធាវីមិនត្រូវផ្តល់នូវការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ។

**មាត្រា ២៣.-** លិខិតប្រគល់សិទ្ធិ

ក្នុងគ្រប់រឿងអ្វីក៏ដោយ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិ ឬ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬពាក្យពឹងពាក់ពីអតិថិជនរបស់ខ្លួន។

ខ្លឹមសារនៃលិខិតទាំងអស់ខាងលើនេះ ត្រូវសរសេរលំអិតអំពីសិទ្ធិនិងតួនាទីរបស់មេធាវីដែលអតិថិជនប្រគល់ឲ្យស្របតាមច្បាប់ និងគំរូដែលគណៈមេធាវីកំណត់។

**មាត្រា ២៤.-** ទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន

ការទាក់ទងជាមួយអតិថិជនត្រូវធ្វើដោយចំពោះនិងផ្ទាល់ខ្លួន។ មេធាវីមិនអាចទទួលរឿងក្តីមួយតាមរយៈតតិយជនបានឡើយ បើខ្លួនគ្មានសេរីភាពនឹងចូលទាក់ទងផ្ទាល់ខ្លួនជាមួយអតិថិជនដែលមានរឿងនោះបាន។

វិធាននេះអាចមិនត្រូវប្រតិបត្តិតាមបាន លុះត្រាណាមេធាវីដើរតួជាអ្នកឆ្លើយឆ្លងរបស់មេធាវីម្នាក់ទៀត។

**មាត្រា ២៥.-** ទំនាស់ផលប្រយោជន៍

មេធាវី មិនត្រូវទទួលរឿងក្តីទាំងឡាយដូចខាងក្រោម ៖

- រឿងក្តីមួយដែលមេធាវីខ្លួនឯង ឬ ក្រុមមេធាវីរបស់ខ្លួន បានជួយបដិភាគីនៅក្នុងការផ្តល់យោបល់ ឬបានទទួលយល់ព្រមតំណាងឲ្យបដិភាគីរួចហើយ
- នៅពេលដែលផលប្រយោជន៍របស់អតិថិជនម្នាក់ មានទំនាស់ជាមួយផលប្រយោជន៍អតិថិជនម្នាក់ទៀតនៅក្នុងរឿងក្តីដែលមេធាវី ឬ ក្រុមមេធាវីរបស់ខ្លួនកំពុងកាន់
- នៅពេលដែលអតិថិជនទាំងពីរ ជាភាគីវិវាទនៅក្នុងរឿងក្តីតែមួយ
- នៅពេលដែលអតិថិជនម្នាក់ចង់ពឹងពាក់មេធាវី ឬ ក្រុមមេធាវីរបស់ខ្លួន តែមេធាវី ឬ ក្រុមមេធាវីនេះធ្លាប់បានទទួលជួយបដិភាគីក្នុងរឿងក្តីដទៃ ឬ មេធាវីបានយល់ព្រមផ្តល់យោបល់ផ្នែកច្បាប់បន្តទៀត លើកលែងតែរឿងក្តីចុងក្រោយដែលមេធាវី ឬ ក្រុមមេធាវីដែលធ្លាប់ពាក់ព័ន្ធនោះ បានកន្លងផុតទៅអស់រយៈពេល២(ពីរ)ឆ្នាំ
- រឿងក្តីមួយដែលមេធាវី ឬ ក្រុមមេធាវីរបស់ខ្លួនបានដើរតួជាអាជ្ញាកណ្តាល អ្នកផ្សះផ្សា ឬ អ្នកសម្របសម្រួល ក្នុងទម្រង់នីតិវិធីនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។

ករណីដែលមេធាវី ឬ ក្រុមមេធាវី ជាទីប្រឹក្សា ឬ ធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបាន លុះត្រាតែត្រូវជម្រាបទៅភាគីឯទៀត និងបន្ទាប់ពីទទួលបានការយល់ព្រមសិន ហើយត្រូវប្រុងប្រយ័ត្នកុំឲ្យបាត់បង់នូវភាពថ្លៃថ្នូរ កិត្តិយស និងការសម្ងាត់វិជ្ជាជីវៈ។

**មាត្រា ២៦..** អតិថិជនជាប់ឃុំ

មេធាវី មិនត្រូវផ្តល់មធ្យោបាយ ឬ វត្ថុផ្សេងៗ ដែលច្បាប់ហាមឃាត់ទៅអតិថិជនដែលកំពុងជាប់ឃុំ។

**មាត្រា ២៧..** កម្រៃមេធាវី

កម្រៃសេវាកម្មមេធាវី គឺជាកម្មវត្ថុនៃការព្រមព្រៀងគ្នា រវាងមេធាវីនិងអតិថិជន។

ជាទូទៅ មេធាវីមិនត្រូវបែងចែកកម្រៃសេវាទៅឲ្យមេធាវីផ្សេងទៀតឡើយ លើកលែងតែករណីដូចខាងក្រោម៖

- មេធាវីជាដៃគូនៅក្នុងការិយាល័យ ឬ ក្រុមមេធាវីជាមួយគ្នា
- មេធាវីដទៃទៀតដែលមិននៅក្នុងការិយាល័យ ឬ ក្រុមមេធាវីជាមួយគ្នា តែមានការទទួលខុសត្រូវរួមគ្នាចំពោះរឿងក្តី ការបែងចែកត្រូវធ្វើទៅតាមសមាមាត្រទៅនឹងសេវាដែលបំពេញដោយមេធាវីនីមួយៗ ឬ តាមចំនួនសមាមាត្រផ្សេងទៀត តាមការព្រមព្រៀង ។

**មាត្រា ២៨..** វិវាទជាមួយអតិថិជន

មេធាវីត្រូវព្យាយាមរក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងព្យាយាមបញ្ចៀសជម្លោះជាមួយអតិថិជន។ ប្រសិនបើមានទំនាស់ជាមួយអតិថិជន មេធាវីត្រូវព្យាយាមដោះស្រាយទំនាស់នោះដោយសន្តិវិធីតាមរយៈការសម្រុះសម្រួលដោយស្ថាប័នគណៈមេធាវី។

**មាត្រា ២៩..** ការប្រកែក និងការបោះបង់ចោលបេសកកម្ម

មេធាវីត្រូវប្រកែកមិនព្រមទទួលយកបេសកកម្មទាំងឡាយណា ឬ អំពើទាំងឡាយណាដែលផ្ទុយពីវិធានវិជ្ជាជីវៈនិងសម្បជញ្ញៈរបស់ខ្លួន។

មេធាវីមិនត្រូវតំណាង ឬ ការពារ ឬ ត្រូវបញ្ឈប់ការតំណាង ឬ ការពារអតិថិជន បើការតំណាង ឬ ការការពារបានចាប់ផ្តើមរួចហើយ នៅក្នុងករណីដូចខាងក្រោម៖

- ការតំណាង ឬ ការការពារនោះ នឹងក្លាយជាលទ្ធផលនៃការរំលោភលើវិធានវិជ្ជាជីវៈ ឬ ច្បាប់ផ្សេងទៀត
- ស្ថានភាពរាងកាយ ឬ ស្មារតីរបស់មេធាវីធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៅក្នុងការតំណាង ការពាររឿងក្តី
- មេធាវីដែលត្រូវបានហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈ ឬលុបឈ្មោះចេញពីបញ្ជីគណៈមេធាវីដោយទណ្ឌកម្មវិន័យ។

ដោយសារបុព្វហេតុដែលចេញពីសម្បជញ្ញៈរបស់ខ្លួន មេធាវីអាចសម្រេចបញ្ឈប់បេសកកម្មរបស់ខ្លួនប្រសិនបើមានមូលហេតុដូចខាងក្រោម៖

- អតិថិជន បន្តប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ អំពើទុច្ចរិត
- អតិថិជន បានប្រើប្រាស់សេវាកម្មរបស់មេធាវី ដើម្បីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ អំពើទុច្ចរិត
- គោលបំណងរបស់អតិថិជនមិនអាចទទួលយកបាន ឬ ផ្ទុយពីជំនឿរបស់មេធាវី
- អតិថិជន មិនសហការជាមួយមេធាវី
- អតិថិជន ខកខានមិនបានបំពេញកាតព្វកិច្ចចំពោះមេធាវី ទាក់ទងនឹងសេវាកម្មរបស់មេធាវី និង បន្ទាប់ពីបានជូនដំណឹងដ៏សមស្របថា មេធាវីនឹងបញ្ឈប់បេសកកម្មរបស់ខ្លួន លុះត្រាតែកាតព្វកិច្ចបានបំពេញ
- មានមូលហេតុសមស្របផ្សេងទៀត សម្រាប់ការបញ្ឈប់បេសកកម្ម។

មុនពេលបញ្ឈប់បេសកកម្មរបស់ខ្លួន មេធាវីត្រូវតែជូនដំណឹងទៅអតិថិជនអំពីការបញ្ឈប់ ឬការដកខ្លួននេះ ក្នុងពេលវេលាមួយសមស្របដែលផ្តល់លទ្ធភាពឲ្យអតិថិជននេះ អាចបង្ការផលប្រយោជន៍របស់ខ្លួនបាន និងស្វែងរកមេធាវីផ្សេងទៀត។

មេធាវីត្រូវដឹងឲ្យច្បាស់ថា បេសកកម្មនោះ ស្ថិតនៅក្នុងក្របខ័ណ្ឌធានារ៉ាប់រងពីក្រុមហ៊ុន ដែលធានារ៉ាប់រងចំពោះខ្លួន។

**មាត្រា ៣០..** ការបញ្ឈប់បេសកកម្មមេធាវីដោយអតិថិជន

អតិថិជនអាចបញ្ឈប់បេសកកម្មរបស់មេធាវីនៅពេលណាក៏បាន ដោយមាន ឬ គ្មានមូលហេតុ។ ប៉ុន្តែ អតិថិជនត្រូវទទួលខុសត្រូវបង់កម្រៃសេវាកម្មមេធាវីដែលបានព្រមព្រៀង។

**មាត្រា ៣១..** ករណីយកិច្ចរបស់មេធាវី ក្រោយការបញ្ឈប់និងការបញ្ចប់បេសកកម្ម

លើកលែងតែមានការហាមឃាត់ដោយច្បាប់និងវិធានវិជ្ជាជីវៈ មេធាវីត្រូវៈ

- ប្រគល់ទៅឲ្យអតិថិជនតាមការស្នើសុំរបស់គេ នូវបញ្ជីស្រង់ប្រាក់ដែលមេធាវីបានចេញជំនួសចំណាយផ្សេងៗ និងប្រាក់កម្រៃមេធាវី។
- ប្រគល់ឲ្យភាគីហត្ថលេខីនីមួយៗនូវលិខិតដើម ព្រមទាំងឯកសារទាំងអស់ ដែលបញ្ជាក់អំពីការបានបំពេញបែបបទគ្រប់សព្វ បើបេសកកម្មនោះជាការតាក់តែងលិខិតស្នាម។
- ប្រគល់ត្រឡប់ទៅឲ្យអតិថិជនវិញ នូវឯកសារទាំងអស់ដែលខ្លួនបានទទួលទុកដោយគ្មានសិទ្ធិរក្សាទុកអ្វីទាំងអស់។

ការប្រគល់ឯកសារខាងលើនេះ ត្រូវមានបញ្ជីរាយឈ្មោះឯកសារ និងមានហត្ថលេខាឬស្នាមមេដៃប្រគល់-ទទួលត្រឹមត្រូវ។

## ជំពូកទី៥
## ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី

**មាត្រា ៣២..** ភាគីដែលមានជំនួយពីមេធាវី

មេធាវីអាចទាក់ទងជាមួយភាគីម្ខាងទៀតដែលខ្លួនដឹងថាមានមេធាវីជួយ លុះត្រាតែការទាក់ទងនោះធ្វើនៅចំពោះមុខមេធាវីរបស់ភាគីម្ខាងទៀតឬទាល់តែមានការយល់ព្រមពីមេធាវីនោះ។

លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ រាល់ការជួបប្រជុំត្រូវធ្វើនៅចំពោះមុខភាគីទាំងអស់ និងមេធាវីរបស់ពួកគេ។

**មាត្រា ៣៣.** ភាគីដែលគ្មានជំនួយពីមេធាវី

មុនធ្វើសកម្មភាពបណ្តឹង មេធាវីដោយមានការយល់ព្រមពីអតិថិជនរបស់ខ្លួនផង អាចទាក់ទងជាមួយភាគីម្ខាងទៀត ដើម្បីរកការដោះស្រាយដោយសម្រុះសម្រួលគ្នា។

ក្នុងឱកាសនោះ មេធាវីមិនត្រូវធ្វើការកៀបសង្កត់ បង្ខិតបង្ខំ ឬ បញ្ឆោះបញ្ឆូល ឲ្យភាគីម្ខាងទៀតយល់ខុស ដើម្បីសម្រេចនូវគោលដៅរបស់ខ្លួននោះទេ។

មុននឹងពិភាក្សាគ្នា មេធាវីត្រូវរំលឹកទៅភាគីម្ខាងទៀត អំពីសិទ្ធិរបស់គេដែលត្រូវមានជំនួយពីមេធាវី។

**មាត្រា ៣៤.** ការទាញយកឬការផ្តល់ផលប្រយោជន៍ដល់ភាគីម្ខាងទៀត

មេធាវីមិនត្រូវទាញយក ឬ ផ្តល់ផលប្រយោជន៍ ឬ ទទួលយកពិធីកំសាន្តពីសំណាក់ភាគីម្ខាងទៀត នៅក្នុងទំនាក់ទំនងនៃរឿងក្តីឡើយ ប្រសិនបើអំពើនេះ ធ្វើឲ្យមានឥទ្ធិពលដល់រឿងក្តីដែលកំពុងដំណើរការ។

**មាត្រា ៣៥.** តតិយជននិងសាក្សី

ក្នុងក្របខ័ណ្ឌសាលាជម្រះក្តីណាមួយ និងគ្រប់ករណី ឬ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងវិធាននីតិវិធី មេធាវីអាចចូលទំនាក់ទំនងជាមួយនឹងតតិយជន ដើម្បីសុំឲ្យផ្តល់ដោយស្រុះស្រួលគ្នានូវឯកសារដែលគេមាន។ បើសុំមិនបានទេ មេធាវីអាចឲ្យចៅក្រមទាមទារឲ្យខ្លួនបាន។

មេធាវី ត្រូវហាមឃាត់ប្រើឥទ្ធិពលតាមវិធីណាមួយក៏ដោយ លើសាក្សីនិង/ឬជនដែលអាចជាសាក្សី ដែលនាំឱ្យប៉ះពាល់ដល់សក្ខីកម្មរបស់ជននោះជាដាច់ខាត។

**មាត្រា ៣៦.** ការល្បួងឲ្យភូតភរតុលាការ

មេធាវី ជាដាច់ខាតមិនត្រូវល្បួងសាក្សីឲ្យប្រព្រឹត្តអំពើភូតភរ ឬ ក្លែងសក្ខីកម្ម ព្រមទាំងមិនត្រូវដាក់ភស្តុតាងក្លែងជូនដល់តុលាការឡើយ។

## ជំពូកទី ៦
## ទំនាក់ទំនងជាមួយតុលាការ

**មាត្រា ៣៧.** ទំនាក់ទំនងជាមួយចៅក្រម

មេធាវីត្រូវណែនាំខ្លួនជូនចៅក្រម ចំពោះរឿងក្តីដែលខ្លួនការពារឬតំណាងដោយអាណត្តិ។

មេធាវីត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវឯករាជ្យភាពនិងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈ នៅចំពោះមុខតុលាការ។

មេធាវីត្រូវគោរពតាមវិធាននីតិវិធីនិងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។ មេធាវីមានសិទ្ធិសំដែងឡើងនូវអ្វីៗដែលខ្លួនយល់ថា មានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។

មេធាវីត្រូវរួចផុតពីការចោទប្រកាន់ក្នុងបទព្រហ្មទណ្ឌនិងការទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះសេចក្ដីថ្លែងការណ៍ឬសារណា ទោះធ្វើជាលាយលក្ខណ៍អក្សរក្ដី ជាផ្ទាល់មាត់ក្ដី ក្នុងបំណងសុចរិតដើម្បីការពារនៅចំពោះមុខតុលាការ សាលាជម្រះក្ដី ឬ អាជ្ញាធរផ្សេងៗទៀត។

ក្នុងករណីមានទំនាស់ជាមួយចៅក្រមពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍ឬសារណា មេធាវីត្រូវសុំអន្តរាគមន៍ពីប្រធានគណៈមេធាវីភ្លាម។

**មាត្រា ៣៨..** ការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងគោរពតាមនីតិវិធីដ៏ត្រឹមត្រូវ

មេធាវីត្រូវទាមទារ និងស្វះស្វែងធ្វើឲ្យមានការជំនុំជម្រះក្ដីដោយយុត្តិធម៌ គោរពតាមច្បាប់ និងនីតិវិធីដ៏ត្រឹមត្រូវឲ្យកើតមានយ៉ាងពិតប្រាកដ។

**មាត្រា ៣៩..** ការពន្យារនៅក្នុងនីតិវិធីតុលាការ

មេធាវីមិនត្រូវបង្កឲ្យមានការពន្យារនីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬ មូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ។

**មាត្រា ៤០..** ការទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបុគ្គលសាធារណៈ

មេធាវីមិនត្រូវប្រើប្រាស់ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយចៅក្រម ព្រះរាជអាជ្ញា មន្ត្រីរាជការ ឬ បុគ្គលមានអំណាចផ្សេងទៀត មកពាក់ព័ន្ធនៅក្នុងនីតិវិធីតុលាការក្នុងការដោះស្រាយរឿងក្ដីនោះទេ។

មេធាវីមិនត្រូវជួយដោយផ្ទាល់ឬដោយប្រយោលដល់ចៅក្រមក្នុងការប្រព្រឹត្តអំពើខុសច្បាប់ នៃព្រះរាជាណាចក្រកម្ពុជាឡើយ។

## ជំពូកទី៧
## ទំនាក់ទំនងជាមួយសហភាគា និង សមាជិកនៃវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា

**មាត្រា ៤១..** វិធានទូទៅនិងវិធានផ្សេងៗ

គ្រប់ទំនាក់ទំនងរវាងសហភាគា មេធាវីត្រូវប្រព្រឹត្តដោយសេចក្ដីថ្លៃថ្នូរ សម្បជញ្ញៈ សេចក្ដីទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យ ទេពកោសល្យប៉ិនប្រសប់ គួរសមជានិច្ច និងដោយគោរពវិធានវិជ្ជាជីវៈរបស់ខ្លួន។

ក្នុងការគោរពផលប្រយោជន៍អតិថិជនរបស់ខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនឹងនាំឲ្យខូចខាតដល់សហភាគាខ្លួនឡើយ។

មេធាវីត្រូវជូនដំណឹងជាមុនតាមគ្រប់មធ្យោបាយ ដល់សហភាគានៃភាគីម្ខាងទៀត អំពីការសុំពន្យាពេលក្នុងនីតិវិធីណាមួយ ឬ ការធ្វើបណ្ដឹងឧបាស្រ័យ ព្រមទាំងការចាប់ផ្ដើមធ្វើនីតិវិធីថ្មីណាមួយ លើកលែងតែមានការចាំបាច់ក្នុងការការពារផលប្រយោជន៍ចម្បងរបស់អតិថិជន។

មេធាវីត្រូវជូនដំណឹង បង្កលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងនានា ដល់សហភាគាដោយគ្មានការយឺតយ៉ាវ។

ការប្រជុំនិងការណាត់ជួបគ្នា ត្រូវកំណត់ដោយការព្រមព្រៀងជាមួយគ្នា ឲ្យសមស្រប និងអធ្យាស្រ័យរៀងៗខ្លួន។ ជាធម្មតា ការប្រជុំនិងការណាត់ជួបគ្នានេះ ត្រូវមកកន្លែងការិយាល័យរបស់មេធាវីដែលមានអតីតភាពច្រើនជាង។

លំដាប់ថ្នាក់ហៅចូលសវនាការ ត្រូវចាត់ឡើងដោយស្មើភាពគ្នាទាំងអស់រវាងសហភាគា លើកលែងតែប្រធានគណៈមេធាវីដែលត្រូវតែហៅមុនគេ។

ទំនាស់សព្វយ៉ាងរវាងសហភាគា ត្រូវដោះស្រាយតាមការចរចារដោយសន្តិវិធីឬដោយប្រធានគណៈមេធាវី។

**មាត្រា ៤២..** ការប្តឹងទៅស្ថាប័នយុត្តាធិការ

មុននឹងមេធាវីណាម្នាក់ ឬ ច្រើននាក់ ចាប់ផ្តើមធ្វើសកម្មភាពបណ្តឹងទៅស្ថាប័នយុត្តាធិការណាមួយ ពីមេធាវីណាម្នាក់ ឬ ច្រើននាក់ មេធាវីនោះត្រូវតែជូនដំណឹងជាមុនទៅប្រធានគណៈមេធាវី។

វិវាទទាំងឡាយដែលកើតឡើងរវាងសហភាគា ក្រៅតែអំពីការអនុវត្តន៍នៃវិធាននីតិវិធីតុលាការ ត្រូវស្នើសុំឡើងទៅរកការសម្រុះសម្រួលដោយប្រធានគណៈមេធាវី។

មុននឹងមេធាវីណាម្នាក់ ឬ ច្រើននាក់ចាប់ផ្តើមធ្វើសកម្មភាពបណ្តឹង ពីសមាជិកណាម្នាក់ ឬ ច្រើននាក់នៃវិជ្ជាជីវៈគតិយុត្តផ្សេងទៀត ឬ តុលាការណាមួយ មេធាវីនោះត្រូវជូនដំណឹងជាមុនដល់ប្រធានគណៈមេធាវី។

**មាត្រា ៤៣..** សំបុត្រឆ្លងឆ្លើយរវាងសហភាគា

ក- ការឆ្លងឆ្លើយតាមលិខិត ឬ តាមសំដីរវាងមេធាវី និងមេធាវីធម្មតាត្រូវជាការសម្ងាត់។

ទោះក្នុងប្រការណាក៏ដោយ ការឆ្លងឆ្លើយនេះមិនអាចរំលឹកអួស ឬ មិនអាចបង្ហាញជាសក្ខីកម្មក្នុងតុលាការ និងមិនអាចទុកជាកម្មវត្ថុនៃការលើកភាពសម្ងាត់ចេញបានឡើយ។

ខ- មិនមែនជាការសម្ងាត់៖

- សំបុត្រ ឬ សារអេឡិចត្រូនិកដែលជំនួសលិខិតនីតិវិធី
- សំបុត្រ ឬ សារអេឡិចត្រូនិកដែលមានដាក់ថា "ផ្លូវការ" ហើយដែលបញ្ជូនសេចក្តីស្នើណាមួយ ឬ ឯកសារមិនសម្ងាត់នានាមក
- ការប្តូរសំបុត្រ ឬ ការឆ្លើយឆ្លងគ្នាទៅវិញទៅមក តាមរយៈសារអេឡិចត្រូនិក ដែលមានដាក់ថា "ផ្លូវការ" ដើម្បីបង្ហាញបញ្ជាក់កិច្ចព្រមព្រៀងណាមួយ ឬ ការចុះហត្ថលេខានៃកិច្ចព្រមព្រៀងណាមួយរវាងមេធាវី និងមេធាវី ក្នុងកម្រិតលក្ខខណ្ឌនៃអាណត្តិរបស់ខ្លួន។

សំបុត្រ សារអេឡិចត្រូនិក និងឯកសារទាំងនេះ មិនត្រូវមានយោងទៅលើការប្តូរសំបុត្រគ្នាទៅវិញទៅមក ឬ ក៏ការប្រាស្រ័យគ្នាពីលើកមុនដែលមានលក្ខណៈជាសម្ងាត់នោះឡើយ។

គ. ក្នុងករណីដែលមានការបំពានលើវិធានទាំងឡាយដូចមានចែងក្នុងចំណុច (ក)និង(ខ) នៃមាត្រានេះ ប្រធានគណៈមេធាវីត្រូវធានាអាំប់រងឲ្យមានការគោរពនូវគោលការណ៍សំខាន់ៗនៃវិជ្ជាជីវៈមេធាវីតាមក្រមសីលធម៌។

ឃ. ក្នុងការទំនាក់ទំនងជាមួយមេធាវីបរទេសណាមួយ មេធាវីមុននឹងប្តូរព័ត៌មានសម្ងាត់គ្នាទៅវិញទៅមក ត្រូវដឹងឲ្យច្បាស់អំពីភាពវិជ្ជមាននៃវិធានក្នុងការរក្សាការសម្ងាត់នៃការឆ្លងឆ្លើយនៅក្នុងប្រទេស ដែលមានមេធាវីបរទេសប្រកបមុខការ។ នៅក្នុងករណីអវិជ្ជមានវិញ មេធាវីត្រូវសួរអតិថិជនរបស់ខ្លួនថាតើ គាត់យល់ព្រមហ៊ានប្រថុយឲ្យការសម្ងាត់នៃការឆ្លងឆ្លើយប្តូរព័ត៌មាននោះ ឬ អត់។

**មាត្រា ៤៤..** ទំនាក់ទំនងដែលត្រូវហាមឃាត់

មេធាវីត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះការរំលោភបំពានវិធានវិជ្ជាជីវៈនូវអំពើដូចខាងក្រោម៖

- មានចេតនាបំពានវិធានវិជ្ជាជីវៈ
- ជួយសហការ ផ្តល់មធ្យោបាយ ឬ សម្រួលដល់មេធាវីបរទេស ឬ បុគ្គលដទៃទៀត ឲ្យរំលោភបំពានវិធានវិជ្ជាជីវៈ
- ប្រើប្រាស់ទំនាក់ទំនងជាមួយមេធាវីបរទេស ឬ បុគ្គលដទៃទៀត ដើម្បីរំលោភបំពានវិធានវិជ្ជាជីវៈ
- ចូលរួមបង្កើត និងសហការជាមួយនឹងរូបវន្តបុគ្គល ឬ នីតិបុគ្គល ឬ មេធាវីបរទេសដែលមិនមែនជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកការិយាល័យមេធាវី ឬ ក្រុមហ៊ុនមេធាវី ឬ ប្រកបវិជ្ជាជីវៈមេធាវីយកកម្រៃ។

**មាត្រា ៤៥..** ការប្តូរមេធាវីនិងការបន្ថែមមេធាវី

មុននឹងទទួលយកបេសកកម្មពីអតិថិជនណាមួយ មេធាវីត្រូវតែពិនិត្យផ្ទៀងផ្ទាត់ឲ្យឃើញថា គ្មានសហភាតាណាមួយបានទទួលយកបេសកកម្មនោះមុនខ្លួនទេ។

មេធាវីដែលទទួលបេសកកម្មបន្តពីសហភាតាណាម្នាក់ ឬ ទទួលធ្វើអន្តរាគមន៍អមសហភាតាមុន ត្រូវជូនដំណឹងដល់សហភាតានោះឲ្យបានដឹងមុន ហើយសួរអំពីប្រាក់សោហ៊ុយ និងប្រាក់កម្រៃដែលគេត្រូវបាន។ ក្នុងករណីមិនទាន់បានទូទាត់ប្រាក់សេវាជាមួយមេធាវីមុនទេ មេធាវីក្រោយមិនអាចទទួលយកបេសកកម្មបន្តនេះបានទេ លើកលែងតែមានការយល់ព្រមពីសហភាតាមុន ឬ មានសេចក្តីសម្រេចផ្សេងពីនេះដោយប្រធានគណៈមេធាវី។

មេធាវីដែលត្រូវគេឲ្យឈប់ធ្វើរឿងក្តីនោះ ត្រូវឆ្លើយតបយ៉ាងរហ័ស និងបញ្ជូនមកនូវអ្វីៗទាំងអស់របស់សំណុំរឿង ទៅឲ្យមេធាវីដែលទទួលបេសកកម្មបន្ត ដែលខ្លួនគ្មានសិទ្ធិអ្វីនឹងខាឃាំងទុកតទៅទៀតឡើយ។

ករណីមានវិវាទលើកម្រៃ ត្រូវប្តឹងទៅប្រធានគណៈមេធាវី ហើយប្រធានគណៈមេធាវីអាចសុំយកប្រាក់កម្រៃនោះតម្កល់ទុកសិន។

មេធាវីដែលបន្ត ត្រូវជូនដំណឹងអំពីអន្តរាគមន៍របស់ខ្លួនទៅមេធាវីនៃភាគីម្ខាងទៀត ឬ ជាយថាហេតុទៅយុត្តាធិការដែលទទួលបណ្តឹង។

បើមេធាវីដែលគេមកពឹងពាក់ មិនទាន់ចង់ឆ្លើយព្រមទទួលរឿងក្តីភ្លាម មេធាវីនោះ ត្រូវសរសេរទៅប្រាប់សហភាតា ដោយសុំឲ្យផ្ញើសំណុំរឿងមកពិនិត្យ ដោយមានការយល់ព្រមពីអតិថិជន។ មេធាវីនោះត្រូវតែឆ្លើយប្រាប់អំពីជំហររបស់គាត់ក្នុងអំឡុងពេលយ៉ាងយូរ១ខែ។ ផុតពីនេះ ត្រូវចាត់ទុកថា គាត់មិនយល់ព្រមទទួលឡើយ ហើយត្រូវបង្វិលសំណុំរឿងនោះទៅឲ្យម្ចាស់ដើមវិញ។

រហូតមកដល់ពេលមានការជូនដំណឹងពីការយល់ព្រមទទួលរបស់មេធាវីក្រោយ មេធាវីមុននៅតែពុំទាន់ផុតភារកិច្ចនៅឡើយ។ មេធាវីក្រោយមិនត្រូវទាន់ធ្វើការខ្វះខ្នែងអ្វីទេ ក្រៅអំពីពិនិត្យសំណុំរឿង និងការទទួល ឬ ទៅជួបអតិថិជនប៉ុណ្ណោះ។

ការបំពេញកិច្ចការអ្វីមួយជាផ្លូវវិជ្ជាជីវៈ មានន័យថាសុខចិត្តព្រមទទួលធ្វើ។

**មាត្រា ៤៦..** មេធាវីដែលទទួលធ្វើជាអ្នកឆ្លើយឆ្លង

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយរបស់សហភាតាណាមួយ ត្រូវទទួលខុសត្រូវចំពោះសហភាតា និងចំពោះអតិថិជន អំពីការធ្វើឲ្យបានចប់សព្វគ្រប់នូវបេសកកម្មរបស់ខ្លួន តាមការព្រមព្រៀងជាមួយមេធាវីដើម បើសិនជាខ្លួនបានទទួលឯកសារជាចាំបាច់ទាំងអស់នៃសំណុំរឿង។

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយ អាចជួបផ្ទាល់ជាមួយអតិថិជនបាន លុះត្រាតែមានការយល់ព្រមពីមេធាវីដើម ឬ លើកលែងតែមានការចាំបាច់។

មេធាវីដែលទទួលធ្វើជាអ្នកឆ្លងឆ្លើយ ធ្វើពាក្យសុំប្រាក់បម្រុង និងប្រាក់កម្រៃ តាមរយៈសហភាតារបស់ខ្លួនដែលត្រូវសម្រេចយល់ព្រមផង។

មេធាវីដើមត្រូវទទួលខុសត្រូវចំពោះសហភាតានេះនូវការចេញសោហ៊ុយ បរិលាភ និងកម្រៃនានាក្នុងលក្ខខណ្ឌដែលមានសំអាងពិតប្រាកដ។

**មាត្រា ៤៧..** មេធាវីដែលជាអនុតំណាង

មេធាវីដែលទទួលបេសកកម្មពីអតិថិជនអាចផ្ទេរបេសកកម្មនោះទាំងស្រុង ឬ មួយភាគទៅឲ្យសហភាតាណាមួយធ្វើជាអនុតំណាងបាន លុះត្រាតែការប្រគល់សិទ្ធិរបស់អតិថិជនផ្តល់ឲ្យមេធាវីដើម មានសិទ្ធិជ្រើសតាំងអនុតំណាងរបស់ខ្លួន។ មេធាវីអនុតំណាងត្រូវបំពេញបេសកកម្មឲ្យដូចជាមេធាវីដើមដែរ។

**មាត្រា ៤៨..** ក្រុមមេធាវី

មេធាវីអាចប្រកបវិជ្ជាជីវៈក្នុងក្របខ័ណ្ឌជាក្រុមមេធាវីដែលប្រមូលផ្តុំមេធាវីច្រើន។

មេធាវីជាសហការីបំពេញកិច្ចការផ្សេងៗក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់សហភាតា ដែលជាប្រធានក្រុមតាមកិច្ចសន្យានៃកិច្ចសហការ។

ក្នុងករណីសមាជិកនៃក្រុមមេធាវីទទួលបេសកកម្មក្នុងនាមខ្លួនផ្ទាល់ក្រៅពីក្រុម មេធាវីនោះត្រូវតែទទួលខុសត្រូវជាមួយអតិថិជនដោយខ្លួនឯង តែបេសកកម្មនោះមិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយក្រុមខ្លួនទេ។

**មាត្រា ៤៩..** ការចូលរួមក្នុងកិច្ចប្រជុំ ឬ សន្និបាត

មេធាវីដែលនឹងចូលរួមក្នុងកិច្ចប្រជុំណាមួយ ទោះជារឿងវិវាទ ឬ គ្មានវិវាទ ត្រូវឲ្យដំណឹងជាមុនទៅអ្នកចូលរួមដទៃទៀតដោយផ្ទាល់ខ្លួនតែម្តង ឬ តាមរយៈអតិថិជនរបស់ខ្លួន។

## ជំពូកទី៨
## ទំនាក់ទំនងជាមួយគណៈមេធាវី

**មាត្រា ៥០..** វិធានទូទៅ

មេធាវីជាសមាជិកនៃគណៈមេធាវី។

គណៈមេធាវីមានសេវាជូនមេធាវី ជួយជ្រោមជ្រែងមេធាវី និងការពារមេធាវី។

គណៈមេធាវីតំណាងឲ្យមេធាវី គ្រប់គ្រងកិច្ចការរួមនៃគណៈមេធាវី ជាពិសេស ការការពារក្ដី និងការចូលទៅតុលាការ។

ដោយអាកប្បកិរិយារបស់ខ្លួន មេធាវីម្នាក់ៗ ត្រូវមានស្មារតីទទួលខុសត្រូវចំពោះ៖

- កេរ្តិ៍ឈ្មោះរបស់គណៈមេធាវី
- ឫទ្ធិអំណាចរបស់ប្រធានគណៈមេធាវី និង
- ប្រសិទ្ធផលនៃក្រុមប្រឹក្សាគណៈមេធាវី។

**មាត្រា ៥១**.. ការសង្កេតទៅលើការអនុវត្តបទប្បញ្ញត្តិនានា

មេធាវីត្រូវចូលរួមសង្កេតអំពីប្រសិទ្ធភាពលើការអនុវត្តន៍បទប្បញ្ញត្តិនានារបស់គណៈមេធាវី មានជាអាទិ៍ វិធានវិជ្ជាជីវៈ រាល់សេចក្ដីសម្រេចផ្សេងៗរបស់គណៈមេធាវី ព្រមទាំងបទប្បញ្ញត្តិដទៃទៀតដែលកំពុងមានជាធរមាន ដើម្បីលើកជាមតិជូនគណៈមេធាវី។

**មាត្រា ៥២**.. បេសកកម្មប្រគល់ឲ្យដោយគណៈមេធាវី

មេធាវីត្រូវទទួលរ៉ាប់រងដោយរៀសរវៃ និងហ្មត់ចត់នូវបេសកកម្ម និងសេវារួម ព្រមទាំងការការពារក្ដីជូនជនក្រីក្រដែលបានប្រគល់ឲ្យដោយគណៈមេធាវី ដោយមិនយកកម្រៃ។ មេធាវីមិនអាចប្រកែកមិនទទួលការងារទាំងឡាយណាដែលគណៈមេធាវីបានប្រគល់ឲ្យដោយគ្មានមូលហេតុសមស្របឡើយ។

**មាត្រា ៥៣**.. ករណីយកិច្ចត្រូវឆ្លើយតបទៅប្រធានគណៈមេធាវី

មេធាវីត្រូវឆ្លើយតបចំពោះការសុំ ឬ អធិបញ្ញាទាំងឡាយរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវីដោយគ្មានបង្អែរបង្អង់។

**មាត្រា ៥៤**.. មេធាវីដែលត្រូវគេប្ដឹង

មេធាវីដែលត្រូវគេប្ដឹងអំពីកំហុស ឬ បទល្មើសព្រហ្មទណ្ឌណាមួយ ដែលទាក់ទិននឹងការប្រកបវិជ្ជាជីវៈ ឬ ដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈត្រូវជូនដំណឹងភ្លាមទៅគណៈមេធាវី។

មេធាវីដែលត្រូវគេប្ដឹងពីបទល្មើសព្រហ្មទណ្ឌណាមួយ ក្រៅពីការប្រកបវិជ្ជាជីវៈអាចជូនដំណឹងដល់គណៈមេធាវី។

**មាត្រា ៥៥**.. ការបង់ភាគទាន

មេធាវីត្រូវបង់ភាគទានប្រចាំត្រីមាសជូនដល់គណៈមេធាវីសម្រាប់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

ភាគទានត្រូវតែបង់ឲ្យទាន់ពេលវេលាដែលបានកំណត់។

សមាជិកនៃគណៈមេធាវីដែលមិនបានបង់ភាគទានត្រូវទទួលទណ្ឌកម្មជាបទវិន័យតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

**មាត្រា ៥៦..** និរាករណ៍

ក្រមសីលធម៌មេធាវីដែលក្រុមប្រឹក្សាគណៈមេធាវីបានអនុម័ត នាសម័យប្រជុំថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥៧..** ការអនុវត្ត

ក្រមសីលធម៌មេធាវីនេះ ត្រូវដាក់ឲ្យអនុវត្តចាប់ពីថ្ងៃផុតបណ្ដឹងឧទ្ធរណ៍។

---

ក្រមសីលធម៌នេះត្រូវបានក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនាសម័យប្រជុំ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ក្រោមអធិបតីភាពរបស់លោកមេធាវី **ជីវ សុងហាក់** ប្រធានគណៈមេធាវី អាណត្តិទី ៨។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១២

**ប្រធានគណៈមេធាវី**

ជីវ_សុងហាក់

**ឧបសម្ព័ន្ធ៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចផ្ទេររឿងក្តី

យើង .....ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លេខ:..............

**-បានឃើញ** ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**-បានឃើញ** សំណុំរឿងរក្សាការពារលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០... របស់សាលាដំបូងរាជធានី ភ្នំពេញ ដែលមាន៖

**-សហដើមចោទ៖**

១. ឈ្មោះ ... ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន សព្វថ្ងៃនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២. ឈ្មោះ ... ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន សព្វថ្ងៃនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៣. ឈ្មោះ ... ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន សព្វថ្ងៃនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៤. ឈ្មោះ ... ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន សព្វថ្ងៃនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៥. ឈ្មោះ ... ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន សព្វថ្ងៃនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**-ចុងចម្លើយ៖**

ឈ្មោះ ... ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ... ផ្លូវលេខ ៤៣០ សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កម្មវត្ថុ៖** សំណើសុំ .... មេត្តាចេញដីកាសម្រេចរក្សាការពារ មានខ្លឹមសារនៃសេចក្តីសម្រេច ហាមឃាត់កូនបំណុល ឈ្មោះ ... និង **តតិយជន** មិនឱ្យ លក់ ដូរ ជួល បញ្ចាំ ផ្ទេរ សិទ្ធិ ធ្វើអំណោយ ធ្វើអច្ច័យទាន ធ្វើមតកសាសន៍ ឬ ធ្វើការអ្វី លើក្បាលដីលេខ ... មានទំហំដី ... ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹង ... ខាងត្បូងទល់នឹង... ខាងកើត

ទល់នឹង ... និង ខាងលិចទល់នឹង... មានទីតាំងស្ថិតនៅ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: .... ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយ កម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់សំណុំរឿងអង្គសេចក្តីចប់ជាស្ថាពរសិន។

## សំអាងហេតុ

១.សំណុំរឿងរក្សាការពារលេខ ... ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ លោកចៅក្រមទទួលបន្ទុកធ្លាប់បានសម្រេចសេចក្តី និងចេញដីកាសម្រេចលើកចោលពាក្យសុំដីកាសម្រេចលេខ... ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ម្តងរួចទៅហើយ ហេតុនេះដើម្បីការពារនូវផលប្រយោជន៍របស់សហដើមចោទ គប្បីផ្ទេរសំណុំរឿងរក្សាការពារខាងលើ ជូនទៅចៅក្រមផ្សេងទៀតដើម្បីចាត់ការតាមនីតិវិធី។

២.ដូចនេះដើម្បីជៀសវាងនូវភាពអស់ជំនឿទុកចិត្តរបស់សហដើមបណ្តឹង គប្បីផ្ទេរសំណុំរឿងរក្សាការពារលេខ... ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ជូនលោកចៅក្រមផ្សេងទៀត ដើម្បីចាត់ការបន្ត។

## ហេតុដូច្នេះសម្រេច

១.ផ្ទេរសំណុំរឿងរក្សាការពារលេខ... ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ជូនចំពោះ ដើម្បីចាត់តាំងចៅក្រមផ្សេងចាត់ការបន្តតាមនីតិវិធី។

២.លោកក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងរក្សាការពារលេខ... ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ត្រូវរៀបចំ បញ្ជូនសំណុំរឿងនេះ ទៅលេខាធិការដ្ឋានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។

ថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

# ឧបសម្ព័ន្ធ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ...១៩៧...... "ច" អ.រ

ចុះថ្ងៃទី២៧ខែឧសភា ឆ្នាំ២០២២

## ដីកាសម្រេចរឹបអូស

យើង សេខ លាខ ចៅក្រមតុលាការអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញ សំណុំរឿងអនុវត្តរក្សាការពារ លេខ ១៣៩ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

**ឧបសម្ព័ន្ធ៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

[redacted]

សាលាដំបូងរាជធានីភ្នំពេញ

[redacted]

**ដីកាសម្រេច**

**បង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ**

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា **៦២** នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម ០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញ សំណុំរឿងរក្សាការពារលេខ: [redacted] ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

ម្ចាស់បំណុលឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ [redacted] ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ [redacted] ផ្លូវ [redacted] ភូមិ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

កូនបំណុលឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ [redacted] មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ផ្លូវ [redacted] ខណ្ឌ [redacted] រាជធានីភ្នំពេញ។

ដែលមានកម្មវត្ថុបណ្តឹង: សុំឲ្យតុលាការចេញសេចក្តីសម្រេចរក្សាការពារមិនឲ្យធ្វើសកម្មភាព លក់-ដូរ ជួលបញ្ចាំ ធានាផ្ទេរសិទ្ធិ ធ្វើអំណោយ ធ្វើប្រទានកម្ម ឬដាក់ប្រាតិភោគ ដាក់ហ៊ីប៉ូតែក អច្ច័យទាន និងរឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុមួយកន្លែងរបស់ឈ្មោះ [redacted] ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: [redacted] ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៦ មានទំហំ ៣០៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិ១១ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សំអាងហេតុ**

-ដើម្បីដំណើរការនីតិវិធីតាមផ្លូវច្បាប់។

-គប្បីតម្រូវឲ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ដើម្បីចំណាយក្នុងការបញ្ជូនឯកសារ បើដើមចោទមិនបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធនេះទេតុលាការនឹងលើកពាក្យបណ្តឹងនេះចោល។

**ហេតុដូច្នេះសម្រេច**

បង្គាប់ឲ្យម្ចាស់បំណុលឈ្មោះ [redacted] បង់ប្រាក់ប្រដាប់ក្តីតុលាការ ក្រៅពីពន្ធចំនួន **១00.000៛** (ដប់ម៉ឺនរៀល) នៅសាលាដំបូងរាជធានីភ្នំពេញ [redacted] ក្នុងរយៈពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃទទួលដំណឹងនេះ ជាកំណត់ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

**ឧបសម្ព័ន្ធ៦**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

បន្ទប់

សាលាដំបូងរាជធានីភ្នំពេញ

លេខ:.................ដ.ប/២១

**ដីកាបញ្ជូន**

**គោរពជូន ៖**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធលេខ .................. រ.វ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។ | ០២.ស | ដើម្បី ធ្វើនីតិវិធីបញ្ជូនឲ្យទៅឈ្មោះ **ក** |
| ០២ | -ដីកាកោះ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។<br>ក្នុងសំណុំរឿងរក្សាការពារលេខ ... ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។ | ០២.ស | |
| សរុប | | ០៤.ស | |

ថ្ងៃអង្គារ ៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៩.ខែមិថុនា ឆ្នាំ២០២១

**ចៅក្រម**

**ឧបសម្ព័ន្ធ៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ:...07.......ផ.អ

ថ្ងៃពុធ ៤កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩

## លិខិតផ្ទុកផ្តាក់
## ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ

### ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ
### គោរពជូន
### លោកប្រធាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

<u>កម្មវត្ថុ:</u> ស្តីពីការផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូស

<u>យោង:</u> -សំណុំរឿងអនុវត្តលេខ២៦២ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

**ក-សញ្ញាណនៃអចលនវត្ថុ:** អចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ៣១៧០២ (ញv ០៤២៥) ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ មានទំហំ ១៥៩៦ម$^{2}$ មានទីតាំងនៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**ខ-កម្មសិទ្ធិករ:** ឈ្មោះ ស៊ាន វុត ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**គ-គោលបំណងនៃការចុះបញ្ជី:** ចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ៣១៧០២ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឈ្មោះ ស៊ាន វុត ដើម្បីចាប់ផ្តើមការលក់ដោយបង្ខំ។

**ឃ-មូលហេតុ:** ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ...08.....“ត” វ.វ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

**ង-ម្ចាស់បំណុលនៃការអនុវត្ត:**

**-ធនាគារ អ អេច ប៊ី ឥណ្ឌូចៃណា លីមីធីត (RHB INDOCHINA BANK LIMITED)** ការិយាល័យកណ្តាល អគារលេខ២៦៣ ផ្លូវអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ តំណាងដោយលោក យ៉ឹង អ៊ីងសាន។

ច-អត្តសញ្ញាណនៃភាគីអនុវត្ត:

-ឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

**ស្ថាប័នអនុវត្ត:** បើបានចុះបញ្ជីអចលនវត្ថុដូចមានចែងក្នុងសញ្ញាណ នៃអចលនវត្ថុខាងលើរួចរាល់ហើយ សូមផ្ញើឯកសារចម្លងដែលមានបញ្ជាក់ការចុះបញ្ជីក្នុងសៀវភៅនោះមកក្រឡាបញ្ជីសាមីវិញ។

**ឯកសារជូនភ្ជាប់មកជាមួយៈ**

-ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំលេខ.[redacted] ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។ (ថតចម្លង១ច្បាប់)

ក្រឡាបញ្ជី

[redacted]

[redacted]

## ឧបសម្ព័ន្ធ៨

ឧបសម្ព័ន្ធទី ១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង................

លេខ.....................

...............,ថ្ងៃទី....ខែ.......ឆ្នាំ.......

### លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

( ប្រការ ១៧ )

យើង.........................ក្រឡាបញ្ជីនៃសាលាដំបូង................................

សូមជម្រាបជូន

លោក/លោកស្រី ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង

សុរិយោដី.........(រដ្ឋបាលសុរិយោដីរាជធានី ខេត្ត)

**កម្មវត្ថុ :** ............(ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នទូវកម្មសិទ្ធិ សិទ្ធិផ្លូលអចិន្ត្រៃយ៍ ឬផលុបភោគ)..................................................។

ក-អត្តសញ្ញាណនៃអចលនវត្ថុ លេខក្បាលដី ឬ លេខប័ណ្ណ:........................
ទីតាំងដី : ......................................................................
.....................................................................។

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិផ្លូលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ .....
អាសយដ្ឋាន :.....................................................................
.....................................................................។

គ-គោលបំណងនៃការចុះបញ្ជី:......(លុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នទូវកម្មសិទ្ធិ ឬសិទ្ធិសិទ្ធិផ្លូលអចិន្ត្រៃយ៍ ឬផលុបភោគ)..........(ទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ :.............................................................

-(ការដកពាក្យសុំដីការីបម្លូសជាបណ្ដោះអាសន្ន ឬការដកពាក្យសុំអនុវត្តវិបម្លូសជាបណ្ដោះអាសន្ន ចុះថ្ងៃទី ......ខែ......ឆ្នាំ.......) ឬ

-(ដីកាសម្រេចលុបចោលការអនុវត្តការវិបម្លូសជាបណ្ដោះអាសន្នលេខ.......ចុះថ្ងៃទី.....ខែ......ឆ្នាំ....... ហើយថ្ងៃទី......ខែ.......ឆ្នាំ....... ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ...............................) ។

ង-ឈ្មោះម្ចាស់បំណុល :..................................................

អាសយដ្ឋាន :..................................................................

.................................។.................................................។

ច-ឈ្មោះកូនបំណុល :..................................................

អាសយដ្ឋាន :..................................................................

..........................................................................។

**ឯកសារភ្ជាប់ជាមួយ :**

(ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ)

ហត្ថលេខា និង ត្រា

ឈ្មោះក្រឡាបញ្ជី

**ឧបសម្ព័ន្ធ៩**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **ក្រសួងយុត្តិធម៌**

លេខ:២១៤...ប្រក.ដនស

## ប្រកាសអន្តរក្រសួង

## ស្តីពី

## នីតិវិធីនៃការចុះបញ្ជីធានាខ្ទង់និងការចាត់ចែងរក្សាការពារ និងការរឹបអូស ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ជនស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
- តាមការចាំបាច់ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១._ គោលបំណង

ប្រកាសនេះ មានគោលបំណងធានានូវប្រសិទ្ធភាពនៃការចុះបញ្ជី ទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត ។

### ប្រការ ២._ គោលដៅ

ប្រកាសនេះ មានគោលដៅបញ្ញត្តអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីរបស់តុលាការដែលបានផ្ញើមកស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ។

### ប្រការ ៣._ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចខាងក្រោម ៖

ក. ដីដែលមិនទាន់បានចុះបញ្ជី។

ខ. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។

### ប្រការ ៤._ និយមន័យ

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

១. អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដី និងចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី ។

២. ដីដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដីដែលមិនទាន់បានចុះក្នុងសៀវភៅចុះបញ្ជី ហើយដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬភោគីនៃដីនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី ៣ និងមាត្រា ៥៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣. ចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលតុលាការបានសន្មតថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ ដោយផ្អែកតាមមាត្រា ៤១៧ កថាខណ្ឌទី៣ និងមាត្រា៥៤១ កថាខណ្ឌ ទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. នីតិវិធីចុះបញ្ជីដីលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីដីដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី ។

៥. នីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង គឺសំដៅលើនីតិវិធីចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជីទៅក្នុងសៀវភៅចុះបញ្ជី។

៦. លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺសំដៅលើលិខិតរបស់តុលាការដែលបានផ្ញើមករដ្ឋបាលសុរិយោដី ដើម្បីស្នើសុំធ្វើនីតិវិធីចុះបញ្ជី។

## ជំពូកទី ២
## យន្តការ និងនីតិវិធីនៃការចុះបញ្ជី

### ប្រការ ៥._ ស្ថាប័នមានសមត្ថកិច្ច

១. ស្ថាប័នមានសមត្ថកិច្ចទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ត្រូវចុះលេខនៃការទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីក្នុងសៀវភៅទទួលពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដែលបានបង្កើតឡើងដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត តាមប្រការ ៥ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

ប្រសិនបើរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅដោយគ្មានការយឺតយ៉ាវ ។

នៅពេលរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត បានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តនោះ ត្រូវផ្ញើច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ និងឯកសារពាក់ព័ន្ធផ្សេងទៀត រួមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង ទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅដើម្បីអនុវត្តនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ។

២. ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ។

៣. ចំពោះលំដាប់នៃការចុះបញ្ជី ត្រូវអនុលោមតាមប្រការ ៧ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ។



ᨁ

## ប្រភេទ ៦._ លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

នៅពេលចេញដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅស្ថាប័នមានសមត្ថកិច្ចឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូង និង/ឬចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង និងចុះបញ្ជីអំពីការរឹបអូស ឬរឹបអូសជាបណ្តោះអាសន្ន ឬចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងតាមទម្រង់និងខ្លឹមសារដូចខាងក្រោម ៖

ក. កម្មវត្ថុ: ១. ចាប់ផ្តើមនីតិវិធីចុះបញ្ជីដីលើកដំបូងនិង/ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ។

២. សរសេរអំពីខ្លឹមសារនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូស ។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ: ទីតាំងដី ទំហំដី លេខក្បាលដីនៃទីតាំងអគារសហកម្មសិទ្ធិ ឈ្មោះអគារសហកម្មសិទ្ធិ និងលេខប័ណ្ណ ។

គ. កម្មសិទ្ធិករ ឬភោគីនៃដីដែលត្រូវបានសន្មត : ឈ្មោះ និងអាសយដ្ឋាន ។ ចំពោះអគារសហកម្មសិទ្ធិ ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលត្រូវបានសន្មតជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍ ។

ឃ. គោលបំណងនៃការចុះបញ្ជី : ការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬការរឹបអូសកម្មសិទ្ធិ សិទ្ធិភោគៈ ឬសិទ្ធិជួលអចិន្ត្រៃយ៍ (ចំពោះតែចំណែកឯកជននៃអគារសហកម្មសិទ្ធិ) ។

ង. មូលហេតុ : ដីកាសម្រេចឱ្យរឹបអូសជាបណ្តោះអាសន្ន ដីកាសម្រេចអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ....ចុះថ្ងៃទី ខែ ឆ្នាំ ។

ច. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត

ឆ. - ចំពោះការរក្សាការពារ សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

- ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត

ឯកសារភ្ជាប់ មានដូចខាងក្រោម ៖

- ចំពោះការរក្សាការពារ :
  - ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
  - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែង
  - ឯកសារនៃសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដែលមានចែងនៅក្នុងមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
- ចំពោះការរឹបអូស :
  - ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ
  - ឯកសារបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍ របស់កូនបំណុលនៃការរឹបអូសអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ដូចមានចែងក្នុងមាត្រា ៤១៧ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ប្រការ ៧._ ការចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូង

១. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះដីដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីដីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. នៅពេលដែលបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកលើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ឬដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំចំពោះចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី និងទទួលបានលិខិតអនុញ្ញាតឱ្យចាប់ផ្តើមធ្វើនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីដោយគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមបទដ្ឋានគតិយុត្តទាក់ទងនឹងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូងដែលនៅជាធរមាន ។

៣. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ បញ្ញត្តិនៃប្រការ ៨០ និងប្រការ ៨១ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ប្រការ ៨._ ការចុះបញ្ជីអំពីការចាត់ចែងរក្សាការពារនិងការរឹបអូសតាមលិខិតផ្ទុកផ្តាក់

១. នៅពេលដែលការចុះបញ្ជីដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិដោយអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវបានបញ្ចប់ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅត្រូវសរសេរនៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" អំពីការចុះបញ្ជីនោះ យោងតាមលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី និងតាមប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីដោយគ្មានការយឺតយ៉ាវ ។

២. នៅពេលធ្វើការចុះបញ្ជីដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃប្រការនេះ បញ្ញត្តិនៃប្រការ៨៣ នៃប្រកាសអន្តរក្រសួងលេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

## ប្រការ ៩._ កាតព្វកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្តជាអាទិ៍

ម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តដែលមានក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី មានកាតព្វកិច្ចបង់ជាមុននូវការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង និងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ផ្អែកតាមមាត្រា ៣៧៤ និងមាត្រា ៥៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ប្រការ ១០._ ការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី

រដ្ឋបាលសុរិយោដីដែលបានចាប់ផ្តើមនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ អាចលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីបាន ចំពោះករណីដូចខាងក្រោមនេះ ៖

១. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬភោគីនៃដីដែលជាកម្មវត្ថុនៃការចុះបញ្ជីនៅពេលកំពុងដំណើរការនីតិវិធីចុះបញ្ជីលើកដំបូង ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីដីលើកដំបូងដែលនៅជាធរមាន ។

២. ក្នុងករណីដែលរកឃើញច្បាស់ថា កូនបំណុល ឬកូនបំណុលនៃការអនុវត្តមិនមែនជាកម្មសិទ្ធិករ ឬអ្នកជួលអចិន្ត្រៃយ៍នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលជាកម្មវត្ថុនៃការចុះបញ្ជី នៅពេលកំពុងដំណើរការនីតិវិធីដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ ដោយផ្អែកតាមបទដ្ឋានគតិយុត្តទាក់ទងនឹងការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលនៅជាធរមាន ។

៣. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ឯកសារភ្ជាប់ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ មកជាមួយនឹងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ។

៤. ក្នុងករណីដែលពុំបានផ្តល់ឯកសារចាំបាច់សម្រាប់នីតិវិធីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ក្នុងអំឡុងពេលសមរម្យដែលកំណត់ដោយមន្ត្រីចុះបញ្ជី ។

៥. ក្នុងករណីដែលតុលាការអនុវត្តពុំបានផ្តល់ទៅឱ្យរដ្ឋបាលសុរិយោដីនូវសោហ៊ុយសេវាផ្សេងៗទាក់ទងនឹងការចុះបញ្ជីដីលើកដំបូង ឬការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិលើកដំបូង ដែលម្ចាស់បំណុល ឬម្ចាស់បំណុលនៃការអនុវត្តបានបង់តាមប្រការ ៩ នៃប្រកាសនេះរួចហើយ ។

៦. ក្នុងករណីដែលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីត្រូវបានដាក់ខុសសមត្ថកិច្ច ។

៧. ករណីចំណុចដែលមាននៅក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីផ្ទុយនឹងប្រកាសនេះ ។

ក្នុងករណីមានការលើកចោលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីដោយផ្អែកតាមប្រការនេះ រដ្ឋបាលសុរិយោដីត្រូវធ្វើលិខិតលើកចោលជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុនៃការលើកចោល ហើយត្រូវផ្ញើលិខិតលើកចោលនេះ និងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី រួមទាំងឯកសារភ្ជាប់ទៅតុលាការដែលបានចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ ។

## ប្រការ ១១._ នីតិវិធីនៃការចុះបញ្ជីលើកដំបូង ក្រោយពីការលើកចោល

១. ទោះបីជាមានការលើកចោលនូវលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ដោយផ្អែកតាមប្រការ ១០ កថាខណ្ឌទី ១ ចំណុចទី ១ និងចំណុចទី២ ក៏ដោយ ក៏ការលើកចោលនេះពុំរារាំងដល់ការអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមការស្នើសុំពីបុគ្គលដែលត្រូវជាកម្មសិទ្ធិករឬភោគីនៃដីពិតប្រាកដ ឬកម្មសិទ្ធិករឬអ្នកជួលអចិន្ត្រៃយ៍ចំណែកឯកជននៃអគារសហកម្មសិទ្ធិពិតប្រាកដឡើយ។

២. ម្ចាស់សិទ្ធិពិតប្រាកដដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើ ជាអ្នកទទួលបន្ទុកលើសោហ៊ុយសម្រាប់ការចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ។

ក្នុងករណីដែលម្ចាស់សិទ្ធិពិតប្រាកដនោះ មិនបានបង់សោហ៊ុយនោះទេ មន្ត្រីចុះបញ្ជីមានសិទ្ធិផ្អាកនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដី ឬចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះបាន ។

# ជំពូកទី៣

# អន្តរប្បញ្ញត្តិ

## ប្រការ ១២._ អន្តរប្បញ្ញត្តិ

ប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីចុះបញ្ជីតាមរយៈលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដែលត្រូវបានផ្ញើមករដ្ឋបាលសុរិយោដីមានសមត្ថកិច្ចមុនការអនុវត្តប្រកាសអន្តរក្រសួងនេះ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលនីតិវិធីចុះបញ្ជីទាំងនោះត្រូវបានអនុវត្តរួចហើយ ។

# ជំពូកទី៤
# អវសានប្បញ្ញត្តិ

## ប្រការ ១៣._ ភាលបរិច្ឆេទនៃភារអនុវត្ត

ប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

## ប្រការ ១៤._ និរាករណ៍នៃបទប្បញ្ញត្តិដែលផ្ទុយ

បទប្បញ្ញត្តិទាំងឡាយណាដែលមានអានុភាពពេលប្រកាសនេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងប្រកាសនេះ ចាប់ពីថ្ងៃដែលប្រកាសនេះត្រូវបានអនុវត្ត ។

រាជធានីភ្នំពេញ ថ្ងៃទី.២១.ខែ.វិច្ឆិកា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

អង្គ.វង្សវឌ្ឍ

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល "ដើម្បីជូនជ្រាប"
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តុលាការគ្រប់ជាន់ថ្នាក់
- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមសាលាដំបូងរាជធានី ខេត្ត
- សាលារាជធានី ខេត្ត
- មន្ទីរ ដនសស "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ